# ធនាគារ អេស៊ីលីដា ភីអិលស៊ី

ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត




# របាយការណ៍ប្រចាំឆ្នាំ

# ២០១៨

# អេស៊ីលីដា យូនីធីទាន់ចិត្ត

ACLEDA Unity ToanChet

Available on the App Store

GET IT ON Google Play

ជាធនាគារផ្ទាល់ខ្លួនរបស់លោកអ្នក
ដែលអាចធ្វើប្រតិបត្តិការសេវា
ធនាគារអេស៊ីលីដាគ្រប់ប្រភេទ

24/7

*Your personal bank with access available to all ACLEDA Bank Services*

**ទូទាត់វិក្កយបត្រ**
Bill Payment

**ផ្ទេរប្រាក់**
Fund Transfer




**បញ្ចូលទឹកប្រាក់ទូរស័ព្ទដៃ**
Mobile Phone Top Up

**ទូទាត់ទាន់ចិត្ត**
ToanChet Payments

# ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

# បេសកកម្ម

បេសកកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយនាយកដ្ឋានទីផ្សារ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖

ការិយាល័យកណ្តាល ៖

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
SWIFT Code: ACLBKHPP
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
វេបសាយ ៖ www.acledabank.com.kh

ការិយាល័យទំនាក់ទំនងអតិថិជន
(បម្រើ ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃ ក្នុងមួយសប្តាហ៍) ៖

ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជាខ្ទង់ពាន់ដុល្លារអាមេរិក | ៣១/១២/១៨ បានធ្វើសវនកម្ម | ៣១/១២/១៧ បានធ្វើសវនកម្ម | ៣១/១២/១៦ បានធ្វើសវនកម្ម | ៣១/១២/១៥ បានធ្វើសវនកម្ម | ៣១/១២/១៤ បានធ្វើសវនកម្ម | បម្រែបម្រួល (%)[១] |
|---|---|---|---|---|---|---|
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេបរួម** | | | | | | |
| ទ្រព្យសកម្ម | ៥.៦៤១.៣៧២ | ៥.២៤៤.៣៦៧ | ៤.៦៦៤.៧២៦ | ៣.៨៨៥.៣១៧ | ៣.១៣៩.៧៧២ | ៧,៥៧% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ៣.៥១៣.៥៩៤ | ៣.០៨៥.២១៥ | ២.៨៤១.៣៩១ | ២.៥០៧.៨៨៧ | ២.០៤៣.៦៨៨ | ១៣,៨៨% |
| បំណុល | ៤.៨៣៤.៩៩៧ | ៤.៥០៤.១៥២ | ៤.០០៣.៩៣៦ | ៣.៣៤០.៨២២ | ២.៦៩៨.៦២៤ | ៧,៣៥% |
| ប្រាក់បញ្ញើ | ៣.៨៣៥.៨៣០ | ៣.៣២៩.៦៦៥ | ៣.១២៦.១៧១ | ២.៦៩៥.៦៤០ | ២.២៦៩.៨៩១ | ១៥,២០% |
| ដើមទុន | ៣៩៥.២២៤ | ៣៥៨.៥៤៥ | ៣០៧.៧៦៤ | ២៦៥.៧២៦ | ២២៥.៥៣៦ | ១០,២៣% |
| មូលនិធិម្ចាស់ហ៊ុន [២] | ៨០៦.៣៧៥ | ៧៣៥.៧៣៣ | ៦៥៧.១៥៩ | ៥៤១.១៦៨ | ៤៣៧.៣៦៧ | ៩,៦០% |
| ចំណូលដុល | ៥០២.៦០៤ | ៤៩៤.៨០៩ | ៤៧៥.៦០៤ | ៤០៣.៦៤៥ | ៣១៦.៩៤០ | ១,៥៨% |
| ប្រាក់ចំណេញមុនដកពន្ធ | ១០៦.៦០៨ | ១១៦.៣៧២ | ១៥៨.៣៨៣ | ១៣២.៥៩១ | ១០២.០០៥ | -៨,៣៩% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ៨៤.០០៩ | ៩១.៦៨៥ | ១២៦.៨៨៧ | ១០៥.០៦៨ | ៨០.៣៦៩ | -៨,៣៧% |
| ចំណេញក្នុងមួយភាគហ៊ុន | ០,២១២៦$ | ០,២៥៥៧$ | ០,៤១២៣$ | ០,៣៩៥៤$ | ០,៣៥៦៣$ | -១៦,៨៦% |
| ភាគលាភ [៣] | ០,១០៦៣$ | ០,១២៧៨$ | ០,២០៦២$ | ០,១៩៧៧$ | ០,១៧៨២$ | -១៦,៨២% |
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេបដាច់ដោយឡែក** | | | | | | |
| ទ្រព្យសកម្ម | ៥.៥២៤.៥២៩ | ៥.១២១.៧២៤ | ៤.៥៦១.០២៤ | ៣.៨០២.៤៦៣ | ៣.០៥១.៤៦០ | ៧,៨៦% |
| ឥណទាន និងបុរេប្រទាន (សុទ្ធ) | ៣.៣៧៨.៦៦៩ | ២.៩៣៩.៨៧៤ | ២.៧១៣.៦៣៥ | ២.៤០៥.៤៦៥ | ១.៩៥៥.០៨៣ | ១៤,៩៣% |
| បំណុល | ៤.៧០៨.៧៤៤ | ៤.៣៧៧.៥៤៤ | ៣.៨៩០.៦៥០ | ៣.២៤៣.៨៩៨ | ២.៥៩៩.០៥៥ | ៧,៥៧% |
| ប្រាក់បញ្ញើ | ៣.៧៥៣.៤០៣ | ៣.២៤៩.៩៥២ | ៣.០៥១.៦៧៦ | ២.៦១៦.៣៦១ | ២.២០២.៣៨៤ | ១៥,៤៩% |
| ដើមទុន | ៣៩៥.២២៤ | ៣៥៨.៥៤៥ | ៣០៧.៧៦៤ | ២៦៥.៧២៦ | ២២៥.៥៣៦ | ១០,២៣% |
| មូលនិធិម្ចាស់ហ៊ុន | ៨១៥.៧៨៤ | ៧៤៤.១៨១ | ៦៧០.៣៧៤ | ៥៥៨.៥៦៥ | ៤៥២.៤០៥ | ៩,៦២% |
| ចំណូលដុល | ៤៧០.៨១៩ | ៤៦២.៩៩០ | ៤៤៥.៧៤០ | ៣៨០.០១៨ | ២៩៦.៥១៩ | ១,៦៩% |
| ប្រាក់ចំណេញមុនដកពន្ធ | ១០១.២៦ | ១០៨.១៤៦ | ១៥២.៨២១ | ១៣២.៩៣៣ | ១០២.៩៥៣ | -៦,៣៧% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ៨០.៧៤៧ | ៨៦.៤៨៧ | ១២២.៣០៥ | ១០៦.១៥៩ | ៨២.២២០ | -៦,៦៤% |
| ចំណេញក្នុងមួយភាគហ៊ុន | ០,២០៤៣$ | ០,២៤១២$ | ០,៣៩៧៤$ | ០,៣៩៩៥$ | ០,៣៦៤៦$ | -១៥,៣០% |

## ចំណុចសំខាន់ៗក្នុងឆ្នាំ២០១៨

- ទ្រព្យសកម្ម កើនឡើង ៧,៥៧% រហូតដល់ ៥.៦៤១,៣៧ លានដុល្លារអាមេរិក ។
- សមតុល្យឥណទាន (សុទ្ធ) កើនឡើង ១៣,៨៨% រហូតដល់ ៣.៥១៣,៥៩ លានដុល្លារអាមេរិក ។
- ឥណទានមិនដំណើរការធៀបនឹងឥណទានសរុប មានចំនួន ១,៧៣% ។
- សេវាបញ្ញើ-សន្សំកើនឡើង ១៥,២០% រហូតដល់  ៣.៨៣៥,៨៣ លានដុល្លារអាមេរិក ។
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ បែងចែកជូនម្ចាស់ភាគហ៊ុនរបស់ធនាគារ មានចំនួន ៨៤,០១ លានដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុន [២] កើនឡើង ៩,៦០% ពី ៧៣៥,៧៣ លានដុល្លារអាមេរិក ដល់ ៨០៦,៣៨ លានដុល្លារអាមេរិក ។
- ផលលើមូលធន មានចំនួន ១០,៤២% ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបណ្តាញប្រតិបត្តិការចំនួន ២៦២ សាខា គ្របដណ្តប់គ្រប់ខេត្ត និងរាជធានី ទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៥ គឺ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អេស៊ីលីដា ប្រូភើធី អិលធីឌី ធនាគារ អេស៊ីលីដា ឡាវ (៣៩ ការិយាល័យ) និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៨ ការិយាល័យ) ព្រមទាំងមានការិយាល័យតំណាងនៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។

---

១ បម្រែបម្រួលពី ឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ ។
២ មិនគិតបញ្ចូលភាគហ៊ុនអប្បភាគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
៣ ភាគលាភឆ្នាំ២០១៤ (បែងចែកជាភាគហ៊ុន) ស្មើនឹង ៥០% នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ។
សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ បែងចែកជាសាច់ប្រាក់ ស្មើនឹង១០% និង ៤០% បែងចែកជាភាគហ៊ុន នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ។

# របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារដែលមានតម្លាភាពមួយ យើងខ្ញុំសូមផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម ៖

| គិតជាដុល្លារអាមេរិក | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប * |
|---|---|---|---|---|---|---|
| ពន្ធប៉ាតង់ | ៦.៥៧១ | ៧.០២៥ | ១៩.០៣៦ | ១៩.៣០៩ | ២០.៩៣៦ | ១៥២.៤១៧ |
| ពន្ធលើស្លាកសញ្ញា | ៦៥.៧៩៦ | ៧៣.៩៣១ | ៧៥.៨២៦ | ៣៦.៩៨៣ | ៥៧.៦៩៥ | ៦៥១.៩៩៣ |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន | ៤៧.០៤៩ | ៤០.៧៧៩ | ៤១.៨៦៤ | ៣៩.២៦៩ | ៣៧.២៤២ | ២៩៧.៥៥៧ |
| ពន្ធលើអចលនទ្រព្យ | ៦.៨៧១ | ២៣.៣៩០ | ៧.៦៥១ | ២២.៩៦៤ | ២៣.០៩៤ | ១០៤.៤១៨ |
| អាករលើតម្លៃបន្ថែម | ១.២៤៨ | ៧.០៤២ | - | - | ១.២៦៦ | ៩.៥៥៦ |
| ប្រាក់រំលោះពន្ធលើប្រាក់ចំណេញ | ២.៩១៣.៦៤៦ | ៣.៧៤៧.៩០៨ | ៤.៣៩៦.៦៦០ | ៤.៦៨១.៧៣៣ | ៤.៦៨២.៤២៨ | ៣១.៨៤៧.៧៣០ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១៥.១៣៧.៥១០ | ២០.៨៤៤.១៣៤ | ២៥.៩៩៣.២១៧ | ៣៥.១២០.៥៤៧ | ២២.៣៤០.៣៣០ | ១៦៨.១៩៦.៧០៦ |
| ពន្ធលើប្រាក់បៀវត្សរ៍ | ៣.៥៨៣.៦១២ | ៣.៧៣៥.៩៦៦ | ៥.០៣៣.៥៥៧ | ៤.០៩២.៩៦៩ | ៩.៣៩៤.៦៥៥ | ៤១.២៦៧.៧៣៧ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើសន្សំ | ១៦១.០៥១ | ២០៩.៦២៥ | ២២៤.២៨៤ | ២៥៦.៣៦៧ | ២២៥.៤៥១ | ២.០០៥.៤០៨ |
| ពន្ធកាត់ទុកលើប្រាក់បញ្ញើ មានកាលកំណត់ | ២.០៩៤.៧១៥ | ៤.៦៨៦.៨៨៩ | ៣.៩០៤.៨៦៥ | ៤.៤១០.៨១៩ | ៤.២០៨.៣២០ | ២៦.០១១.១២៧ |
| ពន្ធកាត់ទុកលើថ្លៃជួលអចលនទ្រព្យ | ៧២២.៩៨២ | ៧៨៥.៩៦៤ | ៨៥៦.៤០០ | ៩៣៣.៩៩៦ | ៩៧៦.៧១៩ | ៨.២១៧.៥១២ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្នុងប្រទេស | ២៤៥.៥០៦ | ២៤៦.៦៦៥ | ២៨៨.១៥៩ | ៣៤៤.៤៩៥ | ៣២៧.៣៩០ | ៣.៤៤៥.០៨៨ |
| ពន្ធកាត់ទុកលើថ្លៃសេវាក្រៅប្រទេស | ២.១៩១.៨៦៣ | ៣.០១៥.២៩៩ | ៤.៧២៤.៥៤២ | ៦.០៤៩.៧១៣ | ៦.៣៩១.៣៦៣ | ៣២.៩៦០.៤៩៧ |
| សរុប | ២៧.១៧៨.៤២០ | ៣៧.៤២៤.៦១៨ | ៤៥.៥៦៦.០៦១ | ៥៦.០០៩.១៦៤ | ៤៨.៦៨៦.៨៨៥ | ៣១៥.១៦៧.៧៤៥ |
| សរុបយោង * (មកដល់បច្ចុប្បន្ន) | ១២៧.៤៨១.០១៧ | ១៦៤.៩០៥.៦៣៤ | ២១០.៤៧១.៦៩៦ | ២៦៦.៤៨០.៨៦០ | ៣១៥.១៦៧.៧៤៥ | |

* សរុប និងសរុបយោង គិតចាប់ពីឆ្នាំ២០០០ មក ។

រូបថតអនុស្សាវរីយថ្នាក់ដឹកនាំជាន់ខ្ពស់ និងនាយក-នាយិកាសាខា របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩



# លទ្ធផលសម្រេចបាន *




ទ្រព្យសកម្មសរុប (គិតជាលានដុល្លារអាមេរិក)




សមតុល្យឥណទាន (គិតជាលានដុល្លារអាមេរិក)




ប្រាក់បញ្ញើ-សន្សំ (គិតជាលានដុល្លារអាមេរិក)




ចំនួនម៉ាស៊ីនអេធីអឹម




អេស៊ីលីដាយូនីធីទាន់ចិត្ត (ធនាគារអេឡិចត្រូនិក)

- ចំនួនអ្នកប្រើប្រាស់
- សមតុល្យគណនី (គិតជាដុល្លារអាមេរិក)

* តួលេខទាំងនេះ គិតតែប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ដូចនេះមានភាពខុសគ្នាពីរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងបុត្រសម្ព័ន្ធ ។

# មាតិកា


៦ សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា
៧ របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល
៩ របាយការណ៍ប្រធាននាយកប្រតិបត្តិ
១៣ អង្គការលេខ
១៤ បណ្តាញប្រតិបត្តិការ

១៥ អភិបាលកិច្ចសាជីវកម្ម
១៥ កិច្ចប្រជុំភាគទុនិក
១៥ ភាគទុនិក

១៧ ក្រុមប្រឹក្សាភិបាល
២២ គណៈកម្មាធិការប្រតិបត្តិ
៣២ សវនករផ្ទៃក្នុង
៣៣ ក្រុមសីលធម៌

៣៤ របាយការណ៍ក្រុមប្រឹក្សាភិបាល
៣៤ របាយការណ៍គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល
៣៤ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
៣៥ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់
៣៦ គណៈកម្មាធិការឥណទាន
៣៧ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន
៣៧ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង
៣៨ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

៤០ របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

៤៤ របាយការណ៍ហិរញ្ញវត្ថុរួម និង
របាយការណ៍ហិរញ្ញវត្ថុដោយឡែក

៤៥ របាយការណ៍ក្រុមប្រឹក្សាភិបាល
៤៨ របាយការណ៍សវនករឯករាជ្យ

*របាយការណ៍ហិរញ្ញវត្ថុរួម*
៥០ តារាងតុល្យការរួម
៥១ របាយការណ៍លទ្ធផលរួម
៥២ របាយការណ៍បម្រែបម្រួលមូលធនរួម
៥៣ របាយការណ៍លំហូរសាច់ប្រាក់រួម

*របាយការណ៍ហិរញ្ញវត្ថុដោយឡែក*
៥៤ តារាងតុល្យការដោយឡែក
៥៥ របាយការណ៍លទ្ធផលដោយឡែក
៥៦ របាយការណ៍បម្រែបម្រួលមូលធនដោយឡែក
៥៧ របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក
៥៨ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

១២៨ ការផ្តល់ចំណាត់ថ្នាក់
១២៩ ឧបសម្ព័ន្ធគំនិតផ្តួចផ្តើមនៃរបាយការណ៍ពិភពលោក (GRI)
១៣០ សាខាធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ
១៤២ ធនាគារដៃគូ


កិច្ចប្រជុំនាយក-នាយិកាសាខា របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩



# សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧e | ២០១៨e | ២០១៩f |
|---|---|---|---|---|---|---|
| **១. ផលិតផលសរុបក្នុងស្រុក ( GDP )** | | | | | | |
| បម្រែបម្រួលផលិតផលសរុបក្នុងស្រុក ( គិតជាភាគរយ ) | ៧,១ | ៧ | ៧ | ៧ | ៧ | ៧,១ |
| ចំណូលក្នុងម្នាក់ ( គិតជាដុល្លារអាមេរិក ) | ១.១៣៨ | ១.២១៥ | ១.៣០២ | ១.៤២៧ | ១.៥៦៣ | ១.៧០៦ |
| **២. អតិផរណា** | | | | | | |
| អតិផរណា ( មធ្យមប្រចាំឆ្នាំ ) | ៣,៩ | ១,២ | ៣ | ២,៩ | ២,៥ | ៣,១ |
| ( ចុងឆ្នាំ ) | ១,១ | ២,៨ | ៣,៩ | ២,២ | ១,៦ | - |
| **៣. ថវិការបស់រដ្ឋាភិបាល ( គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក )** | | | | | | |
| ចំណូល | ១៧,១ | ១៧,៣ | ១៨,៩ | ២០,២ | ១៨,៧ | ១៩,៣ |
| ចំណាយ | ២១,៦ | ២០,៩ | ២២ | ២៣,៥ | ២៤,៥ | ២៤,៧ |
| **៤. រូបិយវត្ថុ និងឥណទាន ( បម្រែបម្រួលជាភាគរយក្នុង ១២ខែ )** | | | | | | |
| រូបិយវត្ថុទូទៅ ( M2 ) | ២៩,៩ | ១៤,៧ | ១៧,៩ | ២៣,៨ | ២៤,២ | - |
| ប្រាក់បញ្ញើសរុបនៅក្នុងប្រព័ន្ធធនាគារ | ២៩ | ១៧,៤ | ២១,៨ | ២៥,១ | ១៤ | - |
| ឥណទានសរុបនៅក្នុងប្រព័ន្ធធនាគារ | ២៧,១ | ២៥,៧ | ២០,៥ | ១៧,២ | ២០,១ | - |
| ឥណទានធៀបនឹងប្រាក់បញ្ញើ ( គិតជាភាគរយ ) | ៩៥,៩ | ១០២,៦ | ១០០,៦ | ៩៥,៣ | ៩៩,៦ | - |
| ឥណទានវិស័យឯកជន | ៣១,៣ | ២៧,១ | ២២,៥ | ១៨,៥ | ២០,១ | - |
| ប្រាក់បញ្ញើធៀបនឹងផលិតផលសរុបក្នុងស្រុក | ៥៩,២ | ៦១,៩ | ៦៨,៤ | ៨៥,៦ | ៨០ | - |
| ឥណទានធៀបនឹងផលិតផលសរុបក្នុងស្រុក | ៥៦,៧ | ៦៣,៥ | ៦៨,៨ | ៨០,៧ | ៧៩,៧ | - |
| **៥. ជញ្ជីងទូទាត់ ( គិតជាលានដុល្លារអាមេរិក )** | | | | | | |
| ការនាំចេញ | ៧.៧០៦ | ៨.៩៧០ | ៩.៥៩៥ | ១០.៧៧៧ | ១១.២១៤ | - |
| ការនាំចូល | ១០.៥៣៤ | ១១.៥៤៤ | ១២.០៧០ | ១៣.០១៩ | ១៣.៧៧១ | - |
| ជញ្ជីងពាណិជ្ជកម្ម | -២.៨២៨ | -២.៥៧៤ | -២.៤៧៥ | -២.២៤២ | -២.៥៥៧ | - |
| គណនីចរន្ត ( មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ ) | -១.៨៩៩,៧ | -២.០០៧ | -២.០៤១ | -២.១៦១ | -២.៤៣២ | -២.៦៣៨ |
| ផលិតផលសរុបក្នុងស្រុកជាមធ្យម ( គិតជាពាន់លានដុល្លារអាមេរិក ) | ១៦,៨ | ១៨,០៨ | ១៩,៨៦ | ២២,១៦ | ២៤,៦១ | ២៧,២២ |
| អត្រាប្តូរប្រាក់ ( រៀលក្នុងមួយដុល្លារ នៅចុងគ្រា ) | ៤.០៣៩ | ៤.០៦២ | ៤.០៥៦ | ៤.០៤៥ | ៤.០៣៧ | ៤.០៣៧ |

ប្រភព ៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី ធនាគារជាតិនៃកម្ពុជា ធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

e: ប៉ាន់ប្រមាណ និង f: ព្យាករណ៍ ។

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



## លោក ឆាយ សឿន
ប្រធានក្រុមប្រឹក្សាភិបាល

"ជំនួសមុខឱ្យក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ២០១៨ ជូនដល់ភាគទុនិក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។"

## សេដ្ឋកិច្ចកម្ពុជា

ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចនឹងកើនឡើង ៧,១% និង ៧% សម្រាប់ឆ្នាំ២០១៨ ។ កំណើននេះបន្តរីកចម្រើនក្នុងល្បឿនមួយដ៏រឹងមាំ ដោយជម្រុញពិពិធកម្មនាំចេញសំណាង់រឹងមាំ និងសកម្មភាពទេសចរណ៍ ជាមួយលក្ខខណ្ឌផ្សេងៗល្អប្រសើរ និងការគាំទ្រលើគោលនយោបាយសារពើពន្ធ ។

## វិស័យហិរញ្ញវត្ថុ

ដោយសារតែប្រទេសកម្ពុជាមានសន្តិភាព ស្ថិរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ទើបធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ នូវចំនួនគ្រឹះស្ថានហិរញ្ញវត្ថុក្នុងឆ្នាំ២០១៨ ដែលបច្ចុប្បន្នមានធនាគារពាណិជ្ជ ចំនួន ៤៣, ធនាគារឯកទេស ចំនួន ១៤, និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ចំនួន ៧៨ ។

យើងខ្ញុំសូមស្វាគមន៍ចំពោះបទប្បញ្ញត្តិថ្មីៗ ដែលបានចេញដោយ ធនាគារជាតិ នៃ កម្ពុជា ដែលផ្តោតលើការឆ្លើយតបទៅនឹងតម្រូវការកាត់បន្ថយហានិភ័យការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ហើយជាពិសេស ដើម្បីពង្រឹងការការពារអតិថិជន ក្នុងចំណោមយន្តការជាច្រើនផ្សេងទៀត ដែលមានគោលដៅល្អបំផុតដើម្បីធានាកំណើនប្រកបដោយនិរន្តរភាព នៅក្នុងវិស័យហិរញ្ញវត្ថុ ។

## ធនាគារ អេស៊ីលីដា ភីអិលស៊ី

ក្នុងឆ្នាំ២០១៨ នេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបន្តអនុវត្តគោលដៅចម្បង ដែលបានចែងនៅក្នុងយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ (២០១៨ ដល់ ២០២២) របស់ធនាគារ ដើម្បីក្លាយជាធនាគារពាណិជ្ជក្នុងតំបន់ ជា "ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត" ជាមួយនឹងការប្រកួតប្រជែងនៅក្នុងទីផ្សារ ។ ការផ្តល់តម្លាភាព និងទំនុកចិត្ត ទៅដល់អ្នកដែលពាក់ព័ន្ធ គឺជាចំណូលរយៈពេលវែង ដោយយើងនៅតែបន្តគាំទ្រដល់របៀបវារៈកំណើនសេដ្ឋកិច្ច និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ចតុកោណរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅតែបន្តពង្រឹងគំរូអាជីវកម្មរបស់ធនាគារ និងសម្រួលដល់ការផ្តល់សេវាកម្មធនាគារដល់អតិថិជន ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលធ្វើឱ្យធនាគារទទួលបានប្រាក់ចំណូលប្រកបដោយនិរន្តរភាពយូរអង្វែង ដើម្បីផ្តល់ផលប្រយោជន៍ដល់ភាគទុនិករបស់ធនាគារ ។

ក្នុងឆ្នាំនេះ និងឆ្នាំក្រោយតទៅមុខទៀត ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងនៅតែបន្តបង្កើនសេវាធនាគារអេឡិចត្រូនិក ដើម្បីផ្តល់សេវាកម្មធនាគារដ៏ល្អប្រសើរ និងភាយងាយស្រួលដល់អតិថិជន និងត្រៀមខ្លួនរួចរាល់ក្នុងការបម្រើអតិថិជន ចាប់ពីឆ្នាំ២០១៨ នេះតទៅ ជាមួយនឹងយុទ្ធសាស្ត្រធនាគារឌីជីថល ដោយរួមបញ្ចូលទាំងសេវាធនាគារអេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិជ្ជាហិរញ្ញវត្ថុ (FinTech) ។

បរិយាកាសធុរកិច្ចនៅប្រទេសកម្ពុជា បានផ្តល់ការគាំទ្រយ៉ាងរឹងមាំដល់សហគមន៍អាជីវកម្ម រួមទាំងធនាគារ អេស៊ីលីដា ភីអិលស៊ី ផងដែរ ។ ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចសម្រេចជោគជ័យបានតាមផែនការអាជីវកម្មរបស់ខ្លួន ខណៈដែលស្ថាប័នផ្តល់ចំណាត់ថ្នាក់ធនាគារអន្តរជាតិ (Standard & Poor's) បានបង្កើនចំណាត់ថ្នាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ពី "B" ទៅ "B+" ជាមួយនឹងទស្សនវិស័យ "ស្ថិរភាព" ។ ចំណាត់ថ្នាក់នេះបញ្ជាក់ពីភាពជោគជ័យតាមរយៈការពង្រឹងអភិបាលកិច្ច ដើមទុន កេរ្តិ៍ឈ្មោះប្រតិបត្តិការ និងលទ្ធភាពផ្តល់ស្ថិរភាពដល់ដំណើរការអាជីវកម្មរបស់ធនាគារ ។

## សមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានអភិបាលសរុបចំនួន ១០នាក់ ដែលក្នុងនោះមាន ៣នាក់ ជាអភិបាលឯករាជ្យមិនប្រតិបត្តិ ៥នាក់ ជាអភិបាលមិនប្រតិបត្តិ និង ២នាក់ទៀតជាអភិបាលប្រតិបត្តិ ។

## អភិបាលកិច្ច

ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង មានភារកិច្ចទទួលខុសត្រូវធានាឱ្យបាននូវរាល់ប្រតិបត្តិការរបស់ធនាគារទាំងអស់ គឺអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលត្រូវបានយកចិត្តទុកដាក់សម្រាប់ប្រតិបត្តិការរបស់ធនាគារនាពេលខាងមុខ ។

ដោយយោងលើតួនាទី និងភារកិច្ច ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំ៤ដងយ៉ាងទៀងទាត់ក្នុងមួយឆ្នាំ ។ ក្នុងកិច្ចប្រជុំ គឺពិនិត្យមើលការអនុវត្តរបស់ថ្នាក់គ្រប់គ្រងប្រតិបត្តិ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើប្រតិបត្តិការរបស់ធនាគារ ។ ក្រុមប្រឹក្សាភិបាល ត្រូវបានគាំទ្រដោយគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវការងារអភិបាលកិច្ចផ្សេងៗគ្នា ។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មាន ៖ គណៈកម្មាធិការសនវកម្ម និងសម្របសម្រួលកិច្ចការច្បាប់, គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការឥណទាន, គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ, និង គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន ។

## ទស្សនវិស័យ ឆ្នាំ២០១៩

យោងតាមការព្យាករណ៍របស់ធនាគារពិភពលោក ស្តីពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺនៅរក្សាកំណើនស្ថិរភាពប្រហែល ៧% ក្នុងឆ្នាំ២០១៩ ។ ធនាគារពិភពលោក បានបន្ថែមទៀតថា ប្រទេសកម្ពុជាបានចាប់ផ្តើមឡើងលើខ្សែសង្វាក់ផលិតកម្ម លើវិស័យកាត់ដេរ អេឡិចត្រូនិក និងគ្រឿងបន្លាស់រថយន្ត ។ ដើម្បីទ្រទ្រង់និន្នាការទាំងនេះ កម្ពុជាត្រូវតែចាប់ផ្តើមកំណែទម្រង់រចនាសម្ព័ន្ធកាន់តែស៊ីជម្រៅ ក្នុងការលើកកម្ពស់បរិយាកាសធុរកិច្ចពិពិធកម្មនាំចេញ កាត់បន្ថយថ្លៃដើមនៃការដឹកជញ្ជូនដោយកាត់បន្ថយគម្លាតជំនាញ ។

## ការទទួលស្គាល់

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណ ដល់អតិថិជន ភាគទុនិក អភិបាល ថ្នាក់គ្រប់គ្រងប្រតិបត្តិ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ដែលបានគាំទ្រ និងខិតខំប្រឹងប្រែងអនុវត្តតាមយុទ្ធសាស្ត្ររបស់ធនាគារ ធ្វើឱ្យធនាគារសម្រេចបានជោគជ័យតាមគោលដៅ និងបំណងរបស់ខ្លួន ។

យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណដល់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា និយ័តករ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលតែងតែជួយគាំទ្រ និងប្រឹងប្រែងអភិវឌ្ឍឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ជាពិសេសវិស័យធនាគារតែម្តង ។

យើងខ្ញុំសូមធានាចំពោះអតិថិជន ព្រមទាំងភាគទុនិកទាំងអស់ថា នៅឆ្នាំ២០១៩ នេះ យើងខ្ញុំនឹងបន្តយកចិត្តទុកដាក់ទៅលើតំបន់ដែលផ្តល់ឱកាសល្អដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបន្តខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការសម្រេចឱ្យបាននូវភាពជោគជ័យ រីកចម្រើន និងមាននិរន្តរភាព ព្រមទាំងផ្តល់នូវគោលដៅយុទ្ធសាស្ត្រ ក្នុងការបង្កើនប្រាក់ចំណេញនាពេលអនាគត ក៏ដូចជាពង្រឹងជំហររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងតំបន់ ។



លោក ឆាយ សឿន

*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩

# របាយការណ៍ប្រធាននាយកប្រតិបត្តិ



## បណ្ឌិត អ៊ុន ចាន់នី

### ប្រធាននាយកប្រតិបត្តិ

យើងខ្ញុំមិនត្រឹមតែបង្កើនគុណភាពបម្រើសេវាហិរញ្ញវត្ថុតាមប្រព័ន្ធឌីជីថល ឱ្យបានល្អបំផុត និងទៅដល់អតិថិជនគ្រប់មជ្ឈដ្ឋានទូទាំងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតជាចម្បងលើការកាត់បន្ថយហានិភ័យផងដែរ ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានសង្កេតឃើញថា កម្រិតប្រាក់ចំណូលប្រចាំគ្រួសារបន្តកើនឡើង ដោយសារតែទទួលអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចកម្ពុជា និងបានជំរុញឱ្យមានតម្រូវការខ្លាំងសម្រាប់សេវាគ្រប់គ្រងសាច់ប្រាក់ ទាំងវិស័យសាធារណៈ និងឯកជន រួមទាំងគណនីឯកត្តជនផងដែរ ។ ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម ដែលមានស្ថិរភាព និងយូរអង្វែងរបស់អតិថិជនដ៏ឆ្លាតវៃទាំងអស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានផ្តោតការយកចិត្តទុកដាក់លើការបម្រើសេវាកម្មស្នូលរបស់ខ្លួន តាមរយៈការអភិវឌ្ឍផលិតផល FinTech ឱ្យមានភាពងាយស្រួល និងលើកកម្ពស់សេវាធនាគារឌីជីថល (ស្វ័យសេវា) ដែលជាសេវាសំខាន់មួយរបស់ធនាគារ ។ ទាំងនេះបានធ្វើឱ្យអតិថិជនដ៏ឆ្លាតវៃរបស់ធនាគារទាំងអស់ទទួលបាននូវជម្រើសដ៏ល្អប្រសើរ ទាំងសុវត្ថិភាព និងភាពងាយស្រួល ព្រមទាំងកាត់បន្ថយហានិភ័យផ្សេងៗ និងបង្កើនប្រាក់ចំណូលពីការវិនិយោគរបស់ពួកគាត់ ។

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨

## ស្ថានភាពប្រកួតប្រជែង

កម្ពុជាជាប្រទេសតូចមួយ ក្នុងចំណោមប្រទេសតូចៗជាច្រើនដទៃទៀតនៅក្នុងពិភពលោក ប៉ុន្តែកម្ពុជាខុសពីប្រទេសដទៃព្រោះវាបានទាក់ទាញវិនិយោគិនជាច្រើននៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ។ វិនិយោគិនទាំងនោះ បានវិនិយោគនៅក្នុងធនាគារពាណិជ្ជ ធនាគារឯកទេស និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលធ្វើឱ្យមានការប្រកួតប្រជែងខ្លាំងទាំងតម្លៃ និងគុណភាពសេវាកម្ម ។ លើសពីនេះ ដោយមានបច្ចេកវិជ្ជាធនាគារថ្មី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចវិនិយោគលើ FinTech ដែលអាចបង្កើនការប្រកួតប្រជែងពីគុណភាពសេវាកម្ម ។ ដោយសារតែការប្រកួតប្រជែង និងភាពឆ្អែតប្រឌិតនេះ ធ្វើឱ្យអតិថិជនទទួលបានផលប្រយោជន៍កាន់តែច្រើន ព្រមទាំងធ្វើឱ្យពួកគាត់ រីកចម្រើនជាមួយគ្នា ទាំងធនាគារ អេស៊ីលីដា ភីអិលស៊ី និងអតិថិជនរបស់ខ្លួន ។

## ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០១៨

- សមតុល្យឥណទានសរុបក្នុងឆ្នាំ២០១៨ មានចំនួន ៣.៦២៧,៥៦លានដុល្លារអាមេរិក ក្នុងនោះមានចំនួន ៦៤៦,៦៦លានដុល្លារអាមេរិក ស្មើនឹង ១៧,៨៣% បានផ្តល់លើវិស័យកសិកម្ម ក្នុងចំណោមវិស័យ ផ្សេងៗជាច្រើនទៀត ។ បើប្រៀបធៀបកាលពីឆ្នាំ២០១៧ ការផ្តល់ឥណទានលើវិស័យកសិកម្មមានចំនួន ៥៨០,៨០លានដុល្លារអាមេរិក ។ គិតត្រឹមដំណាច់ឆ្នាំ២០១៨ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានអតិថិជនឥណទានអាជីវកម្មខ្នាតតូចចំនួន ៤០៦.៦៦៦នាក់ ។
- ឥណទានមិនដំណើរការ មានចំនួន ១,៧៣% ។
- ប្រាក់បញ្ញើ-សន្សំ មានចំនួន ៣.៨៣៥,៨៣ លានដុល្លារអាមេរិក ក្នុងនោះមានគណនីចំនួន ២.៣៤៧,២៧លាន ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានប្រាក់ចំណេញប្រចាំឆ្នាំ២០១៨ ចំនួន ៨៤លានដុល្លារអាមេរិក ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅតែបន្តកាត់បន្ថយចំណាយ និងត្រួតពិនិត្យហានិភ័យ ដើម្បីទទួលបានចំណូលខ្ពស់បំផុត ។
- សេវាធនាគារអេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិជ្ជាហិរញ្ញវត្ថុ (FinTech) បានបញ្ចូលជាមួយនឹងហេដ្ឋា-រចនាសម្ព័ន្ធសេវាធនាគារអេឡិចត្រូនិករបស់ធនាគារ ផ្តល់ជូនអតិថិជននូវជម្រើសជាច្រើន ដើម្បីគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគាត់យ៉ាងមានប្រសិទ្ធភាព ពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមតម្រូវការ ដើម្បីធ្វើប្រតិបត្តិការសេវាធនាគារយ៉ាងមានសុវត្ថិភាពខ្ពស់ ។

## សេវាលក់រាយ និងអាជីវកម្មខ្នាតតូច

ឥណទានខ្នាតតូចបានកើតឡើង ៣០,៩៨% និងឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន កើនឡើង ២៦,៨៣% ។ ឥណទានគេហដ្ឋាន មានចំនួន ៥,៦៤% នៃទំហំឥណទានសរុប ។

ប្រាក់បញ្ញើ-សន្សំបានកើនឡើង ១៥,២០% ដែលមានចំនួន ៣.៨៣៥,៨៣ លានដុល្លារអាមេរិក ។ វិស័យលក់រាយជាផ្នែកដែលធំជាងគេបំផុតនៃកំណើនប្រាក់បញ្ញើសរុប ដែលភាគច្រើនបានមកពីអតិថិជនដាក់ប្រាក់បញ្ញើដំបូង ដូចជាកម្មករនិយោជិតតាមរយៈ សេវាបើកប្រាក់បៀវត្ស និងអតិថិជននៅតាមជនបទដែលពួកគាត់បានប្រើប្រាស់ សេវាអេស៊ីលីដាយូនីធីទាន់ចិត្ត ។ ការពង្រីកសេវាធនាគារតាមរយៈ FinTech បានចូលរួមធ្វើឱ្យមានកំណើននេះខ្លាំងផងដែរ ។ គួរកត់សម្គាល់ផងដែរថា ប្រាក់បញ្ញើទាំងនោះអាចគ្របដណ្តប់លើសមតុល្យឥណទាន ដែលមានចំនួន ៣.៦២៧,៥៦ លានដុល្លារអាមេរិក ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធសាខាទាំង ២៦២ទីតាំង អេធីអឹម ៥២៧គ្រឿង និងម៉ាស៊ីនឆូតកាត ៤.២២២គ្រឿង ថែមទាំងធ្វើឱ្យសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត ឱ្យកាន់តែទំនើប និងមានប្រជាប្រិយដែលមានអតិថិជនកំពុងប្រើប្រាស់ជិតមួយលាននាក់ ។ សមតុល្យប្រាក់បញ្ញើ-សន្សំ មានចំនួន ៣.៧៥៣,៤០ លានដុល្លារអាមេរិក ជាមួយនឹងគណនីសរុបជាងពីរលានគណនី ហើយបានចេញប័ណ្ណឥណពន្ធចំនួន ១,១២លានប័ណ្ណ ។



ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ធនាគារ ADB នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩

## ឥណទានខ្នាតមធ្យម និងសាជីវកម្ម

ក្នុងឆ្នាំ២០១៨ ឥណទាននៅក្នុងវិស័យនេះកើនឡើង ១,០៩% ដែលមានចំនួនស្មើនឹង ៣២,៦៤% នៃឥណទានសរុប ។ សេវាគ្រប់គ្រងសាច់ប្រាក់បានកើនឡើងយ៉ាងខ្លាំង តាមរយៈការចាប់ដៃគូជាមួយនឹងវិស័យសាធារណៈ ជាពិសេសបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សេវាបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរដ្ឋាភិបាល និងសេវាប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ រួមទាំងអតិថិជនមុខជំនួញជាច្រើន ជាពិសេសរោងចក្រកាត់ដេរ ។ ក្នុងនាមជាអ្នកគ្រប់គ្រងមូលនិធិរបស់បេឡាជាតិសន្តិសុខសង្គម ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចទទួលបានប្រាក់វិភាគទាន ទូទាំងរាជធានី-ខេត្ត ។ លើសពីនេះទៀតអតិថិជនថ្មីៗជាច្រើនត្រូវបានតម្រូវឱ្យបើកគណនី ដោយសារការបន្ថែមម៉ាស៊ីនអេធីអឹម និងការទូទាត់វិក្កយបត្ររបស់ក្រុមហ៊ុនផ្សេងៗ តាមរយៈសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត ព្រមទាំងសេវាអេស៊ីលីដាអ៊ីនធើណែតផងដែរ ។ ទាំងនេះធ្វើឱ្យមានលទ្ធផលវិជ្ជមាន ទៅលើលំហូរសាច់ប្រាក់ជារូបិយប័ណ្ណក្នុងស្រុករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងអាចឱ្យយើងផ្តល់ឥណទានជាប្រាក់រៀលពីប្រាក់បញ្ញើបានផងដែរ ។ តម្រូវការប្រើប្រាស់សេវាបើកប្រាក់បៀវត្ស កើនឡើងខ្លាំង នៅក្នុងឆ្នាំ២០១៨ ដោយមានស្ថាប័នរដ្ឋាភិបាល និងមន្ត្រីរាជការ ព្រមទាំងក្រុមហ៊ុនក្រៅប្រទេស និងក្នុងប្រទេសធំៗ និងស្ថាប័ននានាបានចូលរួមប្រើប្រាស់ ដែលជាឱកាសដ៏ល្អ សម្រាប់ការលក់ផលិតផលផ្សេងៗទៀត ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន នៅតែបន្តសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្ររយៈពេលវែង ជាមួយធនាគារជប៉ុន SMBC, ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍, និង ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតៃ ។ ដោយរួមបញ្ចូលគ្នានូវបទពិសោធន៍រាប់រយឆ្នាំក្នុងសេវាធនាគារ និងហិរញ្ញវត្ថុ ដៃគូទាំងអស់ជួយដល់អតិថិជនគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានប្រាក់ចំណូលបង្កើនប្រភពមូលនិធិយូរអង្វែងសម្រាប់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ភាពជាដៃគូទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការផ្តល់មូលនិធិរយៈពេលវែងដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងជាប្រភពដ៏មានប្រយោជន៍នៃប្រាក់ចំណូលក្រៅតារាងតុល្យការ ។

## រតនាភិបាល និងអន្តរជាតិ

ចំណូលពីសេវាប្តូរប្រាក់បន្តកើនឡើង និងចូលរួមបង្កើនចំណូលមិនមែនការប្រាក់ ។ ដោយយោងលើគោលនយោបាយគ្រប់គ្រងហានិភ័យ ធនាគារ អេស៊ីលីដា ភីអិលស៊ី បម្រើសេវាប្តូរប្រាក់ សម្រាប់តែគាំទ្រដល់អាជីវកម្ម របស់អតិថិជនប៉ុណ្ណោះ ។ សេវានេះ ជាប្រភពចំណូលមានហានិភ័យទាប និងមានស្ថិរភាព ហើយមានកំណើនជាលំដាប់ បង្កើតប្រាក់ចំណូលល្អប្រសើរ និងរក្សាទំនាក់ទំនងយូរអង្វែងជាមួយអតិថិជន ។

តារាងតុល្យការរបស់ធនាគារកាន់តែរឹងមាំថែមទៀត តាមរយៈកំណើនអតិថិជនបញ្ញើ-សន្សំយ៉ាងខ្លាំង ធ្វើឱ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើមានភាពល្អប្រសើរ និងជួយទ្រទ្រង់ដល់ការរីកចម្រើននៅលើទីផ្សារ ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចូលរួមចំណែកផ្សព្វផ្សាយការប្រើប្រាស់ប្រាក់រៀល ដោយចូលរួមនៅក្នុង Liquidity Providing Collateralized Operation (LPCO) និងគាំទ្រតម្រូវការសាច់ប្រាក់របស់ LPCO ជាប្រភេទប្រាក់ក្នុងស្រុក ។

បន្ថែមពីនេះទៀត ដើម្បីគាំទ្រដល់ប្រភពមូលនិធិរយៈពេលវែង ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចាត់ចែងជម្រើសមូលនិធិដោយរក្សាទំនាក់ទំនងល្អជាមួយនឹងដៃគូយុទ្ធសាស្ត្រទូទាំងសកលលោក ។

យើងនៅតែបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងបានបន្ថែមធនាគារដៃគូក្រៅប្រទេសថ្មីៗជាច្រើនថែមទៀត ដើម្បីបង្កើនបណ្តាញប្រតិបត្តិការរបស់យើងខ្ញុំ ។ នាដំណាច់ឆ្នាំ២០១៨ យើងខ្ញុំមានធនាគារដៃគូចំនួន ៣១៥ នៅក្នុង ៤៥ប្រទេស ។ បន្ថែមពីនេះទៀត យើងមានចំណែកទីផ្សារលើសលុបសម្រាប់គណនីរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងផ្តល់សេវាផ្ទេរប្រាក់ដល់អតិថិជនទូទាំងប្រទេស ។



ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ធនាគារ ADB នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩



គណៈប្រតិភូជាន់ខ្ពស់ធនាគារ ADB ទស្សនកិច្ចអតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងរាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៨

១. បន្តអភិវឌ្ឍនូវធនាគារឌីជីថល ដោយបង្កើតឱ្យមានសេវាស្វ័យប្រតិបត្តិការ ។

២. បង្កើនសមត្ថភាពធនធានមនុស្ស ដោយលើកកម្ពស់ពហុជំនាញ និងវប្បធម៌បម្រើសេវាធនាគារឌីជីថល ។

៣. អភិវឌ្ឍការិយាល័យសាខា ឱ្យក្លាយជាធនាគារឌីជីថល ។

៤. បង្កើតឯកសារឌីជីថល និងឯកសារផ្សេងៗបញ្ចូលគ្នាជាទម្រង់ឌីជីថលសម្រាប់ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ ។

៥. លើកកម្ពស់បច្ចេកវិជ្ជាព័ត៌មាន និងប្រព័ន្ធសុវត្ថិភាពសម្រាប់ធនាគារឌីជីថលដើម្បីបម្រើនិងការពារអតិថិជន និងធនាគារផងដែរ ។

៦. បន្តលើកកម្ពស់ការអភិវឌ្ឍ FinTech ដើម្បីផ្តល់ភាពកាន់តែងាយស្រួលប្រើប្រាស់ដល់អតិថិជន ក្នុងការផ្លាស់ប្តូរទៅការប្រើប្រាស់សេវាធនាគារតាមបែបឌីជីថល (ស្វ័យសេវា) ។

៧. ចាប់ដៃគូជាមួយស្ថាប័ននានា ដើម្បីភាពរីកចម្រើនរបស់ធនាគារ ។

៨. ធ្វើជាអ្នកថែរក្សា ចេញផ្សាយមូលបត្របំណុល និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ។

៩. ធ្វើឱ្យសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត អាចទូទាត់កាន់តែទូលំទូលាយ តាមរយៈប្រព័ន្ធ API ដើម្បីបម្រើផលប្រយោជន៍ជូនដល់អតិថិជន ទូទាំងប្រទេស និងនៅក្នុងតំបន់ ។

១០. បញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ឱ្យក្លាយជាធនាគារឌីជីថល និងបម្រើសេវាឌីជីថលផងដែរ ។

## បញ្ហាចម្បងក្នុងឆ្នាំ២០១៩

បទប្បញ្ញត្តិស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន សំវិធានធនលើការអន់ថយ និងការកំណត់ទ្រនាប់ដើមទុននៃគ្រឹះស្ថានហិរញ្ញវត្ថុ ដែលនាំមកនូវឱកាស និងបញ្ហាប្រឈមនានារបស់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ។ ស្ថាប័នហិរញ្ញវត្ថុទាំងអស់បន្តប៉ះពាល់ដល់ចំណូលខ្លះៗ ប៉ុន្តែបានជួយកាត់បន្ថយហានិភ័យ សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ និងបង្កើនគុណភាពឥណទាន ។ បញ្ញត្តិទាំងនោះអាចជួយពង្រឹងមូលដ្ឋានដើមទុន ដើម្បីដោះស្រាយការខាតបង់នានា ដែលអាចកើតឡើងដល់ស្ថាប័ននានា ។ ទប់ស្កាត់ការកាត់បន្ថយដើមទុនដល់កម្រិតទាបជាងតម្រូវការបម្រុងកាតព្វកិច្ចអប្បបរមា និងកាត់បន្ថយហានិភ័យពីទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុក៏ដូចជាជួយបង្កើតបរិស្ថានវិន័យឥណទាន ខណៈពេលដែលការត្រួសត្រាយផ្លូវសម្រាប់កំណើនដ៏មានស្ថិរភាពនៅក្នុងអាជីវកម្មធនាគារទូទៅ ។

ក្នុងឆ្នាំ២០១៨ នេះ ខ្ញុំសូមណែនាំនូវសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត ។ សេវានេះមិនត្រឹមតែបម្រើអតិថិជនទាំងក្រុមហ៊ុន និងឯកត្តជនបាន ២៤ម៉ោងប៉ុណ្ណោះទេ ថែមទាំងពង្រីកទំនាក់ទំនងអាជីវកម្មយ៉ាងទូលំទូលាយតាមរយៈ ប្រព័ន្ធ API ភ្ជាប់ទៅកាន់ក្រុមហ៊ុនទូទាត់នានា ដែលទទួលបានការអនុម័តពីធនាគារជាតិ នៃកម្ពុជា ។ ជាមួយសេវាអេស៊ីលីដាយូនីធីទាន់ចិត្ត លោកអ្នកអាចគ្រប់គ្រងជំនួញរបស់លោកអ្នកប្រកបដោយប្រសិទ្ធភាព និងអាចធ្វើប្រតិបត្តិការសេវាធនាគារអេស៊ីលីដា បានគ្រប់ពេលវេលា គ្រប់ទីកន្លែង ដោយសុវត្ថិភាពខ្ពស់ ។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនដ៏វៃឆ្លាត ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ក្រុមប្រឹក្សាយោបល់ព្រមទាំងរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា ដែលបានគាំទ្រដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងឆ្នាំ២០១៨ កន្លងមក ។ សូមជូនពរដល់លោកអ្នក និងក្រុមគ្រួសារ ក្នុងឆ្នាំ២០១៩ ទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ ជោគជ័យក្នុងនាទីការងារនិងមុខជំនួញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តមកុំបីឃ្លៀងឃ្លាតឡើយ ។



**បណ្ឌិត អ៊ិន ចាន់នី**

*ប្រធាននាយកប្រតិបត្តិ*

ថ្ងៃទ២៨ ខែកុម្ភៈ ឆ្នាំ២០១៩





កិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ស្តីពី "អភិបាលកិច្ចសាជីវកម្ម - មធ្យោបាយក្នុងការកម្លាយខ្លួនរបស់អាជីវកម្ម"

# អង្គការលេខ




*បានតែងតាំងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩

# បណ្ដាញប្រតិបត្តិការ

ធនាគារអេស៊ីលីដា មានសាខា
ចំនួន ២៦២ គ្របដណ្ដប់គ្រប់ខេត្ត និងរាជធានី នៅព្រះរាជាណាចក្រកម្ពុជា
និងចំនួន ៣៩ សាខា នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រមទាំង
៩ សាខា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។



# អភិបាលកិច្ចសាជីវកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលស្គាល់នូវលក្ខណៈដ៏សំខាន់ នៃអភិបាលកិច្ចសាជីវកម្ម ដើម្បីគាំទ្រពីស្ថិរភាព នៃការរីកចម្រើនរបស់ធនាគារបង្កើនប្រសិទ្ធភាព ការងារ និងប្រាក់ចំណេញ បង្កើនតម្លៃរបស់ភាគទុនិក និងជំនឿទុកចិត្តដល់ភាគទុនិក អតិថិជន បុគ្គលិក ព្រមទាំងសាធារណជនទូទៅ ។ ក្រុមប្រឹក្សាភិបាលគាំទ្រ និងលើកទឹកចិត្តឱ្យអនុវត្តគោលនយោបាយអភិបាលកិច្ចសាជីវកម្ម រួមទាំងក្រមសីលធម៌ ។

## កិច្ចប្រជុំភាគទុនិក

ធនាគារ អេស៊ីលីដា ភីអិលស៊ី បើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគទុនិក ដោយអនុលោមទៅតាមច្បាប់ លក្ខន្តិកៈ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធ ។ ក្នុងឆ្នាំ២០១៨ កិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគទុនិកបានប្រព្រឹត្តិទៅនៅការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ និងបានប្រជុំសម្រេចតាមអ៊ីម៉ែល ចំនួន១០ដងបន្ថែមទៀតនៅក្នុងឆ្នាំនោះ ។ ធនាគារបានប្រតិបត្តិដូចខាងក្រោម ៖

### មុនបើកកិច្ចប្រជុំ

ធនាគារបានរៀបចំឯកសារមួយចំនួន ជាភាសាអង់គ្លេស និងបានផ្ញើជូនភាគទុនិកទាំងអស់ មុនពេលបើកកិច្ចប្រជុំ ។ ឯកសារទាំងនោះមានដូចជាៈ កំណត់សម្គាល់ក្នុងកិច្ចប្រជុំ របៀបវារៈលម្អិត តួលេខសំខាន់ៗ សេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល ឯកសារគាំទ្រ របាយការណ៍ប្រចាំឆ្នាំ២០១៧ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សវនករខាងក្រៅ ។

### អំឡុងពេលប្រជុំ

កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ២០១៨ បានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ។ ភាគទុនិកទាំងអស់មានឱកាសគ្រប់គ្រាន់ ដើម្បីសាកសួរ និងផ្តល់អនុសាសន៍ ព្រមទាំងអាចស្នើសុំពន្យល់ ឬបញ្ជាក់បញ្ហាផ្សេងៗពីប្រធានក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង ។ កំណត់ហេតុប្រជុំ និងមតិអនុម័ត ត្រូវបានកត់ត្រាដោយលេខាធិការក្រុមហ៊ុន របស់ធនាគារ ។

ចំណុចចម្បងៗដែលបានអនុម័ត ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០១៨ មាន ៖

- អនុម័តបង្កើនដើមទុនរបស់ អេស៊ីលីដា ប្រូភើធី អិលធីឌី ចំនួន ១៥.០០០ ដុល្លារអាមេរិក ។
- អនុម័តបង្កើត "អង្គការមូលនិធិ អេស៊ីលីដា-ចារឌីន សម្រាប់ការអប់រំ" និងអនុញ្ញាតឱ្យប្រើការិយាល័យកណ្តាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាការិយាល័យរបស់ខ្លួន ព្រមទាំងបានចុះឈ្មោះនៅក្រសួងមហាផ្ទៃ ។
- អនុម័តបង្កើនដើមទុនរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា ចំនួន ២លាន ដុល្លារអាមេរិក និងផ្តល់ប្រាក់កម្ចីអាទិភាព ចំនួន ៤លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ និងចំនួន ១លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ។
- អនុម័តតែងតាំង លោក លី ថៃ ជាតំណាងភាគទុនិកថ្មីរបស់ក្រុមហ៊ុន អេ អេស អេ នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក ស្វាយ ហៃ ។
- អនុម័តគោលការណ៍ណែនាំទូទាំងផ្សេងៗ ។
- អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ព្រមទាំងលិខិតថ្នាក់គ្រប់គ្រង សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មដោយក្រុមហ៊ុន PwC ។
- អនុម័តការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៧ នៃប្រាក់ចំណេញក្រោយដកពន្ធ និងផ្ទេរប្រាក់ចំណេញក្រោយដកពន្ធដែលនៅសល់ទៅជាទុនបម្រុងរបស់ធនាគារ ។
- អនុម័តបង្កើនដើមទុន ពីការបែងចែកភាគលាភ ។
- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តគោលនយោបាយភាគលាភ ។
- អនុម័តលើលិខិតចូលរួមសវនកម្ម ជាមួយក្រុមហ៊ុន KPMG និងថ្លៃសេវាសម្រាប់សវនកម្ម ។
- អនុម័តបង្កើនដើមទុនចុះបញ្ជីរបស់ ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ចំនួន ៨លាន ដុល្លារអាមេរិក ។
- អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដោយអនុឡោមតាមរបាយការណ៍ហិរញ្ញវត្ថុស្តង់ដារអន្តរជាតិ របស់ប្រទេសកម្ពុជា (CIFRS) ដែលបានរៀបចំដោយ PwC ។
- អនុម័ត និងទទួលស្គាល់លោក Yuichi Nishimura ជាតំណាងភាគទុនិករបស់ SMBC នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ។

### បន្ទាប់ពីប្រជុំ

កំណត់ហេតុកិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ២០១៨ ត្រូវបានផ្ញើជូនគ្រប់ភាគទុនិកទាំងអស់ ដើម្បីជ្រាបជាព័ត៌មាន និងសម្រាប់កិច្ចប្រជុំបន្ទាប់ ។

## ភាគទុនិក

ភាគទុនិក គឺជាម្ចាស់របស់ធនាគារ ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្រ្តនានា ប៉ុន្តែភាគទុនិកពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីយ៉ាងណាក៏ដោយ ភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះទៅឱ្យក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារ ។

### អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ជាអ្នកបន្តវេនពី អង្គការ អេស៊ីលីដា ដោយអនុលោមតាមអនុក្រឹត្យលេខ : ៤៧៦ អនក្រ-បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងប្រកាសលេខៈ ១០៤១ សហវ-ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ បានទទួលវិញ្ញាបនបត្រ ចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ លេខៈ ២៦៩ សហវ.អឧហ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យចុះបញ្ជីនៅ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ មានគោលបំណង និងតួនាទីដូចខាងក្រោម ៖

- បង្កើតនូវកាលានុវត្តភាពការងារ និងផ្តល់ប្រភពចំណូល ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ។
- ជួយលើកស្ទួយ និងជួយគ្រាំទ្រដល់ការរីកចម្រើន នៃវិទ្យាសាស្រ្តពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច រួមមាន វិស័យធនាគារ និងហិរញ្ញវត្ថុ និងផ្តោតសំខាន់ ទៅលើចំណេះដឹងផ្នែកហិរញ្ញវត្ថុ ។
- លើកស្ទួយកាលានុវត្តភាពសេដ្ឋកិច្ច និងអប់រំដល់យុវជន និងប្រជាពលរដ្ឋដែលមានចំណូលទាប ។
- ចូលរួមចំណែកការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មហិរញ្ញវត្ថុ តាមរយៈធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ។

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ជាភាគទុនិកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានបង្កើតឡើង អនុលោមតាមច្បាប់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានគោលដៅលើកទឹកចិត្តដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ឱ្យប្រកាន់ខ្ជាប់នូវគោលបំណង ដើម្បីគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម និងរក្សានូវសញ្ជាតិជាក្រុមហ៊ុនខ្មែរ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ត្រូវបន្តអនុវត្តដោយផ្ទាល់ និងដាច់ដោយឡែកនូវគោលបំណងមិនរកប្រាក់ចំណេញ ដូចបានរៀបរាប់ខាងលើ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ធ្វើសកម្មភាពជាប្រយោជន៍ដល់ជនទូទៅ និងមិនអនុវត្តគោលបំណងចម្បង ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មឯកជនផ្ទាល់ខ្លួនឡើយ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ មិនមែនជាស្ថាប័ននយោបាយ និងមិនចំណុះឱ្យគណៈបក្សនយោបាយណាមួយឡើយ ។ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ អាចប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុ ដូចបានកំណត់ក្នុងអនុស្សរណៈ និងលក្ខន្តិកៈ នេះតែប៉ុណ្ណោះ ។ គ្មានបុគ្គលណាមួយទទួលបានអត្ថប្រយោជន៍ពីការផ្តល់តម្លៃការខ្ពស់ដោយវិសមាមាត្រ ឬទទួលបានពីការចំណាយ ដែលផ្ទុយទៅនឹងគោលបំណងនៃ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ឡើយ ។

## ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី (ASA, Plc.)

អេ អេស អេ ភីអិលស៊ី (ASA, Plc.) បានបង្កើតឡើងក្នុងលក្ខណៈជាក្រុមហ៊ុនកាន់កាប់ភាគហ៊ុនមួយ និងជាយន្តការមួយដែលបុគ្គលិកអាចចូលរួមនៅក្នុងការរីកចម្រើនរយៈពេលវែង និងការបង្កើនតម្លៃភាគហ៊ុននៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការធ្វើជាម្ចាស់ផលប្រយោជន៍នៅក្នុងភាគហ៊ុនរបស់ធនាគារ និងដើម្បីចូលរួមក្នុងសកម្មភាពផ្សេងទៀតដែលមានសារៈសំខាន់ និងមានហេតុផលសមរម្យ ការវិនិច្ឆ័យ នៃក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ និងការសម្រេចគោលបំណងខាងមុខនេះ ។

## COFIBRED – Compagnie Financière de la BRED (BRED's financial company)

COFIBRED គឺជាបុត្រសម្ព័ន្ធពេញលេញរបស់ BRED BanquePopulaire ។ ដោយសារសកម្មភាព BRED អភិវឌ្ឍន៍ខ្លាំងលើឆាកអន្តរជាតិ នៅឆ្នាំ២០០៨ ក៏សម្រេចឱ្យមានការរៀបចំបុត្រសម្ព័ន្ធ និងផ្នែកដែលពាក់ព័ន្ធទាំងអស់ស្ថិតនៅក្នុងស្ថាប័នតែមួយ ដោយមានឈ្មោះថា Cofibred ។ ភាគហ៊ុនរបស់ Cofibred បានមកពីបុត្រសម្ព័ន្ធ និងស្ថាប័នដែលពាក់ព័ន្ធចំនួនជាង ៤៥ ដែលមានទឹកប្រាក់សរុបប្រហែល ១ពាន់លានអឺរ៉ូ ក្នុងវិស័យធនាគារ, ធានារ៉ាប់រង, អ៊ីខុមមើស និង/ឬ ក្រុមហ៊ុនហិរញ្ញវត្ថុ ។ បុត្រសម្ព័ន្ធ និងស្ថាប័នដែលពាក់ព័ន្ធទាំងនេះស្ថិតនៅក្នុងទ្វីបចំនួន៥ ទូទាំងពិភពលោក ។

## Sumitomo Mitsui Banking Corporation (SMBC)

SMBC គឺជាធនាគារជប៉ុនធំមួយដែលប្រតិបត្តិការទូទាំងពិភពលោក និងមានទ្រព្យសកម្មចំនួន ១៧៧.៨៥៩ ពាន់លានយេន អនុបាតដើមទុនថ្នាក់ទី១ គឺ ១៤,៩% ព្រមទាំងទទួលបានចំណាត់ថ្នាក់ A (ពី S&P's) និង A1 (ពី Moody's) ។ តាមរយៈសាខាក្នុងស្រុកចំនួន ៤៤២ (មិនរាប់បញ្ចូលអនុសាខា និងភ្នាក់ងារធនាគារ) ក្នុងប្រទេសជប៉ុន និងមានសាខាក្រៅប្រទេស ចំនួន ៨៤ (រាប់បញ្ចូលទាំងបុត្រសម្ព័ន្ធ អនុសាខា និងការិយាល័យតំណាង) នៅទូទាំងពិភពលោក ។ SMBC ផ្តល់សេវាកម្មយ៉ាងសម្បូរបែប មានដូចជា ប្រាក់បញ្ញើ, សាជីវកម្មហិរញ្ញវត្ថុ, ការវិនិយោគមូលបត្រ, ផ្ទេរប្រាក់, ប្តូរប្រាក់, សេវាអាជ្ញាប័ណ្ណបំណុលសាជីវកម្ម, សេវាកម្មប្រអប់បញ្ញើសុវត្ថិភាព, ធានាទិញមូលបត្រហិរញ្ញវត្ថុនាពេលអនាគត, និងសេវា Investment Trust Sales ។

SMBC ប្តេជ្ញាធ្វើការឆ្ពោះទៅគោលដៅរបស់ខ្លួន គឺ "ពន្លឿនយុទ្ធសាស្ត្រផ្តោតលើអាស៊ី" ។ SMBC បានវិនិយោគធនធានរបស់ខ្លួនយ៉ាងសកម្មក្នុងប្រទេសជាច្រើននៅតំបន់អាស៊ី ដែលមានសក្តានុពលរីកចម្រើនខ្លាំង ។ ដើម្បីផ្តល់ជូនអតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបាននូវសេវាកម្មហិរញ្ញវត្ថុសមាហរណកម្មបានល្អប្រសើរ SMBC បានផ្តល់អ្នកជំនាញជាន់ខ្ពស់មកបម្រើការជាទីប្រឹក្សា នៅក្នុងផ្នែកសាជីវកម្មអន្តរជាតិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីឆ្នាំ២០១៣ មក ។

ក្រុមហ៊ុនមេរបស់ SMBC គឺ Sumitomo Mitsui Financial Group, Inc. (SMFG) បានចុះបញ្ជីនៅផ្សារភាគហ៊ុនតូក្យូ, Nagoya និង New York និងមានមូលធនប្រហែល ៥,៦ពាន់លានយ៉េន គិតត្រឹមថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ ។ សម្រាប់ព័ត៌មានបន្ថែមអំពី SMBC សូមទស្សនាវេបសាយ ៖ www.smfg.co.jp/english ។

## ORIX Corporation

ក្រុមហ៊ុន ORIX (TSE: 8591; NYSE: IX) ជាក្រុមហ៊ុនកាលានុវត្ត, វិនិយោគចម្រុះ, ការបង្កើតថ្មីទូទាំងពិភពលោក ដែលបង្ហាញឱ្យឃើញ កំណត់ត្រានៃការទទួលបានប្រាក់ចំណេញ ។ ORIX បានបង្កើតឡើងនៅឆ្នាំ១៩៦៤ ហើយបច្ចុប្បន្នកំពុងធ្វើប្រតិបត្តិការអាជីវកម្មផលបត្រចម្រុះ, សេវាហិរញ្ញវត្ថុ និងការវិនិយោគផ្សេងៗ ។ សកម្មភាពអាជីវកម្មក្នុងវិស័យជាច្រើនរបស់ក្រុមហ៊ុន Orix មានដូចជា ៖ ថាមពល, មូលធនឯកជន, ហោដ្ឋារចនាសម្ព័ន្ធ, រថយន្ត, នាវា និងយន្តហោះ, អចលនទ្រព្យ និងសេវាកម្មហិរញ្ញវត្ថុលក់រាយផ្សេងៗទៀត ។ ក្រុមហ៊ុន Orix បានពង្រីកអាជីវកម្មរបស់ខ្លួននៅទូទាំងពិភពលោក ដោយបង្កើតទីតាំងជាច្រើននៅក្នុង ៤០ ប្រទេស និងតំបន់ផ្សេងៗនៅទូទាំងពិភពលោក ។ តាមរយៈសកម្មភាពអាជីវកម្មទាំងនេះ ធ្វើឱ្យក្រុមហ៊ុន Orix បាន ប្តេជ្ញាធ្វើជាក្រុមហ៊ុនសម្រាប់ប្រជាជន និងចីរភាពបរិស្ថាន ។ សម្រាប់ព័ត៌មានបន្ថែម សូមទស្សនាវេបសាយ ៖ www.orix.co.jp/grp/en/ ។

## Triodos Microfinance Fund, Triodos Fair Share Fund, និង Triodos Sustainable Finance Foundation,

Triodos Sustainable Finance Foundation (បង្កើតឡើងពី Triodos-Doen Foundation), Triodos Fair Share Fund និង Triodos Microfinance Fund គឺជាមូលនិធិវិនិយោគបី គ្រប់គ្រងដោយ Triodos Investment Management ។ Triodos Investment Management គឺជាបុត្រសម្ព័ន្ធពេញលេញ និងកាន់កាប់ភាគហ៊ុនចំនួន ១០០% ដោយធនាគារ Triodos ដែលជាធនាគារមួយ មាននិរន្តរភាពឈានមុខគេនៅលើពិភពលោក ។ មូលនិធិនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាហិរញ្ញវត្ថុជូន ប្រជាជន និងសហគ្រាសខ្នាតតូច និងមធ្យម ដែលមានចំណូលទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដើម្បីរួមចំណែកក្នុងវិស័យហិរញ្ញវត្ថុមួយប្រកបដោយនិរន្តរភាព ។

## Triodos Microfinance Fund

Triodos Microfinance Fund បានបង្កើតឡើងនៅក្នុង ឆ្នាំ២០០៩ និងជាមូលនិធិបើកដោយមានភាគហ៊ុន របស់អ្នកវិនិយោគ អ្នកមានទ្រព្យសម្បត្តិច្រើន និងអតិថិជនធនាគារឯកជននៅពាសពេញទ្វីបអឺរ៉ុប ។ សកម្មភាពចម្បងរបស់មូលនិធិនេះ ផ្តោតលើការបង្កើតស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ដែលមានឯកសារបញ្ជាក់ត្រឹមត្រូវ ។ នៅចុងឆ្នាំ២០១៨ ទ្រព្យសកម្មសរុបរបស់មូលនិធិនេះ មានចំនួន ៣៧១,៥ លានអឺរ៉ូ ។

## Triodos Fair Share Fund

Triodos Fair Share Fund បានបង្កើតឡើងនាឆ្នាំ២០០២ ក្នុងប្រទេសហូល្លង់ គឺជាមូលនិធិដំបូងគេបង្អស់ និងដ៏កម្រនៅក្នុងពិភពលោក ដែលផ្តល់ឱកាសដល់សាធារណជនទូទៅក្នុងការវិនិយោគ ក្នុងស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ នៅចុងឆ្នាំ២០១៨ ទ្រព្យសកម្មសរុបរបស់មូលនិធិនេះ មានចំនួន ៣៦០,៥ លានអឺរ៉ូ ។

## Triodos Sustainable Finance Foundation

Triodos Sustainable Finance Foundation មានគំនិតផ្តួចផ្តើមផ្តល់ហិរញ្ញវត្ថុដែលជួយពន្លឿនស្ថិរភាព នៃការអភិវឌ្ឍទូទាំងពិភពលោក ដោយផ្តោតលើសេវាហិរញ្ញវត្ថុគ្រប់ប្រភេទ ។

# ក្រុមប្រឹក្សាភិបាល



( ពីឆ្វេងទៅស្តាំ ) បណ្ឌិត Pieter Kooi, លោក Marc Robert, លោកស្រី Femke Bos, លោក រ័ត្ន យូម៉េង, លោក ឆាយ សឿន, បណ្ឌិត អ៊ិន ចាន់នី, កញ្ញា Heng Su Yin, លោក Ryoji Nishimura, លោក Cornelius Obert, លោក Ian S. Lydall

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគទុនិក សម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យពួកគេផ្ទាល់ ។ តាមលក្ខន្តិកៈ បានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមាន ១០រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ របស់ធនាគារ និងគ្រប់គ្រងរាល់ប្រតិបត្តិការអាជីវកម្ម ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវធ្វើកិច្ចការ ដើម្បីជាប្រយោជន៍ខ្ពស់បំផុត សម្រាប់ធនាគារ ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាណាម្នាក់មានអំណាចក្នុងការផ្តល់ការណែនាំ ឬបង្គាប់បញ្ជាតែឯកឯងលើថ្នាក់ដឹកនាំ ឬបុគ្គលិកណាម្នាក់របស់ធនាគារ ឬចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែមានការផ្ទេរអំណាចជាក់លាក់ឱ្យអនុវត្ត តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាម្នាក់ៗ អាចពិនិត្យដោយគ្មានកំណត់ ចំពោះឯកសារ និងកំណត់ត្រាផ្សេងៗរបស់ធនាគារ គ្រប់ពេលម៉ោងធ្វើការ ។

ក្រុមប្រឹក្សាភិបាល ធ្វើការជ្រើសតាំងនូវសមាជិកម្នាក់ ឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត ដោយយកតាមសំឡេងភាគច្រើនហើយ បុគ្គលនោះជាអ្នកដឹកនាំ នូវរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាមហាសន្និបាតប្រចាំឆ្នាំ ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ ។ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្ស ដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើតយុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រងដើម្បីដាក់ឱ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការ ចំនួន៦ ដូចជា គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ គណៈកម្មាធិការឥណទាន គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងបង្កើតនូវ គណៈកម្មាធិការផ្សេងទៀត អាស្រ័យទៅតាមតម្រូវការចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ។ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងអាស្រ័យទៅនឹងក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៅក្នុងគណៈកម្មាធិការ នឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការទាំងនេះ មិនអនុវត្តអំណាចរបស់ក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចជាផ្លូវការ តែត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ចំពោះសកម្មភាពរួមរបស់ពួកគេ ។ គួរបញ្ជាក់ផងដែរថា សមាជិកភាពនៃគណៈកម្មាធិការមិនកំណត់ថា ត្រូវតែជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលនោះទេ ពោលគឺអាចជាអ្នកគ្រប់គ្រង ឬបុគ្គលណាផ្សេងទៀត ដែលសមស្របក្នុងតួនាទីរបស់គណៈកម្មាធិការនីមួយៗ ។ ប៉ុន្តែប្រធាននៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺចាំបាច់ត្រូវតែជាសមាជិក-សមាជិការបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់, និងគណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង អាចដឹកនាំអភិបាលឯករាជ ។

ចំពោះអត្ថបទពេញលេញស្តីពី គណៈកម្មាធិការក្រុមប្រឹក្សាភិបាល សមាជិកភាព និងសកម្មភាពប្រចាំឆ្នាំ២០១៨ មានបង្ហាញជូននៅក្នុងទំព័រទី៣៤ ដល់ ៣៧ ក្នុងរបាយការណ៍នេះ ។



## លោក នាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ គណៈកម្មាធិការឥណទាន

ជនជាតិខ្មែរ កើតក្នុងខែមេសា ឆ្នាំ១៩៥៤ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែកញ្ញា ឆ្នាំ ២០១៤ ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក ។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ ។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោកនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ ។ លោកធ្លាប់ធ្វើជាគណនេយ្យករ និងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពត ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២ ។

បច្ចុប្បន្នលោកជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា ភីអិលស៊ី សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ឡាវ និងសមាជិកក្រុមប្រឹក្សាភិបាលនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ។

## បណ្ឌិត អ៊ិន ចាន់នី អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម



ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់ សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ។

លោកបណ្ឌិតជាអ្នកតំណាងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិតបានបញ្ចប់វគ្គគ្រប់គ្រងស្តីពី ស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។



## លោក រ័ត្ន យូម៉េង អភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២ ។ លោក រ័ត្ន យូម៉េង បានបម្រើការឱ្យអេស៊ីលីដា ចាប់ពីខែមករា ឆ្នាំ១៩៩៩ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែសីហា ឆ្នាំ២០០៨ លោកបានកាន់តំណែងជាច្រើននៅក្នុងធនាគារ អេស៊ីលីដា ដូចជា ៖ ប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែមករា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧) ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។

លោកទទួលខុសត្រូវដឹកនាំក្រុមគ្រប់គ្រង និងត្រួតពិនិត្យរតនាភិបាល ដូចជា ៖ នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ, ការិយាល័យរតនាភិបាល, ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ, និងការិយាល័យរតនពាណិជ្ជកម្ម ។ លោកក៏ជាអ្នកគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទាក់ទងនឹងការគ្រប់គ្រងមូលនិធិ ។

បន្ថែមពីនេះទៀត លោកក៏កាន់មុខតំណែងជាប្រធាន និងសមាជិក របស់គណៈកម្មាធិការជាច្រើន នៅក្នុងធនាគារ អេស៊ីលីដា ដូចជា ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម, គណៈកម្មាធិការធានារ៉ាប់រងមូលបត្រ, និងគណៈកម្មាធិការឥណទាន ។

ចាប់ពីឆ្នាំ២០០១ ដល់ខែកញ្ញា ឆ្នាំ២០១៤ លោកជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន អេ អេស អេ ដែលជាភាគទុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ នៅខែសីហា ឆ្នាំ២០១៤ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពី វិទ្យាស្ថានអូស្រ្តាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

## បណ្ឌិត Pieter Kooi អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (ប្រធាន), គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ (ប្រធាន), គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម



ជនជាតិហូល្លង់ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០ ។ លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហូល្លង់ ។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ ។ ចាប់ពីឆ្នាំ១៩៩៩ បណ្ឌិត Pieter KOOI បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្រ្វិក និងអាស៊ី ។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូយ៉ក ។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជា វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា) និងអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ។ បច្ចុប្បន្នលោកធ្វើជាក្រុមប្រឹក្សាភិបាលនៅក្នុងស្ថាប័នជាច្រើននៅអាស៊ី ។ លោកបានបញ្ចប់ការសិក្សាពី វិទ្យាស្ថានអូស្រ្តាលីសម្រាប់អភិបាលក្រុមហ៊ុន ។



## លោកស្រី Femke Bos អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការឥណទាន (ប្រធាន),
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ជនជាតិហូល្លង់ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែសីហា ឆ្នាំ២០០២ ។ លោកស្រីកាន់តំណែងជានាយិកាគ្រប់គ្រងមូលនិធិ របស់ Triodos Microfinance Fund មូលនិធិហិរញ្ញវត្ថុ ដែលមានចំនួន ៣៧០លានអឺរ៉ូ នៅក្នុង Triodos Investment Management នៅក្នុងប្រទេសហូល្លង់ ។ លោកស្រីបានបម្រើការងារនៅក្នុង Triodos Investment Management នៅក្នុងឆ្នាំ២០០២ ក្នុងតួនាទីជាមន្ត្រីវិនិយោគជាន់ខ្ពស់សម្រាប់អាស៊ី ។ លោកស្រី Femke BOS មានបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងវិស័យហិរញ្ញវត្ថុ ទាំងនៅទ្វីបអឺរ៉ុប និងក្នុងទីផ្សារទើបតែចាប់ផ្តើមរីកចម្រើន និងទីផ្សារដែលមានព្រំដែន ។ លោកស្រីធ្លាប់ធ្វើជាសមាជិកាក្រុមប្រឹក្សាភិបាលរបស់ XacBank ក្នុងប្រទេសម៉ុងហ្គោលី និងធនាគារ អេស៊ីលីដា ឡាវ ក្នុងប្រទេសឡាវ ហើយបច្ចុប្បន្នលោកស្រីជាសមាជិកាក្រុមប្រឹក្សាភិបាលរបស់ Early Dawn Microfinance ក្នុងប្រទេសមីយ៉ាន់ម៉ា ។ មុនពេលចូលបម្រើការក្នុង Triodos Investment Management លោកស្រីបានបម្រើការងារ ក្នុងតំណែងថ្នាក់គ្រប់គ្រងជាច្រើននៅធនាគារ ABN AMRO ក្នុងប្រទេសហូល្លង់ ព្រមទាំងទទួលបានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យធនាគារ ។ លោកស្រីបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យ Amsterdam ក្នុងឆ្នាំ១៩៩៤ និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

## កញ្ញា Heng Su Yin អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង
គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន

ជនជាតិសឹង្ហបុរី បានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែធ្នូ ឆ្នាំ២០១៦ ។ លោកស្រី Heng Su Yin បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ពីសាកវិទ្យាល័យ Nanyang Technological នៅក្នុងឆ្នាំ២០០១ និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MIT-Tsinghua) ពីសាកលវិទ្យាល័យ Tsinghua (សាលាសេដ្ឋកិច្ច និងគ្រប់គ្រង) នៅក្នុងឆ្នាំ២០១៣ ។ លោកស្រីបានចាប់ផ្តើមការងារដំបូងជាមួយអាជ្ញាធរគ្រប់គ្រងរូបិយវត្ថុសិង្ហបុរី បន្ទាប់មកក៏បានកាន់កាប់តំណែងជាច្រើន នៅក្នុងទីផ្សារមូលធន របស់ធនាគារ Sumitomo Mitsui Banking Corporation (SMBC) និង Standard Chartered Bank ។ បច្ចុប្បន្នលោកស្រីមានតួនាទីជានាយិកាជាន់ខ្ពស់ នៅក្នុងនាយកដ្ឋានកំណើនទីផ្សារអាស៊ី ដោយទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្រ របស់ធនាគារ SMBC ។ លោកស្រីបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន ។





## លោក Cornelius Obert អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (ប្រធាន)
គណៈកម្មាធិការឥណទាន គណៈកម្មាធិការគ្រប់គ្រងហានិភ័យ គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន

ជនជាតិអាល្លឺម៉ង់ កើតក្នុងឆ្នាំ១៩៥០ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកបានបញ្ចប់ការសិក្សានៅឆ្នាំ១៩៧៦ ដោយទទួលបានសញ្ញាបត្រផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងពីសាកលវិទ្យាល័យ Hamburg ។ លោកធ្លាប់ធ្វើជានាយកគ្រប់គ្រង និងសមាជិកប្រតិបត្តិ នៃក្រុមប្រឹក្សាភិបាលរបស់ Commerzbank International SA Luxembourg និងធ្លាប់ធ្វើជាអគ្គនាយក Commerzbank AG, សាខា Johannesburg ។ ទទួលខុសត្រូវលើជំនួញសាជីវកម្ម រតនាគារ ជំនួញលោហៈមានតម្លៃ និងហិរញ្ញប្បទានពាណិជ្ជកម្ម ។

### **លោក** Ian S. Lydall អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង (ប្រធាន) គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន (ប្រធាន) គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ



ជនជាតិអង់គ្លេស កើតក្នុងឆ្នាំ១៩៥៥ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកធ្លាប់ធ្វើជានាយកប្រតិបត្តិ និងជាប្រធានក្រុមហ៊ុន PwC នៅវៀតណាម ។ លោកបានចូលនិវត្តន៍ពីក្រុមហ៊ុននេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ។ លោកមានបំណងរួមចំណែកជាមួយធនាគារអេស៊ីលីដា ដោយប្រើប្រាស់បទពិសោធន៍របស់លោកខាងផ្នែករបាយការណ៍ហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ យុទ្ធសាស្ត្រ និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ និងស៊ីជម្រៅទាក់ទងនឹងសេវាហិរញ្ញវត្ថុ ។



### **លោក** Marc Robert អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង

ជនជាតិបារាំង កើតក្នុងឆ្នាំ១៩៧៣ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥ ។ លោកបានបញ្ចប់ការសិក្សាពី ESSEC និង Science Po Paris ព្រមទាំងទទួលបានសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ California Davis និងសាកលវិទ្យាល័យ Toulouse ក្នុងឆ្នាំ២០០៣ ។ លោកបានចាប់ផ្តើមការងារខាងផ្នែកមូលនិធិរូបិយវត្ថុអន្តរជាតិ និងក្រោយមកទៀតធ្វើជាក្រុមប្រឹក្សាគ្រប់គ្រងធនាគារអឺរ៉ុបមួយចំនួន ។ បច្ចុប្បន្នលោកបម្រើការនៅ BRED Banque Populaire ក្នុងតួនាទីជាសមាជិកនៃថ្នាក់គ្រប់គ្រងក្រុមប្រឹក្សាភិបាល និងជាប្រធានអន្តរជាតិ ដោយទទួលបន្ទុកគ្រប់គ្រងបុត្រសម្ព័ន្ធក្រៅប្រទេស ចំនួន ១២ នៅជុំវិញពិភពលោក ។

### **លោក** Ryoji Nishimura អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង



ជនជាតិជប៉ុន កើតក្នុងឆ្នាំ១៩៧៤ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែមេសា ឆ្នាំ២០១៨ ។

បច្ចុប្បន្នលោកកាន់តំណែងជាអគ្គនាយក ក្រុមអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគសកល នៃទីស្នាក់ការកណ្តាល នៃការវិនិយោគនិងប្រតិបត្តិការរបស់ក្រុមហ៊ុន ORIX Corporation ។ លោកក៏ជានាយក និងសមាជិក IC នៃមូលនិធិ United Orient Capital "UOC" និងជានាយកនៃ DI Asian Industrial Fund "DIAIF" ដែលដើរតួជា PE Investment Fund ប្រចាំប្រទេសសឹង្ហបុរី និងវៀតណាម ហើយបានចូលរួមក្នុងគម្រោងការគ្រប់គ្រងវិនិយោគនៃទ្វីបអឺរ៉ុប អាហ្វ្រិក និងអាស៊ីអាគ្នេយ៍ ។ លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ TenGer Financial Group ដែលជាក្រុមសេវាហិរញ្ញវត្ថុម៉ុងហ្គោលី បម្រើសេវាធនាគារ និងហិរញ្ញវត្ថុយ៉ាងទូលំទូលាយផងដែរ ។

លោកបានទទួលបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Ritsumeikan ក្នុងខែមេសា ឆ្នាំ១៩៩៦ និងបានចាប់ផ្តើមបម្រើការងារឱ្យ Nagoya Branch ។ ចាប់ពីឆ្នាំ២០០៥ ដល់ ២០០៨ លោកធ្វើជាអ្នកដឹកនាំគម្រោងបង្កើតក្រុមហ៊ុនធានារ៉ាប់រងនៅក្រៅប្រទេស និងបានធ្វើកិច្ចចរចារជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់ជាមួយរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសអៀរឡង់ និងការិយាល័យច្បាប់ ។ ចាប់ពីឆ្នាំ ២០០៩ ដល់ ២០០១៤ លោកបានបម្រើការជាមួយ ORIX Taiwan Corporation ក្នុងកោះតៃវ៉ាន់ ដោយបានចូលរួមក្នុងអាជីវកម្មវិនិយោគ NPL ។

# គណៈកម្មាធិការប្រតិបត្តិ

ប្រធាននាយកប្រតិបត្តិត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ និងមានសិទ្ធិពេញលេញ ក្នុងការចាត់ចែងការងារប្រចាំថ្ងៃរបស់ធនាគារ នៅក្នុងវង្វង់គោលការណ៍ និងយុទ្ធសាស្ត្រដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ទោះជាយ៉ាងណា ភាពច្បាស់លាស់ នៃសិទ្ធិអំណាចអាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងការកត់ត្រាទុកជាផ្លូវការនៅក្នុង "Letters of Reserved Matters" ។

ប្រធាននាយកប្រតិបត្តិ ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមាន សមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលវេលា) ។ ប្រធាននាយកប្រតិបត្តិជាអ្នកកំណត់ពេលវេលាប្រជុំ និងកិច្ចដំណើរការ នៃគណៈកម្មាធិការប្រតិបត្តិ ក្រោមការដឹកនាំផ្ទាល់ ប្រកបដោយភាពមធ្យ័តទៅលើ ៖

- យុទ្ធសាស្ត្រផ្ទាល់ ៖ អភិវឌ្ឍគោលការណ៍ កំណត់គោលដៅ យុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តទៅតាមយុទ្ធសាស្ត្រដែលបានព្រមព្រៀង និងប្រតិបត្តិទៅតាមគោលដៅ ដែលបានកំណត់ ។
- ហានិភ័យ ៖ កំណត់ និងវាយតម្លៃទៅលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ធនាគារ និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថាធនាគារប្រតិបត្តិស្របតាមតម្រូវការ របស់សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។



## បណ្ឌិត អ៊ិន ចាន់នី
ប្រធាននាយកប្រតិបត្តិ

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ។

លោកបណ្ឌិតជាអ្នកតំណាងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រងស្ដីពីស្ថាប័នហិរញ្ញវត្ថុ សម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្ដីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

- លោក លី ថៃ
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោកស្រី ប៊ុត ប៊ុនសីហា
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម
  និងលេខាធិការក្រុមហ៊ុន
- បណ្ឌិត សូ ផនណារី
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- បណ្ឌិត អ៊ិន ចាន់នី
  ប្រធាននាយកប្រតិបត្តិ
- លោកស្រី ម៉ារ អមរា
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉េង
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក ម៉ាច ផៃរី
  អនុប្រធាននាយកប្រតិបត្តិ
  និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- បណ្ឌិត ឡឹង សុភាព
  អនុប្រធាននាយកប្រតិបត្តិ
  និងជាប្រធាននាយកប្រតិបត្តិហានិភ័យ





## បណ្ឌិត សូ ផនណារី
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ លោកស្រីបណ្ឌិតបានចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៣ ។

ក្នុងមុខតំណែងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ លោកស្រីបណ្ឌិតក៏ជាសមាជិកា គណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និងគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានសេវាឥណទាន និងហិរញ្ញប្បទានពាណិជ្ជកម្ម, និងនាយកដ្ឋានសេវាហិរញ្ញវត្ថុ ។ លោកស្រីបណ្ឌិតទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្រ្ត និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអភិវឌ្ឍន៍ និងស្រាវជ្រាវសេវាថ្មីៗរបស់ធនាគារ ព្រមទាំងធ្វើផែនការនិងអនុវត្តកំណើននៃការលក់ ។ លោកស្រីបណ្ឌិតទទួលខុសត្រូវទៅលើការដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។

លោកស្រីបណ្ឌិតជាប្រធាន គណៈកម្មាធិការគ្រប់គ្រងផលប័ត្រ សមាជិកា គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម គណៈកម្មាធិការកំណត់ថ្លៃផលិតផល និងសេវាកម្ម និងគណៈកម្មាធិការឥណទាន នៃថ្នាក់គ្រប់គ្រង ។

លោកស្រីបណ្ឌិតទទួលខុសត្រូវចំពោះប្រធាននាយកប្រតិបត្តិ ។

លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច និងបានបញ្ចប់វគ្គសិក្សាស្ដីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់ អភិបាលក្រុមហ៊ុន (GAICD) ។

- លោក នេត ពិសិដ្ឋ
  នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុ
- លោក សុខ សុវត្ថិឌី
  នាយកប្រតិបត្តិប្រតិបត្តិការ
- លោកស្រី សុខ សោភា
  នាយិកាប្រតិបត្តិទីផ្សារ
- បណ្ឌិត សូ ផនណារី
  អនុប្រធាននាយកប្រតិបត្តិ និងជា
  គណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- លោក សុត សារ៉ន
  នាយកប្រតិបត្តិសេវាឥណទាន
  និងហិរញ្ញប្បទានពាណិជ្ជកម្ម
- លោក ចរ សុភាព
  នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល





## លោកស្រី ម៉ារ អមរា

**អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ**

ជនជាតិខ្មែរ កើតក្នុងខែកញ្ញា ឆ្នាំ១៩៦៧ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ លោកស្រីក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកស្រីជាប្រធានគណៈកម្មាធិការ Implementation & Conversion of IFRS (International Financial Reporting Standards) ជាសមាជិកាគណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីក៏ជាអ្នកដឹកនាំការងារ Basel Team ផងដែរ ។ លោកស្រីគ្រប់គ្រងលើនាយកដ្ឋានហិរញ្ញវត្ថុ, ការិយាល័យរៀបចំ និងត្រួតពិនិត្យផែនការថវិកា, ការិយាល័យគណនេយ្យគ្រប់គ្រង, និងការិយាល័យគ្រប់គ្រងការអនុវត្តហិរញ្ញវត្ថុ ។ លោកស្រីទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីរួមមាន ៖ ជាប្រធានក្រុមប្រឹក្សាភិបាលអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និងជាអនុប្រធាននៃអេស៊ីលីដា ហ្វាយណាន់ហ្សលត្រាស់ ។

លោកស្រីបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ក្នុងឆ្នាំ២០១៨ និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០៣ ។ ក្រៅពីនោះនៅមានវគ្គសិក្សាជាច្រើន ដូចជា គណនេយ្យគ្រប់គ្រង គណនេយ្យហិរញ្ញវត្ថុ និងសវនកម្ម ជាដើម នៅសាកលវិទ្យាល័យ Regent ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ នៅក្នុងរាជធានីភ្នំពេញ ។

- លោក តឹក ប្រាថ្នា<br>នាយកការិយាល័យ<br>គណនេយ្យគ្រប់គ្រង
- លោក តឹក ពៅចន្ថាលា<br>នាយកការិយាល័យរៀបចំ<br>និងត្រួតពិនិត្យផែនការថវិកា
- លោកស្រី ម៉ារ អមរា<br>អនុប្រធាននាយកប្រតិបត្តិ និងជា<br>គណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោកស្រី ម៉េង ម៉ារីយ៉ាន<br>នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក គួយ វាសនា<br>នាយកការិយាល័យគ្រប់គ្រង<br>ការអនុវត្តហិរញ្ញវត្ថុ





## លោក រ័ត្ន យូម៉េង

**អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល**

ជនជាតិខ្មែរកើតក្នុងឆ្នាំ១៩៦២ ។លោករ័ត្ន យូម៉េង បានបម្រើការឱ្យអេស៊ីលីដា ចាប់ពីខែមករា ឆ្នាំ១៩៩៩ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែសីហា ឆ្នាំ២០០៨ លោកបានកាន់តំណែងជាច្រើន នៅក្នុងធនាគារ អេស៊ីលីដា ដូចជា៖ ប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែមករា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧) ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។

លោកទទួលខុសត្រូវដឹកនាំក្រុមគ្រប់គ្រង និងត្រួតពិនិត្យរតនាភិបាល ដូចជា ៖ នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ ការិយាល័យរតនាភិបាល ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ និងការិយាល័យរតនពាណិជ្ជកម្ម ។ លោកក៏ជាអ្នកគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទាក់ទងនឹងការគ្រប់គ្រងមូលនិធិ ។

បន្ថែមពីនេះទៀត លោកក៏កាន់មុខតំណែងជាប្រធាន និងសមាជិករបស់គណៈកម្មាធិការជាច្រើន នៅក្នុងធនាគារ អេស៊ីលីដា ដូចជា៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម គណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម គណៈកម្មាធិការធានារ៉ាប់រងមូលបត្រ និងគណៈកម្មាធិការឥណទាន ។

ចាប់ពីឆ្នាំ២០០១ ដល់ខែកញ្ញា ឆ្នាំ២០១៤ លោកជាអ្នកតំណាងភាគទុនិករបស់ក្រុមហ៊ុន អេ អេស អេ ដែលជាភាគទុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ នៅខែសីហា ឆ្នាំ២០១៤ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពី វិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

- លោក ប្រាក់ ច័ន្ទវាសនា
  នាយកការិយាល័យរតនពាណិជ្ជកម្ម
- លោកស្រី សុវណ្ណ បុប្ផា
  នាយិកាប្រតិបត្តិប្រតិបត្តិការហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉េង
  អនុប្រធាននាយកប្រតិបត្តិ និងជា
  គណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក វុធ ហេង
  នាយកការិយាល័យជាន់ខ្ពស់
  ប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ
- លោក ថាន់ សារុន
  នាយកការិយាល័យរតនាភិបាល





## លោក លី ថៃ

**អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច**

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៧៥ និងបានបម្រើការនៅអេស៊ីលីដាចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៧ ។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ក្នុងតួនាទីជា ៖ គណនេយ្យករ (១៩៩៧-១៩៩៩) សវនករផ្ទៃក្នុង (១៩៩៩-២០០០) បេឡាធិការ នាយកសាខា និងនាយកការិយាល័យប្រតិបត្តិការ (២០០០-២០០៤) នាយកនាយកដ្ឋានប្រតិបត្តិការ (២០០៤-២០០៦) និងនាយកប្រតិបត្តិប្រតិបត្តិការ (២០០៦-២០១៦) ។

ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច លោកក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លោកទទួលបន្ទុកគ្រប់គ្រង នាយកដ្ឋានធនធានមនុស្ស, នាយកដ្ឋានរដ្ឋបាល, និងការិយាល័យគ្រប់គ្រងប្រព័ន្ធ SWIFT ។ លោកទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោក ជាប្រធានក្រុមប្រឹក្សាភិបាល របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ ក្នុងឆ្នាំ២០០៨ ។

- លោកស្រី ខាត់ ផានីន
  នាយិកាការិយាល័យគ្រប់គ្រងប្រព័ន្ធ SWIFT
- លោក លី ថៃ
  អនុប្រធាននាយកប្រតិបត្តិ និងជា
  គណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោក ណៃ សុខសំណាង
  នាយកប្រតិបត្តិរដ្ឋបាល
- លោក ហូរ រតនៈ
  នាយកប្រតិបត្តិធនធានមនុស្ស





## លោកស្រី ប៊ុត ប៊ុនសីហា

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន

ជនជាតិខ្មែរ កើតក្នុងខែសីហា ឆ្នាំ១៩៨០ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែតុលា ឆ្នាំ២០០៧ ។

ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន លោកស្រីក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្ររួម និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអនុលោមទៅតាមបទបញ្ញត្តិ ព្រមទាំងទំនាក់ទំនងជាមួយភាគទុនិក និងក្រុមប្រឹក្សាភិបាល ។ លោកស្រីទទួលបន្ទុកគ្រប់គ្រងលើនាយកដ្ឋាននីតិកម្ម, ការិយាល័យគ្រប់គ្រងវិវាទ, ការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ, និងការិយាល័យលេខាធិការក្រុមហ៊ុន ។ លោកស្រីទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

លោកស្រីទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ក្នុងឆ្នាំ២០០៦ ។បច្ចុប្បន្នលោកស្រីកំពុងសិក្សាថ្នាក់បរិញ្ញាបត្រភាសាអង់គ្លេស នៅសាកលវិទ្យាល័យ វេស្ទើន និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

- លោក យិន វីរៈ
  នាយកការិយាល័យលេខាធិការក្រុមហ៊ុន
- លោក កែវ ឆពណ្ណពិសី
  នាយកការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ
- លោកស្រី ប៊ុត ប៊ុនសីហា
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
- លោក សួស ឧសភា
  នាយកប្រតិបត្តិនិតិកម្ម
- លោក សាវ៉ែណ្ណ ម៉ាលីកា
  នាយកការិយាល័យគ្រប់គ្រងវិវាទ





## លោក ម៉ាច ផៃរី

**អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា**

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៥ ។ លោក ម៉ាច ផៃរី បានបម្រើការងារឱ្យអង្គការ-ស្ថាប័នជាច្រើន ដូចជា ធនាគារ ANZ ក្នុងប្រទេសអូស្ត្រាលី សាកលវិទ្យាល័យ Monash, UNHCR ប្រចាំប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកកម្ពុជា អង្គការពលកម្មអន្តរជាតិ និងចុងក្រោយធ្វើជាទីប្រឹក្សាឱ្យអង្គការ អេស៊ីលីដា ។ លោកបានចូលបម្រើការពេញម៉ោងនៅធនាគារ អេស៊ីលីដា ក្នុងខែកក្កដា ឆ្នាំ២០០០ ។ លោក ម៉ាច ផៃរី បានកាន់តំណែងជានាយកប្រតិបត្តិបច្ចេកវិជ្ជាព័ត៌មាន នៃធនាគារ អេស៊ីលីដា ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១៧ ។ បន្ទាប់មកលោកក៏ត្រូវបានតែងតាំងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា ។ លោកក៏ធ្វើជាប្រធានគណៈកម្មាធិការ IT Steering និងរាយការណ៍ជូនគណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាននៃក្រុមប្រឹក្សាភិបាល ។

លោកទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រនិងស្ថិតិ ពីសាកលវិទ្យាល័យ Monash នៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៨៦ ។ បន្ទាប់មកលោកបានបន្តការសិក្សាផ្នែកប្រព័ន្ធអាជីវកម្ម ( Business Systems ) និងបានទទួលសញ្ញាបត្រ ក្នុងឆ្នាំ១៩៩០ ពីសាកលវិទ្យាល័យដដែលនោះ ។

- លោកស្រី សោម ចិន្តាមុនី
  នាយិកាការិយាល័យសេវាកម្មព័ត៌មានវិទ្យា
- លោក មៀង តាយ
  នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន
- លោក ម៉ាច ផៃរី
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- លោក ស៊ុន សុខារីនោ
  នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា
- លោក គង់ ដានី
  នាយកប្រតិបត្តិប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- លោក អ៊ុក ស្រស់
  នាយកប្រតិបត្តិរៀបចំយុទ្ធសាស្ត្រ និងអភិបាលព័ត៌មានវិទ្យា





## បណ្ឌិត ឡឹង សុភាព

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ

ជនជាតិខ្មែរ កើតក្នុងខែមីនា ឆ្នាំ១៩៦៧ ។ បណ្ឌិត ឡឹង សុភាព បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Preston រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១២ ។ លោកបានបម្រើការងារជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៧ ជាគណនេយ្យករ ។ ចាប់ពីពេលនោះមក លោកទទួលមុខងារ និងតួនាទីផ្សេងៗជាច្រើននៅក្នុងធនាគារ ។ បច្ចុប្បន្ន ក្នុងតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ លោកទទួលខុសត្រូវគ្រប់គ្រងហានិភ័យឥណទាន និងហានិភ័យផ្សេងៗទៀតរបស់ធនាគារទាំងមូល ។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៧ ។

- លោក នូ សុធារ៉ា
  នាយកប្រតិបត្តិឥណទាន
- បណ្ឌិត ឡឹង សុភាព
  អនុប្រធាននាយកប្រតិបត្តិ និងជា
  គណៈប្រធាននាយកប្រតិបត្តិហានិភ័យ
- លោក ទេព ប៊ុនធឿន
  នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ



# នាយកដ្ឋានអនុលោមបញ្ញត្តិ



## លោក ហុក លាងគ្រី
នាយកប្រតិបត្តិអនុលោមបញ្ញត្តិ

ជនជាតិខ្មែរ កើតក្នុងខែធ្នូ ឆ្នាំ១៩៧៧ ។ លោកបានចូលបម្រើការងារជាមួយអេស៊ីលីដា ចាប់ពីខែកុម្ភៈ ឆ្នាំ២០០២ ។ ក្នុងមុខតំណែងជានាយកប្រតិបត្តិអនុលោមបញ្ញត្តិ លោកទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអនុលោមភាពប្រចាំថ្ងៃរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ។ ដើម្បីធានានូវឯករាជ្យភាពនៃតួនាទី អនុលោមភាពរបស់ ធនាគារ អេស៊ីលីដា តម្រូវឱ្យលោកជាអ្នករាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាល ព្រមទាំងគណៈកម្មាធិការប្រតិបត្តិផងដែរ ។ លោកត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាល ដើម្បីផ្តល់ព័ត៌មាន និងបង្ហាញពីអនុលោមភាព និងបញ្ហាពាក់ព័ន្ធនឹងវិសាលភាព និងគោលបំណងរបស់គណៈកម្មាធិការ ។

លោកទទួលខុសត្រូវដឹកនាំនាយកដ្ឋានអនុលោមបញ្ញត្តិ ដែលមាន ៤ផ្នែក គឺ ផ្នែកប្រតិបត្តិ, ផ្នែករបាយការណ៍ប្រតិបត្តិ, ផ្នែកវិភាគប្រតិបត្តិការ, និងផ្នែកប្រតិបត្តិតាមច្បាប់ ។

លោកទទួលបានសញ្ញាបត្រជាន់ខ្ពស់ចំនួនពីរ គឺ សញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ ឯកទេសផ្នែកច្បាប់ឯកជន ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៦ និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យប្រេស្តុន សហរដ្ឋអាមេរិក (សាខាក្នុងប្រទេសកម្ពុជា) ឆ្នាំ២០១២ ។ លោកបានទទួលបរិញ្ញាបត្រគ្រប់គ្រងអាជីវកម្មជំនាញគណនេយ្យ ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០១ ។

# សវនករផ្ទៃក្នុង



## លោកស្រី គឹម សុធាវី

គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៦៥ ។ លោកស្រីបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៩៤ ។ ក្នុងមុខតំណែងជាគណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង លោកស្រីទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងសវនកម្មផ្ទៃក្នុងប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការសវនកម្មផ្ទៃក្នុង ។ ដើម្បីធានាឱ្យបានឯករាជ្យភាព នៃមុខងារជាសវនកម្មផ្ទៃក្នុង លោកស្រីជាអ្នករាយការណ៍ផ្ទាល់ ទៅគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាល ។ លោកស្រីត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរបស់ គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ដើម្បីផ្តល់ព័ត៌មាន និងពន្យល់ពីបញ្ហានានាទាក់ទងនឹងវិសាលភាព និងគោលបំណងរបស់គណៈកម្មាធិការ ។

លោកស្រីគ្រប់គ្រង និងដឹកនាំក្រុមសវនកម្មផ្ទៃក្នុង ដែលមាន ១ នាយកដ្ឋាន និង ៥ការិយាល័យ ដូចជា ៖ នាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង, ការិយាល័យរបាយការណ៍សវនកម្ម, ការិយាល័យសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា, ការិយាល័យសវនកម្មឥណទាន, ការិយាល័យសវនកម្មហិរញ្ញវត្ថុ, និងការិយាល័យសវនកម្មប្រាក់បញ្ញើ និងផ្ទេរប្រាក់ ។

លោកស្រីទទួលបានអនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ។

- លោក ទុំ សុខចំរើន
  នាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ
- លោក ចាន់ បូរីវុឌ្ឍ
  នាយកការិយាល័យសវនកម្មឥណទាន
- លោកស្រី ង៉ែត ណារី
  នាយិកាការិយាល័យសវនកម្មប្រាក់បញ្ញើ និង Digital Banking
- លោកស្រី គឹម សុធាវី
  គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង
- លោក ថាត ឌីណុត
  នាយកប្រតិបត្តិអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
- លោក សុក ហៃ
  នាយកការិយាល័យរបាយការណ៍សវនកម្ម
- លោក សុខ ពិសិដ្ឋ
  នាយកការិយាល័យសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា



# ក្រមសីលធម៌

ក្នុងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ១. អនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារ ២. កិច្ចព្រមព្រៀងភាគទុនិក និង ៣. ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធរបស់ព្រះរាជាណាចក្រ កម្ពុជា ។ ការរីកវិវឌ្ឍឥតឈប់ឈររបស់ធនាគារ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងខែមីនា ឆ្នាំ២០០៥ ក្រុមប្រឹក្សាភិបាលបានផ្តល់អនុសាសន៍មួយលើការកំណត់ និងវាយតម្លៃលើបញ្ហាទាំងមូលនៃអភិបាលកិច្ចសាជីវកម្ម ដើម្បីកំណត់ពីតម្រូវការនៃការរីកលូតលាស់ទៅមុខរបស់ធនាគារ ។ ក្នុងចំណោមបញ្ហាផ្សេងៗ រួមមាន កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាលតួនាទី មុខងាររបស់ក្រុមប្រឹក្សាភិបាលបញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឱ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល បានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល បានចូលរួមវគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុនអន្តរជាតិ ដែលរៀបចំដោយវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាលដើម្បីបន្តអភិវឌ្ឍនូវជំនាញវិជ្ជាជីវៈ និងសមត្ថភាពរបស់ខ្លួន ។

កម្មករនិយោជិតគ្រប់រូបរបស់ធនាគារអេស៊ីលីដា ស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរឹងនៃក្រមសីលធម៌ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជា ចរិតលក្ខណៈបុគ្គលទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។ ឯកសារទាំងនេះ បានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ ដោយគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ដើម្បីធានាថា វានៅតែមានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។



វគ្គហ្វឹកហ្វឺនក្រមសិលធម៌ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំគ្នាផ្ទាល់ចំនួន៣ដង ក្នុងរាជធានីភ្នំពេញនៅខែមីនា មិថុនា និងធ្នូ និងបានធ្វើដំណើរទៅប្រជុំមួយទៀតនៅទីក្រុង Amsterdam ប្រទេសហូល្លង់ នៅខែកញ្ញា ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាភិបាលក៏បានអនុម័តតាមរយៈអ៊ីម៉ែល ចំនួន ១៧ ចំណុច ។ កិច្ចប្រជុំនីមួយៗជាធម្មតាមានរយៈពេលពីរថ្ងៃ ដោយរួមបញ្ចូលទាំងកិច្ចប្រជុំគណៈកម្មាធិការផងដែរ ។

## សកម្មភាពចម្បងៗ ក្នុងឆ្នាំ២០១៨

- តែងតាំង PwC សិង្ហបុរី ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងគម្រោងសុវត្ថិភាពប្រព័ន្ធអ៊ីនធើណែត របស់ធនាគារ ។
- អនុម័តគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល ។
- អនុម័តផែនការអាជីវកម្ម សម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ។
- អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ព្រមទាំងលិខិតថ្នាក់គ្រប់គ្រង សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ។
- អនុម័តការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៧ នៃប្រាក់ចំណេញក្រោយដកពន្ធ និងផ្ទេរប្រាក់ចំណេញក្រោយដកពន្ធដែលនៅសល់ទៅជាទុនបម្រុងរបស់ធនាគារ ។
- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- អនុម័តបង្កើនដើមទុន ពីការបែងចែកភាគលាភ ។
- ទទួលស្គាល់ លោក Ryoji Nishimura មកពី ORIX ជាសមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី និងស្នើសុំការអនុម័តពីភាគទុនិក ។
- ពិនិត្យឡើងវិញ និងអនុម័ត តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលនីមួយៗ ។
- អនុម័តផែនការយុទ្ធសាស្ត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- តែងតាំងក្រុមហ៊ុនសវនករខាងក្រៅ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ឆ្នាំ២០១៨ ២០១៩ និង ២០២០ ។
- អនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដោយអនុឡោមតាមរបាយការណ៍ហិរញ្ញវត្ថុស្តង់ដារអន្តរជាតិ របស់ប្រទេសកម្ពុជា (CIFRS) ដែលបានរៀបចំដោយ PwC និងបានដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច ។
- អនុម័តការចុះឈ្មោះការិយាល័យតំណាងរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងប្រទេសមីយ៉ាន់ម៉ា ឡើងវិញ ស្របតាមច្បាប់ថ្មីរបស់ប្រទេសមីយ៉ាន់ម៉ា ។
- អនុម័តកម្ចីមួយ ពីស្ថាប័នផ្តល់ប្រាក់កម្ចីអន្តរជាតិ ។
- អនុម័ត និងទទួលស្គាល់លោក Yuichi Nishimura ជាតំណាងភាគទុនិករបស់ SMBC នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី និងដាក់ជូនភាគទុនិកដើម្បីសម្រេច ។

## របាយការណ៍របស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (BALCO)
- គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ (BACCO)
- គណៈកម្មាធិការឥណទាន (BCC)
- គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន (BITCO)
- គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង (BRENCO)
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (BRMC)

## គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (BALCO)

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (BALCO) បានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាភិបាល ដោយផ្តល់យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ ។

### សមាជិក

| | |
|---|---|
| ១. លោក Cornelius Obert (ប្រធាន) | អភិបាលឯករាជ |
| ២. លោក ឆាយ សឿន | អភិបាលមិនប្រតិបត្តិ |
| ៣. បណ្ឌិត Pieter Kooi | អភិបាលឯករាជ |
| ៤. បណ្ឌិត អ៊ិន ចាន់នី | អភិបាលប្រតិបត្តិ |

BALCO មានសមាជិក-សមាជិកាមិនប្រតិបត្តិយ៉ាងតិច២នាក់ ដែលក្នុងនោះមានម្នាក់ធ្វើជាប្រធាន ។

បន្ថែមពីនេះទៀត អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិឥនាភិបាល និង អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ ត្រូវបានអញ្ជើញចូលរួមគ្រប់កិច្ចប្រជុំ ។ ប្រសិនបើចាំបាច់ថ្នាក់គ្រប់គ្រងដែលពាក់ព័ន្ធរបស់ធនាគារ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំផងដែរ ដើម្បីផ្តល់ព័ត៌មាន និងការពន្យល់ពីបញ្ហាផ្សេងៗទាក់ទងនឹងវិសាលភាព និងគោលបំណងរបស់គណៈកម្មាធិការ ប៉ុន្តែពួកគាត់មិនមានសិទ្ធិបោះឆ្នោតទេ ។

### កិច្ចប្រជុំ

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្មបានជួបប្រជុំ៤ដងក្នុងឆ្នាំ២០១៨ នៅខែមីនា មិថុនា កញ្ញា និងធ្នូ ។ លើសពីនេះទៅទៀត មានកិច្ចប្រជុំពិសេសទល់មុខគ្នា១លើក នៅក្នុងខែមករា ដើម្បីពិនិត្យក្របខណ្ឌការគ្រប់គ្រងហានិភ័យសាច់ប្រាក់ ហើយកិច្ចប្រជុំ២លើកទៀតបានធ្វើតាមរយៈអ៊ីម៉ែលនៅខែមីនា និងវិច្ឆិកា ដើម្បីពិនិត្យពីសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ២០១៧ ព្រមទាំងដាក់ជូនក្រុមប្រឹក្សាភិបាល ហើយនិងអនុម័តលើសំណើថវិការបស់ថ្នាក់ដឹកនាំ ។

## បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៨

- ដោយយោងតាមលក្ខខណ្ឌតម្រូវនៃប្រកាសរបស់ ធនាគារជាតិ នៃ កម្ពុជា ស្តីពី "Liquidity Risk Management Framework" (LRMF) BALCO បានពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ និងផ្តល់យោបល់ដើម្បីកែសម្រួលលើ LRMF នេះ ចាប់ពីត្រីមាសចុងក្រោយនៃឆ្នាំ២០១៧ រហូតដល់ដើមឆ្នាំ២០១៨ ។ នៅខែមីនា ឆ្នាំ២០១៨ LRMF ជំនាន់ដំបូងបានរៀបចំរួចរាល់ និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។
- BALCO បានពិភាក្សាយ៉ាងសកម្មអំពីកម្រិតសុវត្ថិភាពសន្ទនីយភាព ដែលសមស្រប ដើម្បីរៀបចំទប់ស្កាត់ព្រឹត្តិការណ៍សន្ទនីយភាព ដែលមិនបានរំពឹងទុក ដែលអាចកើតឡើងមុនពេល អំឡុងពេល និងក្រោយការបោះឆ្នោតជាតិនាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ។ ដើម្បីរក្សាសុវត្ថិភាព និងតាមរយៈការផ្តល់ដំបូន្មាន និងការគាំទ្រពី BALCO ក្រុមរតនាភិបាលបានរក្សាកម្រិតសាច់ប្រាក់ងាយស្រួលខ្ពស់ ដោយបន្ថែម ៣0% ទៀតលើសពីបញ្ញត្តិតម្រូវនៃកម្រិតរបស់អនុបាតសន្ទនីយភាព ។
- ដោយគិតគូរពីរចនាសម្ព័ន្ធអត្រាការប្រាក់របស់ធនាគារ និងការអភិវឌ្ឍអត្រាការប្រាក់អន្តរជាតិ ថ្នាក់ដឹកនាំ និង BALCO បានពិនិត្យយ៉ាងដិតដល់ពីទីផ្សារស្វប ។ ជាមួយនឹងការគាំទ្រ និងលើកទឹកចិត្តរបស់ BALCO ថ្នាក់ដឹកនាំបានបញ្ចប់ដោយជោគជ័យនូវ ប្រតិបត្តិការផ្តោះប្តូរអត្រាការប្រាក់ជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងធនាគារ កាថេយូណៃធីត សម្រាប់កម្ចីរយៈពេលវែងរបស់ធនាគារ ដែលមានចំនួនសរុប ៨0លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ។
- ដើម្បីគាំទ្រដល់តម្រូវការមូលនិធិក្នុងឆ្នាំ២០១៨ BALCO បានអនុម័តលើសំណើសុំថវិកាជាច្រើនរបស់ថ្នាក់គ្រប់គ្រង ដែលមានចំនួនទឹកប្រាក់សរុប ១៦១,៤ លានដុល្លារអាមេរិក ហើយក្នុងចំណោមនោះមានឥណទានបន្ទាប់បន្សំចំនួន ១១,៤ លានដុល្លារអាមេរិក ។
- BALCO បានពិភាក្សាជាច្រើនពីគុណសម្បត្តិ និងគុណវិបត្តិនៃលទ្ធភាពបោះផ្សាយប័ណ្ណបំណុលជាប្រាក់រៀល ។ ជាចុងក្រោយ គណៈកម្មាធិការបានគាំទ្រលើសំណើរបស់ថ្នាក់គ្រប់គ្រង ចំពោះការបោះផ្សាយប័ណ្ណបំណុលនេះ ។ ប័ណ្ណបំណុលនេះ នឹងជួយដល់កំណើនប្រាក់កម្ចីរយៈពេលវែងជាប្រាក់រៀលដែលអាចឱ្យធនាគារអនុវត្តយ៉ាងពេញលេញ តាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា ស្តីពីការផ្តល់ឥណទានជារូបិយវត្ថុក្នុងស្រុក របស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ។ តាមប្រកាសនេះ គឺតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ផ្តល់ឥណទានសរុបជារូបិយវត្ថុក្នុងស្រុក យ៉ាងហោចណាស់ ១0% នៃឥណទានសរុប ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ ។
- BALCO បានទទួល និងពិនិត្យលទ្ធផលនៃការធ្វើតេស្តភាពតានតឹង និងផែនការផ្តល់មូលនិធិសម្រាប់ឆ្នាំ២០១៩ ពីថ្នាក់គ្រប់គ្រង មុនពេលដាក់ជូនធនាគារជាតិ នៃ កម្ពុជា នៅដំណាច់ឆ្នាំ២០១៨ ។
- ដោយពិចារណាលើកំណើន និងរចនាសម្ព័ន្ធអាជីវកម្មរបស់ធនាគារ BALCO បានពិនិត្យយ៉ាងសកម្ម ហើយបានផ្តល់ដំបូន្មាន លើការគ្រប់គ្រង និងការបែងចែកដើមទុន ដើម្បីធានាថាធនាគារបានអនុលោមស្របតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា ស្តីពីការកំណត់ដើមទុននៃស្ថាប័នធនាគារ និងហិរញ្ញវត្ថុ ។
- BALCO បានធ្វើការជាមួយថ្នាក់គ្រប់គ្រង លើការបន្តពិនិត្យឡើងវិញនៃផែនការអាជីវកម្ម រយៈពេល៥ឆ្នាំ ២០១៩-២០២៣ របស់ធនាគារ ក្នុងគោលបំណងសម្រេចបាននូវអត្រាកំណើនប្រកបដោយនិរន្តរភាព ខណៈដែលរក្សានូវអនុបាតសន្ទនីយភាព និងអនុបាតដើមទុនខ្លាំង ។
- គណៈកម្មាធិការបានទទួល និងពិនិត្យយ៉ាងទៀតទាត់របាយការណ៍ប្រចាំខែរបស់គណៈកម្មាធិការគ្រប់គ្រង់ទ្រព្យសកម្ម និងអកម្មនៃថ្នាក់គ្រប់គ្រង និងតាមដានតួនាទីសន្ទនីយភាព ការកំណត់មិនទៀងទាត់ និងការប្តូរប្រាក់បរទេស ដើម្បីអនុលោមតាមគោលនយោបាយ និងបទប្បញ្ញត្តិរបស់ធនាគារ ។
- BALCO បានចាប់ផ្តើម ព្រមទាំងបន្តបង្កើនការពិនិត្យមើលពីបម្រែបម្រួលរយៈពេលវែងនៃសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា ជាមួយនឹងការអភិវឌ្ឍរយៈពេលវែង នៃតារាងតុល្យការរបស់ធនាគារដើម្បីបង្កើនការបែងចែកមូលធន និងប្រភពមូលនិធិ ។

# គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ (BACCO)

## វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ (BACCO) បានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង, សវនកម្មផ្ទៃក្នុងនិងមុខងារខាងកិច្ចការច្បាប់ ព្រមទាំងសេវាកម្មរបស់សវនករខាងក្រៅ ។

គណៈកម្មាធិការនេះមានអភិបាលឯករាជ្យចំនួនពីររូប ដែលមួយរូបត្រូវបានតែងតាំងជាប្រធាន ។ តាមសំណើរបស់គណៈកម្មាធិការ, គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង, នាយកប្រតិបត្តិអនុលោមបញ្ញត្តិ និងអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន ព្រមទាំងសមាជិក-សមាជិកាផ្សេងទៀតនៃគណៈកម្មាធិការប្រតិបត្តិរបស់ធនាគារអាចត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំម្តងហើយម្តងទៀត ដើម្បីផ្តល់ព័ត៌មាន និងពន្យល់លើបញ្ហានានាដែលទាក់ទងទៅនឹងវិសាលភាពនិងគោលបំណងនៃគណៈកម្មាធិការនេះ ។

## សមាជិក

| | |
|---|---|
| ១. បណ្ឌិត Pieter Kooi (ប្រធាន) | អភិបាលឯករាជ |
| ២. លោក ឆាយ សឿន | អភិបាលមិនប្រតិបត្តិ |
| ៣. លោក Ian S. Lydall | អភិបាលឯករាជ |

## កិច្ចប្រជុំក្នុងឆ្នាំ២០១៨

គណៈកម្មាធិការបានជួបគ្នាក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញចំនួនប្រាំបីដងក្នុងឆ្នាំ២០១៨ គឺនៅខែកុម្ភៈ មីនា ឧសភា មិថុនា កក្កដា កញ្ញា និងខែធ្នូ ។ បន្ថែមពីនេះទៀត កិច្ចប្រជុំបានប្រារព្ធឡើង បីដង តាមអ៊ីម៉ែល គឺក្នុងខែមករា និងខែមេសា ដើម្បីអនុម័តគោលនយោបាយក្រុមប្រឹក្សាភិបាល និងដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច ។ កិច្ចប្រជុំមួយទៀតក្នុងខែសីហា ដើម្បីអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ឆ្នាំ២០១៧ ដោយអនុលោមតាមរបាយការណ៍ហិរញ្ញវត្ថុស្តង់ដារអន្តរជាតិនៃកម្ពុជា និងដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច ។

ក្នុងឆ្នាំ២០១៨ សវនករខាងក្រៅ "ប្រាយវ៉ែតធ័រហោវខូភើស (PwC)" បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរបស់ BACCO នៅខែកុម្ភៈ ដើម្បីបង្ហាញរបាយការណ៍សវនកម្មឆ្នាំ២០១៧ ។ នៅខែធ្នូ សវនករខាងក្រៅ KPMG បានចូលរួមប្រជុំដើម្បីបង្ហាញពីវឌ្ឍនភាព នៃរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០១៨ និងលិខិតរបស់ថ្នាក់គ្រប់គ្រង ។

## បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៨

- ពិនិត្យឡើងវិញ អនុម័ត និងបានបន្តផ្ញើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ នៃរបាយការណ៍ហិរញ្ញវត្ថុបានធ្វើសវនកម្ម ឆ្នាំ២០១៧ ។
- បានពិនិត្យឡើងវិញនូវរបាយការណ៍ថ្នាក់គ្រប់គ្រងរបស់ ក្រុមហ៊ុន PwC សម្រាប់ឆ្នាំ២០១៧ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងផងដែរ ។
- ពិនិត្យ និងតាមដានដំណើរការនៃការអនុវត្ត និងការអភិវឌ្ឍ IFRS របស់ថ្នាក់គ្រប់គ្រង ។
- បានពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងឆ្នាំ២០១៧ ដើម្បីដាក់ជូនធនាគារជាតិនៃកម្ពុជា ។
- ពិនិត្យឡើងវិញនូវរបាយការណ៍សវនកម្មផ្ទៃក្នុង និងវិភាគពីនិន្នាការ ឬហេតុការណ៍មិនប្រក្រតីនានា ។
- ពិនិត្យ និង អនុម័តតួនាទីនិងភារកិច្ច របស់គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិអនុលោមបញ្ញត្តិ ។
- បានពិនិត្យឡើងវិញនូវរបាយការណ៍របស់នាយកដ្ឋានអនុលោមបញ្ញត្តិ និងបានទទួលការវិភាគអំពីប្រតិបត្តិការសង្ស័យណាមួយ ។
- ពិនិត្យ និងអនុម័តផែនការកំណត់ប្រាក់លើកទឹកចិត្ត សម្រាប់សវនកម្មផ្ទៃក្នុង និងនាយកដ្ឋានអនុលោមបញ្ញត្តិ ហើយបានដាក់សំណើជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត ។
- បានពិនិត្យឡើងវិញ និងអនុម័តផែនការសវនកម្មផ្ទៃក្នុងសារពើពន្ធឆ្នាំ២០១៩ ។
- បានពិនិត្យ និងអនុម័តផែនការថវិការបស់នាយកដ្ឋានអនុលោមបញ្ញត្តិ សម្រាប់ឆ្នាំសារពើពន្ធ ២០១៩ ។
- បានពិនិត្យឡើងវិញនូវរបាយការណ៍អធិការកិច្ច (AML/CFT) របស់ធនាគារជាតិ នៃ កម្ពុជា ។
- បានពិនិត្យ និងអនុម័តតួនាទីនិងភារកិច្ចរបស់ BACCO និងបានដាក់ឱ្យក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត ។
- បានពិនិត្យ គោលនយោបាយជាច្រើន ដូចជា ៖ គោលនយោបាយបណ្តឹងរបស់អតិថិជន, គោលនយោបាយភាគលាភ, គោលនយោបាយក្រុមសីលធម៌, គោលនយោបាយទំនាស់ផលប្រយោជន៍, គោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង, គោលនយោបាយអនុលោមភាព, គោលនយោបាយ Whistle Blower's Protection, គោលនយោបាយប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រឆាំងនឹងការផ្តល់ហិរញ្ញប្បទានភេរវកម្ម, គោលនយោបាយ KYC/Customer Due Diligence, និងគោលនយោបាយផ្សេងៗទៀត ។

## របាយការណ៍ និងអនុសាសន៍

វាជាយោបល់របស់គណៈកម្មាធិការដែលនីតិវិធីសវនកម្ម និងត្រួតពិនិត្យផ្ទៃក្នុង មានភាពគ្រប់គ្រាន់ ដើម្បីការពារធនាគារ និងដើម្បីផ្តល់នូវការធានាគ្រប់គ្រាន់ពីសុចរិតភាព នៃរបាយការណ៍ហិរញ្ញវត្ថុ ។

គណៈកម្មាធិការពេញចិត្តក្រុមហ៊ុន KPMG ដែលបានបង្ហាញឯករាជ្យភាព និងជំនាញវិជ្ជាជីវៈ ធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងឆ្នាំសារពើពន្ធ ២០១៨ របស់ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

# គណៈកម្មាធិការឥណទាន (BCC)

## វិសាលភាព និងគោលបំណង

គណៈកម្មាធិការឥណទាន (BCC) បានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលស្តីពីគោលនយោបាយឥណទាន សំណើសុំធ្វើវិសោធនកម្មផ្សេងៗ និងត្រួតពិនិត្យគុណភាពឥណទាន ដើម្បីធានាថាសកម្មភាពបង្កាផ្សេងៗត្រូវបានអនុវត្ត និងគោរពតាមច្បាប់ និងបទប្បញ្ញត្តិយ៉ាងពេញលេញ ។

## សមាជិក-សមាជិកា

| | |
|---|---|
| ១. លោកស្រី Femke Bos (ប្រធាន) | អភិបាលមិនប្រតិបត្តិ |
| ២. លោក ឆាយ សឿន | អភិបាលមិនប្រតិបត្តិ |
| ៣. លោក Cornelius Obert | អភិបាលឯករាជ |
| ៤. លោក Marc Robert | អភិបាលមិនប្រតិបត្តិ |

## កិច្ចប្រជុំ

ក្នុងឆ្នាំ២០១៨ គណៈកម្មាធិការឥណទានបានជួបប្រជុំ ៤ដង គឺក្នុងខែមីនា មិថុនា កញ្ញា និងខែធ្នូ ។

ក្នុងកិច្ចប្រជុំនីមួយៗ គណៈកម្មាធិការបានត្រួតពិនិត្យយ៉ាងដិតដល់ នូវគុណភាព នៃសមតុល្យឥណទាន ពិភាក្សាពីស្ថានភាពសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យកសិកម្ម អចលនទ្រព្យ សំណង់ កាត់ដេរ និងទេសចរណ៍ ។ វិស័យកសិកម្មគឺជាប្រធានបទក្តៅគគុកមួយ សម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ ជាពិសេសការធ្លាក់ចុះនៃតម្លៃទំនិញ ដែលប៉ះពាល់ដល់អាជីវកម្មរបស់ធនាគារ ។ គណៈកម្មាធិការបានយកចិត្តទុកដាក់លើការធ្វើពិពិធកម្មហានិភ័យនៅក្នុង ផលបត្របំណុលតាមវិស័យជាក់លាក់មួយចំនួន និន្នាការទីផ្សារ គុណភាព និងអនុលោមភាពតាមគោលនយោបាយឥណទាន នីតិវិធី និងបញ្ហាផ្សេងៗទៀត ។

## បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៨

- នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរសេចក្តីណែនាំបន្ថែមពីការអនុវត្តប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ។ សេចក្តីប្រកាសនេះតម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុទាំងអស់ វាយតម្លៃឡើងវិញនូវហានិភ័យឥណទានដែលអាចកើតឡើង និងសាកល្បងលើអ៊ីមភែរមិន នាខែមិថុនា និងខែធ្នូ ឆ្នាំ២០១៨ ។
- បញ្ហាប្រឈមក្នុងវិស័យកសិកម្ម (ដំណាំមានតម្លៃទាប ដូចជា ស្រូវ ដំឡូងមី និងកៅស៊ូ) ដែលបានកើតឡើងក្នុងឆ្នាំ២០១៦ និងបន្តដល់ឆ្នាំ២០១៨ ។ តម្លៃដំណាំធ្លាក់ចុះទាប បានប៉ះពាល់សមត្ថភាពទូទាត់របស់កសិករជាច្រើន និងនាំឱ្យមានកំណើនកម្រិតហានិភ័យឥណទាន និងឥណទានមិនដំណើរការក្នុងវិស័យកសិកម្ម ១,២៨% និង ០,៩៣% ក្នុងឆ្នាំ២០១៦ និង ៣,០២% និង ២,៩៣% ក្នុងឆ្នាំ២០១៧ ។ ដើម្បីកាត់បន្ថយហានិភ័យនេះ BCC បានផ្តល់អនុសាសន៍ដល់ថ្នាក់គ្រប់គ្រងរបស់ធនាគារ ឱ្យបង្កើតយុទ្ធសាស្ត្រនានាសម្រាប់ការវាយតម្លៃការផ្តល់កម្ចីដល់វិស័យនេះ ក្នុងឆ្នាំ២០១៨ ។ យុទ្ធសាស្ត្រទាំងនោះរួមមាន ៖ ត្រូវពិនិត្យយ៉ាងដិតដល់ពីស្ថានភាព និងអភិវឌ្ឍន៍របទាសម្ព័ន្ធផ្តល់ប្រាក់កម្ចី ឬនីតិវិធីណែនាំស្តីពីការផ្តល់កម្ចីដល់វិស័យកសិកម្ម ដោយកំណត់ដែនកំណត់ត្រួតពិនិត្យ និងចាត់វិធានការដោះស្រាយ នៅពេលដិតមានបញ្ហាកើតឡើង ។ ជាលទ្ធផល កម្រិតហានិភ័យ និងឥណទានមិនដំណើរការ បានកាត់បន្ថយមកនៅត្រឹម ២,១៩% និង ១,៩៣% នាខែធ្នូ ឆ្នាំ២០១៨ ។

- BCC បានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មលើគោលនយោបាយឥណទានរបស់ក្រុមប្រឹក្សាភិបាល ។ ថ្នាក់គ្រប់គ្រងបានស្នើសុំផ្លាស់ប្តូររចនាសម្ព័ន្ធ នៃដំណើរការឥណទាន ។
- យោងតាមតម្រូវការនៃប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា និងការអនុវត្ត IFRS 9, BCC បានផ្តល់អនុសាសន៍ដោយកំណត់ពន្ធឥណទាន ជាមធ្យោបាយធ្វើសេចក្តីសម្រេចចិត្ត មុនដំណើរការផ្តល់ឥណទាន និងជាគន្លឹះមួយក្នុងការកំណត់ចំណាត់ថ្នាក់ និងគ្រប់គ្រងកម្រិតហានិភ័យឥណទានរបស់អតិថិជន ។

## សេចក្តីសន្និដ្ឋាន

ថ្វីបើឆ្នាំនេះមានការលំបាក ជាពិសេសការគិតគូរពីផលប៉ះពាល់នៃបទប្បញ្ញត្តិស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងការផ្តល់ឱនភាពក្តី ក៏គុណភាពនៃសមតុល្យឥណទាននៅតែស្ថិតក្រោមការគ្រប់គ្រង ជាមួយអនុបាតឥណទានមិនដំណើរការ ចំនួន ១,៧៤% ខណៈសមតុល្យឥណទានរបស់ធនាគារ អេស៊ីលីដា កើនឡើង ១៥,៤២% នាចុងឆ្នាំនេះ ។

ធនាគារ អេស៊ីលីដា បានអនុវត្តតាមច្បាប់គោលនយោបាយឥណទានពេញលេញទាំងអស់ពេញមួយឆ្នាំ ។

# គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន ( BITCO )

នេះជាឆ្នាំដំបូងដែលគណៈកម្មាធិការបានធ្វើការប្រតិបត្តិការ ពេញមួយមួយឆ្នាំ ។ គោលបំណងដើមរបស់គណៈកម្មាធិការមួយផ្នែក គឺដើម្បីបន្តការងារទាក់ទងនឹងបច្ចេកវិជ្ជាព័ត៌មាន ពីគណៈកម្មាធិការបណ្តោះអាសន្នមួយ ដែលបានបង្កើតឡើងកាលពីដើមឆ្នាំ២០១៧ ។ ក្រុមប្រឹក្សាភិបាលបានឃើញពីភាពចាំបាច់ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង លើការអភិវឌ្ឍបច្ចេកវិជ្ជាព័ត៌មាន និងបញ្ហាសន្តិសុខ ហើយគណៈកម្មាធិការ គឺជាបណ្តាញដ៏សំខាន់ដែលអាចសម្រេចបាន ។

គណៈកម្មាធិការទទួលខុសត្រូវ ត្រួតពិនិត្យការងាររបស់គណៈកម្មាធិការដឹកនាំការងារបច្ចេកវិជ្ជាព័ត៌មាន របស់ថ្នាក់គ្រប់គ្រង ដែលមានប្រធានជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា ។ ក្នុងឆ្នាំ២០១៨ ការងារផ្តោតលើការដំណើរការដែលបានអនុវត្ត ដើម្បីផ្តល់អនុសាសន៍នៃរបាយការណ៍ស្តីពីអភិបាលកិច្ចព័ត៌មានវិទ្យា និងសុវត្ថិភាពប្រព័ន្ធទិន្នន័យ ដោយក្រុមអ្នកជំនាញទេសជាន់ខ្ពស់ពីក្រុមហ៊ុនប្រឹក្សាយោបល់ឯករាជ ។ មានគម្រោងជាច្រើនកំពុងអភិវឌ្ឍ ដែលភាគច្រើននៃគម្រោងទាំងនោះ នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៩ ។ ក្រុមប្រឹក្សាភិបាលបានលើកទឹកចិត្តកម្លាំងចិត្ត និងសិល្បៈនៃការគ្រប់គ្រង និងបុគ្គលិកទាំងនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាន និងផ្នែកផ្សេងដើម្បីជំរុញគុណភាពទំនុកចិត្តនិងការច្នៃប្រឌិតថ្មីនៃបច្ចេកវិជ្ជាព័ត៌មានរបស់ធនាគារ ។

លទ្ធផលសម្រេចបានជាច្រើន រួមបញ្ចូលទាំងការលើកកម្ពស់នីតិវិធីផ្ទៃក្នុង ដើម្បីបង្កើនបទពិសោធន៍នៃការបម្រើអតិថិជន និងសុវត្ថិភាពប្រព័ន្ធទិន្នន័យ ព្រមទាំងពង្រីកពីសមត្ថភាពរបស់សេវាអេស៊ីលីដាទាន់ចិត្ត ។ គណៈកម្មាធិការត្រួតពិនិត្យ និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ។

## សមាជិក-សមាជិកា

| | |
|---|---|
| ១. លោក Ian S. Lydall ( ប្រធាន ) | អភិបាលឯករាជ |
| ២. កញ្ញា Heng Su Yin | អភិបាលមិនប្រតិបត្តិ |
| ៣. លោក Cornelius Obert | អភិបាលឯករាជ |

# គណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង ( BRENCO )

## វិសាលភាព និងគោលបំណង

គណៈកម្មាធិការបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីផ្តល់អនុសាសន៍ឯករាជ្យដល់ក្រុមប្រឹក្សាភិបាលនូវការងារដូចខាងក្រោម ៖

- ផ្តល់តម្លៃការដល់អភិបាល និងគណៈប្រតិបត្តិ និង
- ការជ្រើសរើសសមាសភាព ដែលសមរម្យសម្រាប់ក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ សម្រាប់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

## សមាជិក-សមាជិកា

| | |
|---|---|
| ១. លោក Ian S. Lydall ( ប្រធាន ) | អភិបាលឯករាជ |
| ២. លោក Marc Robert | អភិបាលមិនប្រតិបត្តិ |
| ៣. កញ្ញា Heng Su Yin | អភិបាលមិនប្រតិបត្តិ |
| ៤. លោក Yoshiaki Matsuoka ( បានលាលែងពីតំណែង នាថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ) | អភិបាលមិនប្រតិបត្តិ |
| ៥. លោក Ryoji Nishimura ( បានតែងតាំង នាថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ) | អភិបាលមិនប្រតិបត្តិ |

គណៈកម្មាធិការ អាចអញ្ជើញសមាជិក-សមាជិកានៃថ្នាក់គ្រប់គ្រង និងទីប្រឹក្សា ដែលមានជំនាញវិជ្ជាជីវៈនៅខាងក្រៅដើម្បីចូលរួមកិច្ចប្រជុំទាំងមូល ឬមួយផ្នែកដើម្បីផ្តល់ព័ត៌មានបន្ថែម និងការពន្យល់បកស្រាយតាមការដែលពួកគាត់គិតថាជាការចាំបាច់ ។

## បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៨

BRENCO ជួបប្រជុំគ្នា៤ដង ក្នុងឆ្នាំ២០១៨ គឺក្នុងខែមីនា ខែមិថុនា ខែកញ្ញា និងខែធ្នូ ។ កិច្ចដំណើរការសំខាន់ៗរួមមាន៖

- ត្រួតពិនិត្យសំណើរបស់ថ្នាក់គ្រប់គ្រងក្នុងការកែតម្រូវអតិផរណា និងការបង្កើនប្រាក់ខែគោល សម្រាប់ឆ្នាំ២០១៨ ។
- បានវាយតម្លៃពីលទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ និងប្រាក់រង្វាន់សម្រាប់ឆ្នាំ២០១៨ និងបានដាក់សំណើជូនទៅក្រុមប្រឹក្សាភិបាល ពីយន្តការលើកទឹកចិត្តសម្រាប់ ឆ្នាំ២០១៩ ។
- ពិនិត្យឡើងវិញនូវប្រាក់កម្រៃ និងការចំណាយផ្សេងៗ សម្រាប់ឆ្នាំ២០១៨ របស់ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលមិនប្រតិបត្តិ និងដាក់សំណើជូនទៅក្រុមប្រឹក្សាភិបាល និងភាគទុនិក ។ ប្រាក់កម្រៃសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលមិនប្រតិបត្តិត្រូវបានកំណត់ដោយភាគទុនិកដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងរបស់ភាគទុនិក ។ ពួកគាត់មិនមានប្រាក់សោធននិវត្តន៍ទេ ។ ក្នុងអំឡុងឆ្នាំ ២០១៨ ប្រាក់កម្រៃរបស់អភិបាលសរុបចំនួន ១,៣៤ លានដុល្លារអាមេរិក ត្រូវបានធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ផ្តល់ជូនដោយសារការចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។

- ពិនិត្យឡើងវិញនូវប្រាក់កម្រៃរបស់សមាជិក-សមាជិកា ដែលជាអភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងដាក់ជូនក្រុមប្រឹក្សាភិបាល និងភាគទុនិក ។
- ពិនិត្យឡើងវិញនូវផែនការតួនាទីរបស់ប្រធាននាយកប្រតិបត្តិ និងអនុប្រធាននាយកប្រតិបត្តិរបស់ធនាគារ ។ ហើយក៏បានពិនិត្យពីតួនាទីរបស់អគ្គនាយកក្រុមហ៊ុនបុត្រសម្ព័ន្ធផងដែរ ។

គណៈកម្មាធិការបានរៀបចំ នីតិវិធីបែងចែកអាសនៈរបស់សមាជិក-សមាជិកា ក្រុមប្រឹក្សាភិបាល និងបានអនុម័តដោយគណៈកម្មាធិការផ្តល់តម្លៃការ និងជ្រើសតាំង និងបានដាក់ជូនភាគទុនិក ។ នាខែឧសភា ឆ្នាំ២០១៨ កិច្ចប្រជុំភាគទុនិក បានអនុម័តនីតិវិធីនេះ ។

គណៈកម្មាធិការបានបញ្ចប់កម្រងសំណួរជាមូលដ្ឋាន សម្រាប់ការវាយតម្លៃប្រចាំឆ្នាំដោយខ្លួនឯង ពីលទ្ធផលសម្រេចបានរបស់គណៈកម្មាធិការ ។ គណៈកម្មាធិការ ក៏បានរៀបចំកម្រងសំណួរសម្រាប់ សមាជិក-សមាជិកា ក្រុមប្រឹក្សាភិបាល សម្រាប់បំពេញនូវការវាយតម្លៃប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាភិបាល ហើយបានសង្ខេបលទ្ធផលរួមជាមួយអនុសាសន៍សម្រាប់ដំណើរការទៅមុខ ។

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (BRMC)

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (BRMC) ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការបដិបត្តិតួនាទីប្រកបដោយប្រសិទ្ធភាព ទៅលើទំនួលខុសត្រូវ ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យមើលយ៉ាងទៀងទាត់នូវសមត្ថភាពរបស់ថ្នាក់គ្រប់គ្រង ដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យរបស់ធនាគារ ។

### សមាជិក-សមាជិកា

| | |
|---|---|
| ១. បណ្ឌិត Pieter Kooi (ប្រធាន) | អភិបាលឯករាជ |
| ២. លោកស្រី Femke Bos | អភិបាលមិនប្រតិបត្តិ |
| ៣. លោក Cornelius Obert | អភិបាលឯករាជ |
| ៤. លោក Ian S. Lydall | អភិបាលឯករាជ |

### បញ្ហាចម្បង និងសកម្មភាពក្នុងឆ្នាំ២០១៨

BRMC ជួបប្រជុំគ្នា ចំនួនបួនដងក្នុងឆ្នាំ២០១៨ គឺនៅខែមីនា មិថុនា កញ្ញា និងធ្នូ ។

- រាល់កិច្ចប្រជុំស្តីពីហានិភ័យទាំងមូល ត្រូវបានបង្ហាញដោយការិយាល័យគ្រប់គ្រងហានិភ័យ និងពិភាក្សាជាមួយសមាជិក-សមាជិកា និងអ្នកចូល រួម ដើម្បីធានាថា សូចនាករហានិភ័យសំខាន់ៗ ត្រូវបានអនុវត្តទៅតាមច្បាប់ ដែលបានកំណត់ដូចការអនុម័តដោយក្រុមប្រឹក្សាភិបាល ។
- បានវាយតម្លៃ និងបានពិភាក្សាអំពីហានិភ័យចម្បងៗ នាពេលអនាគតរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។
- ដំណើរការវិភាគហានិភ័យ ឱ្យបានប្រសើរឡើងបន្ថែមទៀត និងការធ្វើសេណារីយ៉ូ ស្រ្តេសតេស្ត ពីភាពតានតឹង ដែលអនុញ្ញាតឱ្យមានការកើតឡើងជាបន្តបន្ទាប់នៃហានិភ័យ រួមទាំងផលប៉ះពាល់នៃការរីករាលដាលសក្តានុពល ។
- វិភាគពីផលប៉ះពាល់នៃសេណារីយ៉ូហានិភ័យដែលអាចកើតមាននៅលើតារាងតុល្យការ របាយការណ៍លទ្ធផល និងសមាមាត្រដែលមានភាពប្រុងប្រយ័ត្ន ។
- ពិនិត្យឡើងវិញនូវហានិភ័យដែលអាចមានផលប៉ះពាល់អវិជ្ជមាន ដល់ស្តង់ដារខ្ពស់របស់អាជីវកម្ម ឆ្លោះទៅកេសហគមន៍ និងបរិស្ថាន ។
- បានពិភាក្សាអំពីយុទ្ធសាស្ត្រគ្រប់គ្រង ព្រឹត្តិការណ៍ហានិភ័យសក្តានុពលទាំងនោះ នៅក្នុងការប្រាក់រយៈពេលវែងរបស់ធនាគារ អេស៊ីលីដា និងអតិថិជនរបស់ខ្លួន ។
- បានពិនិត្យឡើងវិញ និងវិភាគលើការអភិវឌ្ឍ នៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃទៅលើឱកាស និងហានិភ័យ ។
- បានធ្វើការវាយតម្លៃប្រចាំឆ្នាំ ទាក់ទងនឹងការបំពេញការងាររបស់ខ្លួន ស្របតាមគោលបំណង តួនាទី និងភារកិច្ច របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដើម្បីធានាឱ្យបានប្រសិទ្ធភាពនៃការទទួលខុសត្រូវរបស់ខ្លួន ។
- គោលនយោបាយគ្រប់គ្រងហានិភ័យធនាគារ ត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយគណៈកម្មាធិការ ដើម្បីឱ្យធនាគារ អេស៊ីលីដា គ្រប់គ្រងហានិភ័យសំខាន់ឱ្យមានប្រសិទ្ធភាព ក៏ដូចជាដើម្បីធានាបាននូវការអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ។

# តួលេខបរិស្ថាន និងសង្គម

បរិមាណជាក់លាក់ធៀបនឹង FTE [១]

| | ២០១៨ | ២០១៧ | ២០១៦ | ២០១៥ | ២០១៤ |
|---|---|---|---|---|---|
| **សូចនាករលើការអនុវត្តផ្នែកបរិស្ថាន** | | | | | |
| **សម្ភារ** | | | | | |
| ក្រដាស ប្រើគិតជាគីឡូក្រាម /FTE | ១០,៦៤ | ១០,៤២ | ១០,៦៥ | ១១,៤៥ | ១៣,១៦ |
| **សំណល់** | | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម /FTE | ១,៧៩ | ២,១៥ | ១,៩២ | ១,៨០ | ១,៥២ |
| **ថាមពល** | | | | | |
| ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE | ១.៦៤៦,១៥ | ១.៦៧៣,៤៦ | ១.៦៦០,១៩ | ១.៣៩០,៥១ | ១.២៣០,៨០ |
| ប្រេងសាំង ប្រើគិតជាលីត្រ /FTE | ៣៨,២៣ | ៣៩,៧៦ | ៤០,០៨ | ៤០,៨៧ | ៤១,៣០ |
| ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE | ៤៤,៩៧ | ៤៩,០៤ | ៥១,៧០ | ៤៩,១១ | ៥៣,៨៩ |
| ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE | ១,១៣ | ១,២៧ | ១,៧៥ | ១,៣១ | ១,៥៥ |
| **ការបញ្ចេញចោលនូវឧស្ម័នកាបូនិក ( សមមូល គិតជាពាន់គីឡូក្រាម )[២]** | | | | | |
| ចរន្តអគ្គិសនី | ១១.១៤២ | ១១.៤៣០ | ១១.១៣៨ | ៨.៩២៩ | ៧.០៥០ |
| ប្រេងសាំង | ១.១២១ | ១.១៧៦ | ១.១៦៥ | ១.១៣៧ | ១.០២៥ |
| ប្រេងម៉ាស៊ូត | ១.៥១៩ | ១.៦៧២ | ១.៧៣២ | ១.៥៧៤ | ១.៥៤១ |
| **ទឹក** | | | | | |
| ទឹក ប្រើគិតជាម៉ែត្រគូប /FTE | ១៥,៥៤ | ១៥,៨៧ | ១៦,១៤ | ១៥,៨៤ | ១៩,១៦ |
| **ការធ្វើដំណើរ** | | | | | |
| ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE | ៤៨១,៨២ | ២៩៥,៩៨ | ២៣០,៣៥ | ២២៣,៩៦ | ៣៤៣,៤០ |
| ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE | ១.៨៩៤,៩០ | ១.៩៤១,៨៦ | ១.៨២៤,៨៩ | ១.៧៩១,៨៧ | ២.២១៦,៨៤ |
| **សូចនាករលើការអនុវត្តផ្នែកសង្គម** | | | | | |
| **ការបម្រើការងារ** | | | | | |
| ចំនួនបុគ្គលិក | ១២.១៧៧ | ១២.៤៥៦ | ១២.៣២៥ | ១១.៩២៦ | ១១.១៨២ |
| ប្រុស | ៧.២៧០ | ៧.៣៧០ | ៧.២៣៦ | ៧.០៥៩ | ៦.៦៦៤ |
| ស្រី | ៤.៩០៧ | ៥.០៨៦ | ៥.០៨៩ | ៤.៨៦៧ | ៤.៥១៨ |
| ចំនួនបុគ្គលិក ( FTE ) | ១២.៣០៧ | ១២.៤១៩ | ១២.១៩៧ | ១១.៦៧៥ | ១០.៤១៥ |
| **ការបណ្ដុះបណ្ដាល និងការអប់រំ** | | | | | |
| ការបណ្ដុះបណ្ដាល ( កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ ) | ៣.៨០១ | ៦.៥១៧ | ៤.៦៨៧ | ៥.៦២១ | ៣.៩២៩ |
| ការបណ្ដុះបណ្ដាលបុគ្គលិកចូលថ្មី ( កម្មវិធីដំបូង ) | ៥៤៩ | ១.១៧៩ | ១.៣៧៤ | ១.៧១៧ | ២.៣៦៨ |
| ការបណ្ដុះបណ្ដាលនិស្សិតនៅក្នុងស្រុក | ៦១០ | ១.០២៥ | ១.៤៣៣ | ១.២៤១ | ៩៦៩ |
| ការបណ្ដុះបណ្ដាលនិស្សិតនៅក្រៅប្រទេស | - | ៥ | ១ | ៥ | ២ |

[១] FTE ( Full Time Equivalent ): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ ។

[២] សមមូលឧស្ម័នកាបូនិក ត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol ។

# របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

## បេសកកម្មស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

*ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តរភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារ អេស៊ីលីដា ក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅ ដោយអនុវត្តតាមទស្សនៈគ្រឹះសំខាន់ទាំងបី "មនុស្ស ផែនដី និងប្រាក់ចំណេញ" ហើយធ្វើការកំណត់ជានិច្ចនូវសូចនាករសម្រាប់វាស់វែង និងរាយការណ៍អំពីសកម្មភាព និងផលប៉ះពាល់ទៅលើសង្គមនិងបរិស្ថាន ព្រមទាំងដើម្បីអនុវត្តនូវរចនាសម្ព័ន្ធរបាយការណ៍ ដោយផ្អែកជាចម្បងទៅលើការណែនាំក្នុងគំនិតផ្តួចផ្តើមនៃរបាយការណ៍ ពិភពលោក (GRI) ។ សូមមើលឧបសម្ព័ន្ធ GRI នៅទំព័រ ១១៥ ។*

## សមាសធាតុសំខាន់ៗនៃបេសកកម្មរបស់ ធនាគារ អេស៊ីលីដា ទាក់ទងនឹងនិរន្តរភាពបរិស្ថាន និងសង្គម

១. ផ្តល់ជាក្របខ័ណ្ឌសំខាន់នៅក្នុងគោលការណ៍ណែនាំ ដែលក្នុងនោះ ធនាគារ អេស៊ីលីដា អាចអនុវត្តតាមវិធីមួយដែលយើងអាចគ្រប់គ្រងរាល់ប្រតិបត្តិការដែល មានផលប៉ះពាល់ដល់បរិស្ថាន សង្គម និងសហគមន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

២. បន្តការបំពាក់ប្រព័ន្ធប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ក្នុងអគារការិយាល័យ ហើយគ្រប់គ្រងលើការប្រើប្រាស់ថាមពលឱ្យបានហ្មត់ចត់ នៅគ្រប់ទីកន្លែងដែលយើងមានប្រតិបត្តិការ ។

៣. អនុលោមទៅតាមច្បាប់សង្គមដែលយើងរស់នៅ និងធ្វើការយ៉ាងសកម្ម ដើម្បីផ្សព្វផ្សាយវប្បធម៌ដ៏ស្និទ្ធស្នាល ដែលមិនមែនតែចំពោះភាគទុនិក កម្មករនិយោជិត អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ គឺថែមទាំងគោរពចំពោះឯកត្តបុគ្គល នៅក្នុងសហគមន៍របស់យើងទៀតផង ។

៤. ទទួលស្គាល់ថា ការគាំទ្រចំពោះសហគមន៍មិនមែនគ្រាន់តែជាសីលធម៌ល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអាជីវកម្មមានលក្ខណៈល្អប្រសើរផងដែរ ពោលគឺមានភាពរឹងមាំ និងភាពរុងរឿង គឺត្រូវបំពេញឱ្យគ្នាទៅវិញទៅមក ។

## បរិស្ថាន

ធនាគារអេស៊ីលីដា បានចូលរួមអនុវត្តយ៉ាងពេញលេញ ស្របតាមសន្ធិសញ្ញាអន្តរជាតិ ដែលហាមឃាត់លើការផ្តល់ឥណទាន ឬគាំទ្រចំពោះសកម្មភាពផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ទាំងសកម្មភាពដែលប្រាសចាកពីសីលធម៌ ឬសកម្មភាពដែលធ្វើឱ្យមានការអន្តរាយចំពោះសិទ្ធិមនុស្ស ។ ដោយឡែក ធនាគារបានដាក់នូវគោលនយោបាយមួយចំនួន ដែលហាមដាច់ខាតរាល់សកម្មភាព ដែលពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំ ឬការរំលោភបំពានលើកំលាំងពលកម្មកុមារ ការធ្វើពាណិជ្ជកម្មខាងសព្វាវុធនិងគ្រឿងផ្ទុះ ល្បែងស៊ីសង បនល្បែង ផ្ទះបន ការជួញដូរ ឬផលិតផលសត្វព្រៃ (អនុសញ្ញាស្តីពីការជួញដូរជាអន្តរជាតិលើព្រៃឈើ និងសត្វព្រៃដែលជិតផុតពូជ) ដែលច្បាប់បានបញ្ញត្តិ ព្រមទាំងការផលិត ឬការធ្វើពាណិជ្ជកម្មលើវត្ថុធាតុដើមដែលមានជាតិវិទ្យុសកម្ម ឬជាតិគីមី ដែលមានគ្រោះថ្នាក់ក្នុងកម្រិតខ្ពស់ ។ ដំណើរការគ្រប់គ្រងយ៉ាងតឹងរ៉ឹង កំពុងត្រូវបានអនុវត្ត ដែលតម្រូវឱ្យអតិថិជនទាក់ទងមកកាន់បុគ្គលិកដើម្បីបញ្ជាក់ថា អាជីវកម្មរបស់ពួកគាត់ អនុលោមទៅតាមគោលការណ៍ទាំងនេះ ។

ធនាគារ អេស៊ីលីដា បានតែងតាំងមន្ត្រីទទួលបន្ទុកផ្នែកបរិស្ថានចំនួន ៥រូប ដែលទទួលខុសត្រូវទាំងស្រុងលើការងារហ្វឹកហ្វឺន និងវគ្គបំពាក់បំប៉ន ដើម្បីសម្របសម្រួលសកម្មភាពបរិស្ថាន និងត្រួតពិនិត្យលើប្រតិបត្តិការរបស់ធនាគារអេស៊ីលីដា ។

លើសពីនេះទៀត ធនាគារ អេស៊ីលីដា គាំទ្រថាមពលកើតឡើងវិញ ដោយផ្តល់ប្រាក់កម្ចីដល់អតិថិជនទាក់ទងនឹងថាមពលជីវឧស្ម័ន និងថាមពលពន្លឺព្រះអាទិត្យ ។

## សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

ក្នុងគោលបំណងបង្កើតខ្សែមូលដ្ឋាន សម្រាប់វាស់វែង កិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាន នៅក្នុងឆ្នាំ២០០៥ យើងបានបង្កើតប្រព័ន្ធឃ្លាំមើលចំពោះការប្រើប្រាស់ធនធាន ។ លទ្ធផលត្រូវបានបង្ហាញជាចំណុចចម្បងតាមលំដាប់លំដោយដូចខាងក្រោម ដើម្បីប្រើប្រាស់ជាគំរូសម្រាប់អនុវត្តនាពេលអនាគត ។

## ការប្រើប្រាស់ក្រដាស

នៅក្នុងឆ្នាំ២០១៨ ការប្រើប្រាស់ក្រដាសបានកើនឡើង ២,១១% សម្រាប់កម្មករនិយោជិតម្នាក់ៗបើប្រៀបធៀបនឹងឆ្នាំ២០១៧ ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារនៅតែបន្តជំរុញឱ្យបុគ្គលិកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្ទុកឯកសារនិងព័ត៌មានផ្សេងៗ ។

សំណល់ក្រដាសបានថយចុះ ១៦,៧៤% បើប្រៀបធៀបនឹងឆ្នាំ២០១៧ ។

| | ២០១៨ | ២០១៧ | ២០១៦ | ២០១៥ | ២០១៤ |
|---|---|---|---|---|---|
| **សម្ភារ** | | | | | |
| ក្រដាស ប្រើគិតជាគីឡូក្រាម /FTE | ១០,៦៤ | ១០,៤២ | ១០,៦៥ | ១១,៤៥ | ១៣,១៦ |
| **សំណល់** | | | | | |
| សំណល់ក្រដាស គិតជាគីឡូក្រាម /FTE | ១,៧៩ | ២,១៥ | ១,៩២ | ១,៨០ | ១,៥២ |

## ការប្រើប្រាស់ថាមពល

| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | | ១១.៤១៧.៤០០ | ៨.២៨៤.០៩០ | ៤៥.៨៧៥.១១៣ | ៣៣.៤៤២.៨៧១ |
| ការសងបំណុលបន្ទាប់បន្សំ | | (៤៣.០០០.០០០) | (៩.០០០.០០០) | (១៧២.៧៧៤.០០០) | (៣៦.៣៣៣.០០០) |
| លំហូរសាច់ប្រាក់ចេញសុទ្ធពីសកម្មភាពហិរញ្ញប្បទាន | | (១៥៨.៦១៨.៥៥៩) | ២៧០.៦៩៨.៥៨៦ | (៦៣៧.៣២៩.៣៧០) | ១.០៩២.៨១០.១៩២ |
| **(ការថយចុះ)/កំណើនសាច់ប្រាក់ និង សាច់ប្រាក់សមមូលសុទ្ធ** | | (១១៩.៦៩០.៨២៤) | ២៤៣.១៣១.៧៤២ | (៤៨០.៩១៧.៧៣១) | ៩៨១.៥២២.៨៤២ |
| សាច់ប្រាក់ និង សាច់ប្រាក់សមមូលដើមឆ្នាំ | | ១.៤០៦.៦០៩.៧៩៦ | ១.១៦៣.៤៧៨.០៥៤ | ៥.៦៧៨.៤៨៣.៧៤៦ | ៤.៦៩៦.៩៦០.៩០៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (២៦.៧២៥.៥៨៦) | - |
| **សាច់ប្រាក់ និង សាច់ប្រាក់សមមូលចុងឆ្នាំ** | ២៨ | ១.២៨៦.៩១៨.៩៧២ | ១.៤០៦.៦០៩.៧៩៦ | ៥.១៧០.៨៤០.៤២៩ | ៥.៦៧៨.៤៨៣.៧៤៦ |

ក្នុងអំឡុងឆ្នាំនេះ ធនាគារបានបង្វិលប្រាក់ចំណេញរក្សាទុកចំនួន ៣៦.៦៧៩.១៤៩ ដុល្លារអាមេរិក (២០១៧ ស្មើ ៥០.៧៨១.០៤៥ ដុល្លារអាមេរិក) ទៅជាដើមទុនដែលត្រូវបានដកចេញពីរបាយការណ៍លំហូរសាច់ប្រាក់ដោយឡែក ។

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៥៨ ដល់ទំព័រទី ១២៧ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

## ១. ព័ត៌មានទូទៅ

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") គឺជាធនាគារមហាជនទទួលខុសត្រូវមានកំណត់ ដែលបង្កើតឡើងក្រោមច្បាប់ព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជា ធនាគារឯកទេស ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិ នៃ កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជន សម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ។ អាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវបានធ្វើជាថ្មីទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ធនាគារធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត សម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាអាជីវករធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានលាតត្រដាង នៅក្នុងកំណត់សម្គាល់ ១១ នៃរបាយការណ៍ហិរញ្ញវត្ថុ ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ មានបុគ្គលិកចំនួន ១៣.៧២៨ នាក់ (២០១៧ ៖ ១៣.៨៥៩ នាក់) ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ ធនាគារជាតិ នៃ កម្ពុជា ដែលពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យ ដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ ។

ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

### (គ) រូបិយប័ណ្ណសម្រាប់ការវាស់វែង និងការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ។ ដោយសារធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថា ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណ មុខងាររបស់ធនាគារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ធនាគារ ។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ ។

### (ឃ) មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

#### (i) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម គឺរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ដែលបានរៀបចំសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ។ បុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនទាំងឡាយណាដែលសម្ព័ន្ធធនាគារ មានអំណាចក្នុងការគ្រប់គ្រងលើផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការរបស់ក្រុមហ៊ុននោះ ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់ក្រុមហ៊ុននោះ ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ត្រូវបានរួមបញ្ចូលគ្នា ដោយប្រើវិធីសាស្ត្រគណនេយ្យក្នុងការទិញ ។ យោងតាមវិធីសាស្ត្រគណនេយ្យ ក្នុងការទិញលទ្ធផលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានទិញ ឬបានលក់ក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានរួមបញ្ចូលចាប់ពីកាលបរិច្ឆេទទិញ ឬរហូតដល់កាលបរិច្ឆេទលក់ ។ នាកាលបរិច្ឆេទទិញ តម្លៃសមស្របនៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកំណត់រួចជាស្រេច ហើយតម្លៃទាំងនេះត្រូវបានឆ្លុះបញ្ចាំង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ។

ប្រតិបត្តិការអន្តរក្រុមហ៊ុន សមតុល្យនិងចំណេញឬខាតមិនទាន់ទទួលស្គាល់ដែលកើតមកពីប្រតិបត្តិការអន្តរ ក្រុមហ៊ុនត្រូវបានលុបចោល ហើយរបាយការណ៍ហិរញ្ញវត្ថុរួមឆ្លុះបញ្ចាំងតែប្រតិបត្តិការជាមួយភាគី ខាងក្រៅតែប៉ុណ្ណោះ ។ ការខាតបង់ដែលបណ្តាលមកពីប្រតិបត្តិការក្នុងសម្ព័ន្ធធនាគារ ដែលចង្អុលបង្ហាញនូវការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ នឹងត្រូវកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលរួម ។ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរៀបចំឡើងដោយប្រើប្រាស់គោលនយោបាយគណនេយ្យរួម ចំពោះប្រតិបត្តិការដូចគ្នា និងព្រឹត្តិការណ៍ផ្សេងៗនៅក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា ។

ចំណេញ ឬខាតពី ការលក់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាភាពលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងភាគហ៊ុនរបស់សម្ព័ន្ធធនាគារ លើទ្រព្យសកម្មសុទ្ធរបស់ខ្លួននាកាលបរិច្ឆេទលក់នោះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលរួម ។

#### (ii) ការផ្លាស់ប្តូរអត្ថប្រយោជន៍ម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយមិនផ្លាស់ប្តូរការគ្រប់គ្រង

ប្រតិបត្តិការជាមួយអប្បភាគភាគកម្ម ដែលមិនធ្វើឱ្យមានការខាតបង់ដល់ការគ្រប់គ្រង ត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន ដូចជាប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនក្នុងលក្ខណៈជាម្ចាស់ក្រុមហ៊ុនដែរ ។ លម្អៀងរវាងតម្លៃសមស្របនៃទឹកប្រាក់ដែលបានបង់ និងភាគហ៊ុនពាក់ព័ន្ធដែលបានទិញតាមតម្លៃយោង នៃទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកត់ត្រាក្នុងមូលធន ។ ចំណេញ ឬខាតពីការលក់អប្បភាគភាគកម្ម ក៏ត្រូវបានកត់ត្រាក្នុងមូលធនដែរ ។

(iii) ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានលុបចោលក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុរួម ហើយត្រូវបានរាយការណ៍ តាមថ្លៃដើមនៅក្នុងរបាយការណ៍ដោយឡែករបស់ធនាគារ ។ នៅពេលលក់ការវិនិយោគនោះចេញវិញ តម្លៃលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងតម្លៃយោងរបស់វា ត្រូវបានកត់ត្រាជាចំណេញ ឬខាតក្នុងការលក់ នៅក្នុងរបាយការណ៍លទ្ធផលរបស់ធនាគារ ។

## (ង) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយយោងស្តង់ដារគណនេយ្យនៃកម្ពុជាតម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មត ដែលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មត់ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងកាលបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែឡើងវិញ និងការិយបរិច្ឆេទ អនាគតដែលប៉ះពាល់ដោយការកែប្រែនេះ ។

ការប៉ាន់ស្មាននេះ មានការចូលរួមការវិនិច្ឆ័យខ្ពស់ និងស្មុគស្មាញ ឬតំបន់ដែលមានការសន្មត និងការប៉ាន់ស្មានដែលមាន សារៈសំខាន់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញខាងក្រោម ។

(i) ការខាតបង់លើការថយចុះតម្លៃនៃឥណទាន និង បុរេប្រទានអតិថិជន និងប្រាក់បញ្ញើនៅធនាគារនានា

សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និង សំវិធានធន ដែលតម្រូវដោយប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំ លេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអឹមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ឥណទាន និងបុរេប្រទាន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធន អាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) ។ ក្រុមប្រឹក្សាភិបាលជឿជាក់ថាអាយុកាលឥណទាន (តាមចំនួនថ្ងៃផុតកំណត់) ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់ឥណទាន មានភាពសមស្របដើម្បីកំណត់ភាពគ្រប់គ្រាន់នៃការខាតបង់ បណ្តាលមកពីការថយចុះតម្លៃនៃឥណទាន និងបុរេប្រទាន ដើម្បីឱ្យស្របតាមប្រកាសនេះ ។

(ii) ពន្ធ

ពន្ធត្រូវបានគណនា តាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ន នៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរ ពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយ លើចំនួនពន្ធនឹងធ្វើឡើងបន្ទាប់ពី អធិការកិច្ចរបស់អាជ្ញាធរពន្ធដារ ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួន ដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ សំវិធានធនពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ និង ពន្ធពន្យារនៅក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធបានធ្វើឡើង ។

(iii) អត្ថប្រយោជន៍ពេលចូលនិវត្ត

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ គឺអាស្រ័យទៅតាមចំនួននៃកត្តាផ្សេងៗដែលកំណត់ ដោយគណៈគ្រប់គ្រងដោយប្រើប្រាស់ការសន្មតមួយចំនួន ដូចជា អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាលាឈប់ពីការងារ និងអត្រាមរណៈ ។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ថ្លៃដើមសុទ្ធ សម្រាប់អត្ថប្រយោជន៍ពេលចូលនិវត្តរួមមាន អត្រាអប្បហារជាដើម ។ គណៈគ្រប់គ្រងបានប្រើអត្រាការប្រាក់សម្រាប់ប្រាក់បញ្ញើ មានកាលកំណត់រយៈពេល ៦ឆ្នាំ របស់ធនាគារ ជាអត្រាអប្បហារក្នុងការកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ ចេញប៉ាន់ស្មាន ដែលរំពឹងថា នឹងត្រូវទូទាត់កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ។ បម្រែបម្រួលណាមួយ ក្នុងការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃនៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ។

(iv) អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ គឺអាស្រ័យទៅតាមចំនួននៃកត្តាផ្សេងៗដែលកំណត់ ដោយគណៈគ្រប់គ្រងដោយប្រើប្រាស់ការសន្មតមួយចំនួន ដូចជា អត្រាលាឈប់ពីការងារ និងអត្រាមរណៈ ។ ការសន្មតដែល បានប្រើប្រាស់ក្នុងការកំណត់ថ្លៃដើមសុទ្ធ សម្រាប់ប្រាក់បំណាច់អតីតភាពការងារ រួមមាន អត្រាអប្បហារជាដើម ។

គណៈគ្រប់គ្រង បានប្រើអត្រាការប្រាក់សម្រាប់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៦ឆ្នាំ របស់ធនាគារ ជាអត្រាអប្បហារ ក្នុងការកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាន ដែលរំពឹងថានឹងត្រូវទូទាត់កាតព្វកិច្ច អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ ។

## (ច) ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យ បន្ទាប់ពីនេះ ។

យោងតាមសារាចរណែនាំលេខ ០៥៨ សហវ-កជគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ដែលចេញដោយក្រុមប្រឹក្សាជាតិ គណនេយ្យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុម័តឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ ។

# ៣. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយសម្ព័ន្ធធនាគារ និងធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម ។

## (ក) ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ ។ ចំណេញ និង ខាតពីការប្តូររូបិយប័ណ្ណដែលបណ្តាលមកពី ការទូទាត់តាមប្រតិបត្តិការបែបនេះ និង ពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរនាកាលបរិច្ឆេទរាយការណ៍ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

លទ្ធផលនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុនក្នុងសម្ព័ន្ធធនាគារទាំងអស់ (ដែលក្នុងចំណោមក្រុមហ៊ុនទាំងនោះ មិនមានក្រុមហ៊ុនដែលមានសេដ្ឋកិច្ចអតិ

ផលណាខ្ពស់) ដែលមានរូបិយប័ណ្ណគោល ខុសពីរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណសម្រាប់បង្ហាញ ដូចខាងក្រោម ៖

- ទ្រព្យសកម្ម និងបំណុលក្នុងតារាងតុល្យការនីមួយៗដែលបានបង្ហាញ ត្រូវបានកត់ត្រាប្តូរតាមអត្រានាថ្ងៃបិទបញ្ជី នាកាលបរិច្ឆេទតារាងតុល្យការ ។
- ដើមទុនក្នុងតារាងតុល្យការនីមួយៗ ដែលបានបង្ហាញ ត្រូវបានកត់ត្រាប្តូរតាមអត្រាថ្លៃដើមនាកាលបរិច្ឆេទវិញ ។
- ចំណូល និង ចំណាយក្នុងរបាយការណ៍លទ្ធផលនីមួយៗ ត្រូវបានកត់ត្រាប្តូរតាមអត្រាមធ្យមភាគ (លើកលែងតែអត្រាមធ្យមភាគនេះមិនមែនជាអត្រាបង្គរប៉ាន់ប្រមាណដ៏សមហេតុផលនាកាលបរិច្ឆេទប្រតិបត្តិការ ដែលក្នុងករណីនេះ ចំណូល និងចំណាយត្រូវបានកត់ត្រាប្តូរ តាមអត្រាកាលបរិច្ឆេទប្រតិបត្តិការវិញ ។
- រាល់លម្អៀងដែលបណ្តាលមកពីការប្តូរទាំងអស់ ត្រូវបានកត់ត្រាដាច់ដោយឡែកក្នុងគណនីមូលធន ។

## (ខ) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និង ធនាគាររួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូលការ ផ្តល់ឥណទាន និងគណនីត្រូវទទួលប្រាក់បញ្ញើគណនីត្រូវទទួលផ្សេងៗ និងត្រូវទូទាត់ផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យ ដោយឡែកពីគ្នា ។

## (គ) សាច់ប្រាក់ និង សាច់ប្រាក់សមមូល

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់គណនីសាច់ប្រាក់ និង សាច់ប្រាក់សមមូលរួមមានសមតុល្យ ដែលមានកាលកំណត់តិចជាង ឬស្មើបីខែ ក្នុងនោះរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានកម្រិតនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ។

## (ឃ) សមតុល្យនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើនៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា (រួមបញ្ចូលទាំងប្រាក់បញ្ញើតម្កល់តាមច្បាប់) ប្រាក់បញ្ញើនៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## (ង) ឥណទាន និង បុរេប្រទានអតិថិជន

ឥណទាន និង បុរេប្រទានអតិថិជនទាំងអស់ ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការតាមចំនួនទឹកប្រាក់ដើមដកចំនួន ដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានបាត់បង់ ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពជាក់ស្តែងអំពីលទ្ធភាពក្នុងការប្រមូលប្រាក់មកវិញ ។ ឥណទាន និង បុរេប្រទាន ដែលប្រមូលបានមកវិញ បន្ទាប់ពីបានជម្រះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសំវិធានធនដើម្បីកាត់បន្ថយ ចំនួនសំវិធានធនឥណទាននិងបុរេប្រទានបាត់បង់រួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## (ច) សំវិធានធនឥណទានបាត់បង់

សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និង សំវិធានធនដែលតម្រូវដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ឥណទាន និងបុរេប្រទាន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ហើយត្រូវកត់ត្រាសំវិធានធនអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វាដោយមិនគិតដល់ ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមាន ព័ត៌មានផ្សេងទៀតដែលចង្អុលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ ។

សំវិធានធនឥណទាន និងបុរេប្រទាន ត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីឥណទាន និងបុរេប្រទាន ។

តារាងខាងក្រោមនេះបង្ហាញពីចំណាត់ថ្នាក់ឥណទាន និងតម្រូវការសំវិធានធន ៖

| ចំណាត់ថ្នាក់ហ្វាស៊ីលីធី | ចំនួនថ្ងៃផុតកំណត់ | សំវិធានធន |
|---|---|---|
| រយៈពេលខ្លី | | |
| សំវិធានធនទូទៅ ៖ | | |
| ឥណទានធម្មតា | តិចជាង ១៥ ថ្ងៃ | ១% |
| សំវិធានធនជាក់លាក់ ៖ | | |
| ឥណទានឃ្លាំមើល | ១៥ ថ្ងៃ - ៣០ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៣១ ថ្ងៃ - ៦០ ថ្ងៃ | ២០% |
| ឥណទានសង្ស័យ | ៦១ ថ្ងៃ - ៩០ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៩១ ថ្ងៃ ឬ លើស | ១០០% |
| រយៈពេលវែង | | |
| សំវិធានធនទូទៅ ៖ | | |
| ឥណទានធម្មតា | តិចជាង ៣០ ថ្ងៃ | ១% |
| សំវិធានធនជាក់លាក់ ៖ | | |
| ឥណទានឃ្លាំមើល | ៣០ ថ្ងៃ - ៨៩ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៩០ ថ្ងៃ - ១៧៩ ថ្ងៃ | ២០% |
| ឥណទានសង្ស័យ | ១៨០ ថ្ងៃ - ៣៥៩ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៣៦០ ថ្ងៃ ឬ លើស | ១០០% |

## (ឆ) កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការអាជីវកម្មធម្មតា សម្ព័ន្ធធនាគារ និងធនាគារ ចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗ រួមមាន កិច្ចសន្យាឥណទាន លិខិតឥណទាន និងលិខិតធានាធនាគារផ្សេងៗ ។ គោលការណ៍គណនេយ្យ និងសំវិធានធន ត្រូវបានអនុវត្តទៅតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៧-៣៤៤ ប្រ.ក និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ក្នុងកំណត់សម្គាល់ ៣(ច) ខាងលើ ។

សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ ត្រូវបានបង្ហាញក្នុងខ្ទង់ដាច់ដោយឡែកមួយក្នុងតារាងតុល្យការ ។

## (ជ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដកសំវិធានធនឥណទានបាត់បង់ បើសិនមាន ។

## (ឈ) ទ្រព្យសម្បត្តិ និង បរិក្ខារ

ទ្រព្យសម្បត្តិ និង បរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់នានា ក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មទាំងនោះ ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោង នៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នៃទ្រព្យនោះនឹងហូរចូលមកក្នុងសម្ព័ន្ធធនាគារ និងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ ។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រា ជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង ។

ដីធ្លី និងការងារកំពុងដំណើរការមិនត្រូវបានធ្វើរំលស់ទេ ។ ការធ្វើរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាជាបន្ទុក នៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានរំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗ ។

| | ឆ្នាំ |
|---|---|
| ការកែលម្អលើដី | ៣ - ២០ |
| អគារ និង ការកែលម្អ | ៣ - ២០ |
| ការកែលម្អលើទ្រព្យជួល | ១ - ៣ |
| បរិក្ខារការិយាល័យ | ១ - ១០ |
| បរិក្ខារកុំព្យូទ័រ | ១ - ១០ |
| យានយន្ត | ៣ - ៥ |

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅ ត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន ។

ចំណេញ និង ខាតពីការលក់ជម្រះទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និង តម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ( ញ ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាម ថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់ ។ ថ្លៃដើមត្រូវបានធ្វើរំលស់លើអាយុកាលប៉ាន់ស្មានរបស់វាក្នុងរយៈពេល ៥ឆ្នាំ លើកលែងតែអាជ្ញាប័ណ្ណកម្មវិធីធនាគារ ដែលមានអាយុកាលប្រើប្រាស់ ១០ឆ្នាំ ។

ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង ។

## ( ដ ) ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណា ដែលមានអាយុកាលប្រើប្រាស់ មិនមានកាលកំណត់ គឺមិនត្រូវបានធ្វើរំលស់ទេ ប៉ុន្តែត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំរកការថយចុះតម្លៃរបស់វា ។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន ។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានគេកត់តាត្រាមចំនួនលម្អៀង រវាងតម្លៃនៅសល់នៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន ។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់ ។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុក ក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការ នោះបានកើតឡើង ។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល ទៅតាមទំហំតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់កាត់កងនឹងរំលស់ ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ។

## ( ឋ ) ការវិនិយោគផ្សេងៗ

ការវិនិយោគផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃ ដើមដកចេញតម្លៃឱនភាពដែលបណ្តាលមកពីការថយចុះតម្លៃ វិនិយោគ ដែលមានលក្ខណៈមិនបណ្តោះអាសន្ន ។

## ( ឌ ) ភតិសន្យា

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងផលកម្មសិទ្ធិលើទ្រព្យនេះ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ ។ ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា ។

## ( ឍ ) ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## ( ណ ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានរាយការណ៍តាមចំនួនប្រាក់ដើម ដែលនៅមិនទាន់ទូទាត់ ។ កម្រៃដែលបានចំណាយ ដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានកត់ត្រាជាចំណាយ និងកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលលើរយៈពេលនៃប្រាក់កម្ចីនោះ ។

## ( ត ) បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចផ្នែកកិច្ចសន្យា ក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅអង្គភាពមួយផ្សេងទៀត ឬត្រូវផ្តោះប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាមួយអង្គភាពមួយផ្សេងទៀត ក្រោមលក្ខខណ្ឌដែលមិនសូវអំណោយផលចំពោះធនាគារ ហើយប្រសិនបើមិនដូច្នោះទេវានឹងត្រូវបានកត់ត្រាជាមូលធន ។ បំណុលបន្ទាប់បន្សំដែលត្រូវអនុម័តដោយ ធនាគារជាតិ នៃ កម្ពុជា ត្រូវបានបញ្ចូលទៅក្នុងខ្ទង់ប្រភេទទីពីរ នៅក្នុងការគណនាមូលនិធិផ្ទាល់របស់ធនាគារ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា ។

បំណុលបន្ទាប់បន្សំ ត្រូវបានរាយការណ៍តាមចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់ ។

## ( ថ ) អត្ថប្រយោជន៍បុគ្គលិក

### *(i) មូលនិធិសោធននិវត្តន៍*

មកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារ និងបុត្រសម្ព័ន្ធ ផ្តល់មូលនិធិសោធននិវត្តន៍ទៅឲ្យបុគ្គលិក ។ មូលនិធិនេះត្រូវបានផ្តល់ឲ្យដោយផ្អែកលើប្រាក់ខែរបស់បុគ្គលិក ។ ការបែងចែកត្រូវបានសង្ខេបដូចខាងក្រោម ៖

| | ២០១៧ (មូលនិធិសោធននិវត្តន៍) | |
|---|---|---|
| | ក្រុមហ៊ុន | បុគ្គលិក |
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ១០% | ៥% |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | ១០% | ៥% |
| វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា | ១០% | ៥% |

សម្ព័ន្ធធនាគារ ផ្តល់អត្រាការប្រាក់សម្រាប់មូលនិធិសោធននិវត្តន៍សរុប ជាមួយអត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំ និងការបង្គរការប្រាក់ប្រចាំខែ នឹងបញ្ចូលក្នុងមូលនិធិសោធននិវត្តន៍ ។ មូលនិធិសោធននិវត្តន៍ ត្រូវទូទាត់ទៅឲ្យបុគ្គលិកនៅពេលដែលបុគ្គលិកឈប់ ។ ក្នុងខែមករា ឆ្នាំ២០១៨ សម្ព័ន្ធធនាគារ បានទូទាត់មូលនិធិសោធននិវត្តន៍ និងការប្រាក់លើមូលនិធិសោធន និវត្តន៍ដែលទទួលបានត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដល់បុគ្គលិកទាំងអស់ និងបញ្ចប់មូលនិធិសោធននិវត្តន៍នេះ ។

*(ii) ប្រាក់បំណាច់អតីតភាពការងារ*

យោងទៅតាមប្រកាស លេខ ៤៤៣ ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែធនាគារ អេស៊ីលីដា ឡាវ និង អេស៊ីលីដា មីយ៉ាន់ម៉ា នឹងផ្តល់ជូននិយោជិត នូវប្រាក់បំណាច់អតីតភាពការងារ ដូចខាងក្រោម ៖

- ប្រាក់បំណាច់អតីតភាពការងារបច្ចុប្បន្ន ៖ និយោជិតដែលបម្រើការចាប់ពី ១ ខែ ដល់ ៦ខែ (មិនរាប់បញ្ចូលរយៈពេលសាកល្បងការងារ) គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូ នឹងទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ៧,៥ ថ្ងៃ ។
- ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ៖ និយោជិតដែលបម្រើការក្រោមកិច្ចសន្យាមានថេរវេលាមិនកំណត់ ហើយបម្រើការចាប់ពី ១ខែ ដល់ ៦ខែ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងទទួលបានប្រាក់បំណាច់អតីតភាពការងារស្មើនឹង ៧,៥ ថ្ងៃ ហើយក្នុងករណីបម្រើការលើសពី ៦ខែ នឹងទទួលបាន ១៥ថ្ងៃ ។ ប្រាក់បំណាច់អតិបរមា មិនត្រូវលើសពី ៦ ខែ នៃប្រាក់ឈ្នួលសុទ្ធសាធ គិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលបានបង់ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវលើសពី ១៥៦ ថ្ងៃឡើយ ។

បំណុលប្រាក់បំណាច់នេះ ត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចត្រូវទូទាត់នាកាលបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្រ្តឯកតាឥណទានប៉ាន់ស្មាន ដើម្បីប៉ាន់ស្មានចំណាយចុងក្រោយដែលអាចនឹងត្រូវទូទាត់ ដោយសម្ព័ន្ធធនាគារ និងធនាគារ លើប្រាក់បំណាច់អតីតភាពការងារ ដែលនិយោជិតមានសិទ្ធិទទួលលើការ បម្រើការងារចាប់ពីឆ្នាំ ២០០៨ ដល់ ២០១៨ ។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកប្រាក់បំណាច់អតីតភាពការងារទៅតាមថេរវេលា ដែលត្រូវទូទាត់ប្រាក់បំណាច់នេះ ។ កាតព្វកិច្ចបំណុលកើតឡើងនៅពេលនិយោជិតបម្រើការងារដើម្បីទទួលបាននូវប្រាក់បំណាច់អតីតភាពការងារ ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថានឹងត្រូវទូទាត់ នៅកាលបរិច្ឆេទរាយការណ៍អនាគត ។

តម្លៃបច្ចុប្បន្ន ប្រាក់បំណាច់អតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារ ប្រាក់ដែលត្រូវទូទាត់ពេលអនាគត ហើយប្រើអត្រាការប្រាក់កម្ចីមានកាលកំណត់ចំនួន ៦ឆ្នាំ ។

*(iii) អត្ថប្រយោជន៍ពេលចូលនិវត្តន៍*

ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ លើកលែងតែ ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ផ្តល់ជូនបុគ្គលិកពេញសិទ្ធិរបស់ខ្លួន នូវអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលមិនមានមូលនិធិដាច់ដោយឡែក នៅពេលដែលពួកគាត់ដល់អាយុចូលនិវត្តន៍ ដូចខាងក្រោម ៖

- បុគ្គលិកដែលមានអតីតភាពការងារជាមួយ សម្ព័ន្ធធនាគារ និងធនាគារ ចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្ត នៅអាយុ ៥៨ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៦០ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សចំនួន ១២ខែ នៃប្រាក់បៀវត្សចុងក្រោយ ។
- បុគ្គលិកដែលមានអតីតភាពការងារជាមួយសម្ព័ន្ធធនាគារ និងធនាគារ ចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្ត មុននៅអាយុ ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៥៧ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សចំនួន ៦ខែ នៃប្រាក់បៀវត្សចុងក្រោយ ។

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តនេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ ហើយក៏មិនមានការប្រាក់ដែរ ។

បំណុលត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្រ្តឯកតាឥណទានប៉ាន់ស្មាន ដើម្បីប៉ាន់ប្រមាណនូវថ្លៃចំណាយចុងក្រោយបំផុត ដែលសម្ព័ន្ធធនាគារ និងធនាគារត្រូវចំណាយចំពោះ អត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបាន ជាថ្នូរនឹងការបម្រើការងាររបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងពេលកន្លងមក ។ សម្ព័ន្ធធនាគារ និងធនាគារ ចូលរួមផ្តល់វិភាគទានក្នុងរយៈពេលដែលមាន ការទូទាត់អត្ថប្រយោជន៍ពេលចូលនិវត្ត ។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបម្រើការងារដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលសម្ព័ន្ធធនាគារ និង ធនាគាររំពឹងថានឹងទូទាត់ក្នុងការិយបរិច្ឆេទ រាយការណ៍នាពេលអនាគត ។

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត ត្រូវបានកំណត់ដោយអប្បហារចំណាយត្រូវបង់ ប៉ាន់ស្មាននាពេលអនាគត ដោយយោងទៅតាមអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់រយៈពេលប្រាំមួយឆ្នាំរបស់ធនាគារ ។

ចំណេញ និងខាត ដែលកើតពីនិយ័តកម្មក្នុងគ្រាកន្លងមក និងពីបម្រែបម្រួលការសន្មតហានិភ័យ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ក្នុងការិយបរិច្ឆេទដែលមានប្រតិបត្តិការនោះកើតឡើង ។ ចំណាយទាក់ទិននឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ដើម្បីបែងចែកចំណាយទាំងនោះ លើរយៈពេលដែលបុគ្គលិកបម្រើការងារ ហើយមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ ។ ចំណាយលើការបម្រើការងារក្នុងអតីតកាលត្រូវបានកត់ត្រាភ្លាមៗ នៅក្នុងរបាយការណ៍លទ្ធផល ។

## (ទ) ទុនបម្រុងទូទៅ

ទុនបម្រុងទូទៅ ត្រូវបានរៀបចំសម្រាប់ទប់នឹងហានិភ័យហិរញ្ញវត្ថុទូទៅរបស់សម្ព័ន្ធធនាគារ ។ ក្រុមប្រឹក្សាភិបាល មានការប្រុងប្រយ័ត្នទៅលើការប្រើប្រាស់ និងការរក្សាទុកទុនបម្រុងទូទៅ ដោយការផ្ទេរពីប្រាក់ចំណេញរក្សាទុក ។

## (ធ) សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលសម្ព័ន្ធធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផល នៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន ។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញ តាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថា ត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗ នៃកាតព្វកិច្ចនោះ ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់ ។

## (ន) ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ និង ពន្ធពន្យារលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទរាយការណ៍ នៅក្នុងប្រទេសដែលសម្ព័ន្ធធនាគារ និងធនាគារ ធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ ។

ពន្ធពន្យារលើប្រាក់ចំណេញ ត្រូវបានធ្វើសំវិធានធន ដោយប្រើវិធីសាស្រ្តបំណុលលើលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលសម្រាប់ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងចំនួនដែលត្រូវបានប្រើប្រាស់ សម្រាប់គោលដៅពន្ធដារ ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវអនុវត្ត ចំពោះលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាកត់ត្រាត្រលប់មកវិញ ដោយផ្អែកលើច្បាប់ដែលបានអនុម័ត រួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទរាយការណ៍ ។ ពន្ធពន្យារទ្រព្យសកម្ម ត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងបំណុលពន្ធ ក្នុងឆ្នាំជាមួយនឹងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថា នឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់ ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយទៅតាមទំហំដែលទំនងជាមិនមានប្រាក់ចំណេញ ជាប់ពន្ធត្រូវបានកត់ត្រា ។

## (ប) ការទទួលស្គាល់ចំណូល

### *(i) ចំណូលការប្រាក់*

ចំណូលការប្រាក់បានមកពីឥណទាន និង បុរេប្រទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យ នៅធនាគារ ផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរលើកលែងតែមានការសង្ស័យគួរឱ្យបារម្ភចំពោះការប្រមូលប្រាក់មកវិញ ដែលក្នុង ករណីនេះការប្រាក់ត្រូវបានព្យួរសិន រហូតដល់ពេលទទួលបានសាច់ប្រាក់ជាក់ស្តែង ។ គោលការណ៍ក្នុងការព្យួរការប្រាក់ គឺអនុលោមស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការព្យួរការប្រាក់លើឥណទានមិនដំណើរការ និង សំវិធានធនឥណទាន បាត់បង់ ។

### *(ii) ចំណូលកម្រៃ និង ជើងសា*

ចំណូលកម្រៃ និងជើងសារួមមាន កម្រៃពីដំណើរការឥណទាន ចំណូលបានមកពីសេវាផ្ទេរប្រាក់ចេញចូល លិខិតធានាធនាគារ លិខិតឥណទាន កម្រៃសេវាអេធីអឹម សេវាឈ្មួញកណ្តាល និងសេវាផ្សេងៗទៀត ។

កម្រៃបានមកពីដំណើរការឥណទាន ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលលើរយៈពេលផ្តល់ឥណទាន និងបុរេប្រទាន ជូនអតិថិជន ។ កម្រៃពីដំណើរការឥណទាននៅសល់ ត្រូវបានបង្ហាញដោយកាត់កងពីឥណទាន និងបុរេប្រទានអតិថិជន ។ ចំណូលកម្រៃ និងជើងសាផ្សេងៗត្រូវបានកត់ត្រា នៅពេលដែលបានបំពេញសេវានោះជូនអតិថិជន ។

### *(iii) សេវាបណ្តុះបណ្តាល និង សេវាប្រឹក្សា*

សម្ព័ន្ធធនាគារកត់ត្រាប្រាក់ចំណូល នៅពេលដែលមានភាពប្រាកដថា នឹងមានអត្ថប្រយោជន៍សេដ្ឋកិច្ចហូរចូលមកក្នុង សម្ព័ន្ធធនាគារ ហើយចំនួនប្រាក់ចំណូលអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បាន ។ ប្រាក់ចំណូលពីសេវាបណ្តុះបណ្តាល និងសេវាប្រឹក្សា ត្រូវបានកត់ត្រានៅពេលបានផ្តល់សេវាជូនអតិថិជន ។

## (ផ) ចំណាយការប្រាក់

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី និង បំណុលបន្ទាប់បន្សំ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ ។

## (ព) ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ក្តីឬដោយប្រយោលក្តី ក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្ត លើភាគីមួយផ្សេងទៀតក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬប្រសិនបើធនាគារ និង ភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅក្រោម ឥទ្ធិពលរួមរបស់ក្រុមហ៊ុនមេតែមួយ ។ ភាគីពាក់ព័ន្ធ អាចជាឯកបុគ្គល ឬជាក្រុមហ៊ុន រួមទាំងសមាជិកគ្រួសារជិតដិតរបស់បុគ្គលនោះ ក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ ។

អនុលោមតាមច្បាប់ស្តីពីធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុភាគីពាក់ព័ន្ធត្រូវបានឱ្យនិយមន័យថា ជាភាគីទាំងឡាយណា ដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោល យ៉ាងហោចណាស់ ១០% នៃដើមទុនរបស់ធនាគារ ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គល ដែលមានតួនាទីក្នុងអភិបាលកិច្ចការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ។

# ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០០៧ របស់ធនាគារជាតិ នៃ កម្ពុជា តម្រូវឱ្យមានការប្តូរទៅជាប្រាក់រៀលចំពោះតារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍ លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការ ដែលផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា នាកាលបរិច្ឆេទរាយការណ៍ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០១៨ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ៖ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៣៧ រៀល) ។ តួលេខដែលត្រូវបានប្តូរនេះ មិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះ ជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ ។ តួលេខជាប្រាក់រៀលក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប្តូរមកពីប្រាក់ដុល្លារអាមេរិកតាមអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

## ៥. សាច់ប្រាក់ក្នុងដៃ

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សាច់ប្រាក់ក្នុងដៃ៖ | | | | | | | | |
| ប្រាក់ដុល្លារអាមេរិក | ៣០៧.៦២៧.៨៤៦ | ២២០.៤២៩.៣៤៧ | ១.២៣៦.០៤៨.៦៨៥ | ៨៨៩.៨៧៣.២៧៤ | ៣០៥.៥៨០.៤៦៧ | ២១៨.៥៣២.៨៨១ | ១.២២៧.៨២២.៣១៦ | ៨៨២.២១៧.២៤១ |
| ប្រាក់រៀល | ៧៤.០៤៦.១៦៣ | ៧៦.២១៣.២៦៣ | ២៩៧.៥១៧.៤៨៣ | ៣០៧.៦៧២.៩៤៣ | ៧៤.០៤១.៧៥៣ | ៧៦.២០៩.១៦៧ | ២៩៧.៤៩៩.៧៦៤ | ៣០៧.៦៥៦.៤០៧ |
| ប្រាក់បាតថៃ | ១៦.១៨០.១១៥ | ១៥.៤១៧.១៣៨ | ៦៥.០១១.៧០២ | ៦២.២៣៨.៩៨៦ | ១៤.៥១៤.៥២៣ | ១៣.៣៩៧.១២៤ | ៥៨.៣១៩.៣៥៣ | ៥៤.០៨៤.១៩០ |
| ប្រាក់អឺរ៉ូ | ១.៩១៩.៦៣១ | ១.៨៣៤.៨០០ | ៧.៧១៣.០៧៧ | ៧.៤០៧.០៨៨ | ១.៨០៤.០០២ | ១.៨០៤.៨០២ | ៧.២៤៨.៤៨០ | ៧.២៨៥.៩៨៦ |
| រូបិយប័ណ្ណផ្សេងៗ | ៨.០៩០.៩៤៨ | ៧.៨៤៩.៦៩៧ | ៣២.៥០៩.៤៣០ | ៣១.៦៨៩.២២៦ | ២.០៧១.៤៣៩ | ៩៣១.៧៥៦ | ៨.៣២៣.០៤២ | ៣.៧៦១.៤៩៨ |
| | ៤០៧.៨៦៤.៧០៣ | ៣២១.៧៤៤.២៤៥ | ១.៦៣៨.៨០០.៣៧៧ | ១.២៩៨.៨៨១.៥១៧ | ៣៩៨.០១២.១៨៤ | ៣១០.៨៧៥.៧៣០ | ១.៥៩៩.២១២.៩៥៥ | ១.២៥៥.០០៥.៣២២ |

## ៦. សមតុល្យនៅធនាគារកណ្តាល

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា ៖ | | | | | | | | |
| ទុនបម្រុងកាតព្វកិច្ច (ក) | ៤៩៨.៤៣០.៨៦១ | ៤៥៧.៤៥៣.៦៦៦ | ២.០០២.៦៩៥.២០០ | ១.៨៤៦.៧៤០.៤៥០ | ៤៩៨.៤៣០.៨៦១ | ៤៥៧.៤៥៣.៦៦៦ | ២.០០២.៦៩៥.២០០ | ១.៨៤៦.៧៤០.៤៥០ |
| គណនីចរន្ត | ៣០៤.៣២១.២៥៧ | ២៨០.៤៩៣.៣៥៦ | ១.២២២.៧៦២.៨១១ | ១.១៣២.៣៥១.៦៧៨ | ៣០៤.៣២១.២៥៧ | ២៨០.៤៩៣.៣៥៦ | ១.២២២.៧៦២.៨១១ | ១.១៣២.៣៥១.៦៧៨ |
| ប្រាក់តម្កល់ធានាលើដើមទុន (ខ) | ៣៩.៥២២.៤១១ | ៣៥.៨៥៤.៤៩៦ | ១៥៨.៨០១.០៤៧ | ១៤៤.៧៤៤.៦០០ | ៣៩.៥២២.៤១១ | ៣៥.៨៥៤.៤៩៦ | ១៥៨.៨០១.០៤៧ | ១៤៤.៧៤៤.៦០០ |
| មូលបត្រអាចជួញដូរបាន(NCD)(គ) | ៦១៩.៣០៦.៥២១ | ៧០៩.៥៩២.៨៩១ | ២.៤៨៨.៣៧៣.៦០១ | ២.៨៦៤.៦២៦.៥០១ | ៦១៩.៣០៦.៥២១ | ៧០៩.៥៩២.៨៩១ | ២.៤៨៨.៣៧៣.៦០១ | ២.៨៦៤.៦២៦.៥០១ |
| | ១.៤៦១.៥៨១.០៥០ | ១.៤៨៣.៣៩៤.៤០៩ | ៥.៨៧២.៦៣២.៦៥៩ | ៥.៩៨៨.៤៦៣.២២៩ | ១.៤៦១.៥៨១.០៥០ | ១.៤៨៣.៣៩៤.៤០៩ | ៥.៨៧២.៦៣២.៦៥៩ | ៥.៩៨៨.៤៦៣.២២៩ |
| សមតុល្យនៅធនាគារជាតិ ឡាវ ៖ | | | | | | | | |
| ទុនបម្រុងកាតព្វកិច្ច (ឃ) | ២.៣៧២.២៣៥ | ២.១៧៧.៤២៥ | ៩.៥៣១.៦៤០ | ៨.៧៩០.២៦៥ | - | - | - | - |
| គណនីចរន្ត | ៦.០១៦.៨៣២ | ៩.៥៦០.៨៨៧ | ២៤.១៧៥.៦៣១ | ៣៨.៥៩៧.៣០១ | - | - | - | - |
| ប្រាក់បញ្ញើមានកាលកំណត់ (ង) | ៦២១.៨១១ | ២.០០០.០០០ | ២.៤៩៨.៤៣៧ | ៨.០៧៤.០០០ | - | - | - | - |
| ប្រាក់តម្កល់ធានាលើដើមទុន (ច) | ៥៨៦ | ៦០៣ | ២.៣៥៥ | ២.៤៣៤ | - | - | - | - |
| | ៩.០១១.៤៦៤ | ១៣.៧៣៨.៩១៥ | ៣៦.២០៨.០៦៣ | ៥៥.៤៦៤.០០០ | - | - | - | - |
| សមតុល្យសរុបនៅធនាគារកណ្តាល - រយៈពេលខ្លី | ១.៤៧០.៥៩២.៥១៤ | ១.៤៩៧.១៣៣.៣២៤ | ៥.៩០៨.៨៤០.៧២១ | ៦.០៤៣.៩២៧.២២៩ | ១.៤៦១.៥៨១.០៥០ | ១.៤៨៣.៣៩៤.៤០៩ | ៥.៨៧២.៦៣២.៦៥៩ | ៥.៩៨៨.៤៦៣.២២៩ |

## (ក) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ចគឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា ៨% ចំពោះប្រាក់រៀល និង ១២,៥០% ចំពោះរូបិយប័ណ្ណផ្សេងៗ នៃប្រាក់បញ្ញើរបស់អតិថិជន ប្រាក់បញ្ញើរបស់ធនាគារអនិវាសនជន និងប្រាក់បញ្ញើគ្រឹះស្ថានហិរញ្ញវត្ថុ និង ប្រាក់កម្ចីអនិវាសនជន ។ យោងតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៨-២៨២ប្រ.ក. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរក្សាទុនបម្រុងកាតព្វកិច្ចមិនមានការប្រាក់ទេ ។

## (ខ) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវឱ្យធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីនៅធនាគារកណ្តាល ។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយប្រាក់តម្កល់នេះមិនសម្រាប់ប្រើក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ។

## (គ) មូលបត្រអាចជួញដូរបាន (NCD)

ធនាគារបានដាក់មូលបត្រអាចជួញដូរបាន ដែលមានទឹកប្រាក់ចំនួន ៥៩.៣០៦.៥២១ ដុល្លារអាមេរិក (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ៖ ៨.៧២៩.៣៧៨ ដុល្លារអាមេរិក) នៅធនាគារជាតិ នៃ កម្ពុជា ជាទ្រព្យដាក់បញ្ចាំសម្រាប់គណនីទូទាត់ ។ មូលបត្រអាចជួញដូរបានចំនួន ៥៦០.០០០.០០០ ដុល្លារអាមេរិកទៀតនៅធនាគារជាតិ នៃ កម្ពុជា សម្រាប់គោលបំណងរកចំណូលការប្រាក់ ។ មូលបត្រអាចជួញដូរបានមានរយៈពេលមិនលើសមួយឆ្នាំ ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ធនាគារមិនទាន់បានប្រើឥណទានវិបារូបន៍នេះនៅឡើយទេ ។

**(ឃ)** ចំនួននេះគឺជាទុនបម្រុងកាតព្វកិច្ចរបស់ ធនាគារ អេស៊ីលីដា ឡាវ ដែលបានរក្សាទុកនៅធនាគារជាតិ ឡាវ ដោយអនុលោមទៅតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ ឡាវ ។ ទុនបម្រុងកាតព្វកិច្ចនេះត្រូវបានគណនាតាមអត្រា ៥% នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយវត្ថុជាតិ និង ១០% នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយវត្ថុផ្សេងៗ ហើយទុនបម្រុងនេះមិនមានការប្រាក់ទេ ។

**(ង)** ចំនួននេះគឺជាប្រាក់តម្កល់ធានាលើដើមទុនរបស់ ធនាគារ អេស៊ីលីដា ឡាវ ដែលបានរក្សាទុកនៅធនាគារជាតិ ឡាវ ដោយអនុលោមទៅតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ ឡាវ ស្តីពី ប្រាក់តម្កល់ធានាលើដើមទុន ហើយប្រាក់តម្កល់នេះមិនមានការប្រាក់ទេ ។

**(ច)** ប្រាក់បញ្ញើមានកាលកំណត់ មានរយៈពេលមួយឆ្នាំ ។

## (ឆ) អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំនៃសមតុល្យនៅធនាគារកណ្តាលមានដូចខាងក្រោម ៖

| | ២០១៨ | ២០១៧ |
|---|---|---|
| គណនីចរន្ត | សូន្យ | សូន្យ |
| ទុនបម្រុងកាតព្វកិច្ច | ០,៧៧% - ១,០៥% | ០,៣៨% - ០,៧៨% |
| ប្រាក់បញ្ញើមានកាលកំណត់ | ១,០០% - ៣,០០% | ២,៣០% - ៣,២៥% |
| ប្រាក់តម្កល់ធានាលើដើមទុន | ០,៤៦% - ០,៦២% | ០,៣២% - ០,៣៦% |
| មូលបត្រអាចជួញដូរបាន | ០,២៦% - ១,៦៣% | ០,២៩% - ១,៦៣% |

# ៧. សមតុល្យនៅធនាគារផ្សេងៗ

## (ក) វិភាគតាមទីតាំង

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សមតុល្យនៅធនាគារក្នុងស្រុក | ១.១៨៣.៤៧៦ | ៦.១២៣.០១០ | ៤.៧៥៥.២០៦ | ២៤.៧១៨.៥៩១ | ៣០១.៤៩៩ | ៣.៣៦៤.៩២៧ | ១.២១១.៤២៣ | ១៣.៥៨៤.២១០ |
| សមតុល្យនៅធនាគារបរទេស | ២៥.៦៦៣.៣៣០ | ១១៤.១៣១.៩០៧ | ១០៣.១១៥.២៦០ | ៤៦០.៧៥០.៥០៩ | ២៤.២៨៤.០៣២ | ១១៨.៤៩៨.៥២២ | ៩៧.៥៧៣.២៤០ | ៤៧៨.៣៧៨.៥៣៤ |
| | ២៦.៨៤៦.៨០៦ | ១២០.២៥៤.៩១៧ | ១០៧.៨៧០.៤៦៦ | ៤៨៥.៤៦៩.១០០ | ២៤.៥៨៥.៥៣១ | ១២១.៨៦៣.៤៤៩ | ៩៨.៧៨៤.៦៦៣ | ៤៩១.៩៦២.៧៤៤ |
| សំវិធានធនតាមច្បាប់ (កំណត់សម្គាល់ ៨(ក)(i)) | (២៧៩.១១៤) | - | (១.១២១.៤៨០) | - | (២៤៥.៨៥៥) | - | (៩៨៧.៨៤៥) | - |
| | ២៦.៥៦៧.៦៩២ | ១២០.២៥៤.៩១៧ | ១០៦.៧៤៨.៩៨៦ | ៤៨៥.៤៦៩.១០០ | ២៤.៣៣៩.៦៧៦ | ១២១.៨៦៣.៤៤៩ | ៩៧.៧៩៦.៨១៨ | ៤៩១.៩៦២.៧៤៤ |

## (ខ) វិភាគតាមប្រភេទគណនី

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សមតុល្យនៅធនាគារក្នុងស្រុក៖ | | | | | | | | |
| គណនីចរន្ត | ៨៧២.២៣៥ | ៣.១២២.៩២២ | ៣.៥០៤.៦៤០ | ១២.៦០៧.២៣៦ | ៣០១.៤៩៩ | ៣៦៤.៩២៧ | ១.២១១.៤២៣ | ១.៤៧៣.២១០ |
| គណនីសន្សំ | ៣៣៦ | ៨៨ | ១.៣៥០ | ៣៥៥ | - | - | - | - |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ៣១០.៩០៥ | ៣.០០០.០០០ | ១.២៤៩.២១៦ | ១២.១១១.០០០ | - | ៣.០០០.០០០ | - | ១២.១១១.០០០ |
| សមតុល្យនៅធនាគារក្នុងស្រុកសរុប | ១.១៨៣.៤៧៦ | ៦.១២៣.០១០ | ៤.៧៥៥.២០៦ | ២៤.៧១៨.៥៩១ | ៣០១.៤៩៩ | ៣.៣៦៤.៩២៧ | ១.២១១.៤២៣ | ១៣.៥៨៤.២១០ |
| សមតុល្យនៅធនាគារបរទេស៖ | | | | | | | | |
| គណនីចរន្ត | ២៥.៣៧៣.០៨០ | ៧៨.៥៣២.៩២៤ | ១០១.៩៤៩.០៣៥ | ៣១៧.០៣៧.៤១៥ | ២៣.៩៩៣.៧៨២ | ៧៧.៨៩៩.៥៣៩ | ៩៦.៤០៧.០១៥ | ៣១៤.៤៨០.៤៤០ |
| គណនីសន្សំ | ២៩០.២៥០ | ៥៩៨.៩៨៣ | ១.១៦៦.២២៥ | ២.៤១៨.០៩៤ | ២៩០.២៥០ | ៥៩៨.៩៨៣ | ១.១៦៦.២២៥ | ២.៤១៨.០៩៤ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | - | ៣៥.០០០.០០០ | - | ១៤១.២៩៥.០០០ | - | ៤០.០០០.០០០ | - | ១៦១.៤៨០.០០០ |
| សមតុល្យនៅធនាគារបរទេសសរុប | ២៥.៦៦៣.៣៣០ | ១១៤.១៣១.៩០៧ | ១០៣.១១៥.២៦០ | ៤៦០.៧៥០.៥០៩ | ២៤.២៨៤.០៣២ | ១១៨.៤៩៨.៥២២ | ៩៧.៥៧៣.២៤០ | ៤៧៨.៣៧៨.៥៣៤ |
| | ២៦.៨៤៦.៨០៦ | ១២០.២៥៤.៩១៧ | ១០៧.៨៧០.៤៦៦ | ៤៨៥.៤៦៩.១០០ | ២៤.៥៨៥.៥៣១ | ១២១.៨៦៣.៤៤៩ | ៩៨.៧៨៤.៦៦៣ | ៤៩១.៩៦២.៧៤៤ |

រាល់គណនីប្រាក់បញ្ញើមានកាលកំណត់ទាំងអស់ មានរយៈពេលមួយឆ្នាំ ។

## (គ) អត្រាការប្រាក់

| | សម្ព័ន្ធធនាគារ | | ធនាគារ | |
|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| ធនាគារក្នុងស្រុក | 0,00% - ៨,២៥% | 0,00% - ៨,២៥% | 0,00% - ៣,00% | 0,00% - ៣,00% |
| ធនាគារក្រៅស្រុក | 0,00% - ៤,២0% | 0,00% - ៤,២0% | 0,00% - ៤,២0% | 0,00% - ៤,២0% |

# ៨. ឥណទាន និងបុរេប្រទានអតិថិជន

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ឥណទានពាណិជ្ជកម្ម | ២.៩៥៥.៤១៦.៧៨០ | ២.៥៣៨.៥៨៧.១៧៣ | ១១.៨៧៤.៨៦៤.៦២២ | ១០.២៤៨.២៧៦.៤១៧ | ២.៨២១.៥៨៧.៨៤៣ | ២.៣៩៣.៤៨៥.១០៣ | ១១.៣៣៧.១៣៩.៩៥១ | ៩.៦៦២.៤៩៩.៣៦១ |
| ឥណទានអចលនទ្រព្យ | ២០៣.៥៦៥.៧៦៤ | ២០៥.៥៣៥.៣៦៦ | ៨១៧.៩២៧.២៤០ | ៨២៩.៧៤៦.២៧៣ | ២០៣.៥៦៥.៧៦៤ | ២០៥.៥៣៥.៣៦៦ | ៨១៧.៩២៧.២៤០ | ៨២៩.៧៤៦.២៧៣ |
| ឥណទានកែលម្អគេហដ្ឋាន | ១០០.៧៦០.៧០៧ | ៧០.៣៥៧.៦៥៦ | ៤០៤.៨៥៦.៥២១ | ២៨៤.០៣៣.៨៥៧ | ១០០.៣១៥.៦៤៨ | ៧០.៣៥៧.៦៥៦ | ៤០៣.០៦៨.២៧៤ | ២៨៤.០៣៣.៨៥៧ |
| ឥណទានបុគ្គលិក | ១៣២.៦៧៣.៧២២ | ១១០.៣៧២.៩៥៨ | ៥៣៣.០៨៣.០១៥ | ៤៤៥.៥៧៥.៦៣១ | ១២៨.៩២៩.៧៥៣ | ១០៦.៩៨១.០១៨ | ៥១៨.០៣៩.៧៤៨ | ៤៣១.៨៨២.៣៧០ |
| ឥណទានបង្វិល | ៦៣.២៩៥.៦៤៧ | ១០៥.៧៦៥.៨៧០ | ២៥៤.៣២១.៩១០ | ៤២៦.៩៧៦.៨១៧ | ៦៣.២៩៥.៦៤៧ | ១០៥.៧៦៥.៨៧០ | ២៥៤.៣២១.៩១០ | ៤២៦.៩៧៦.៨១៧ |
| ឥណទានវិបារូបន៍ | ៦០.១៣៥.៩១៤ | ៤៦.៨៩៩.៧៩៤ | ២៤១.៦២៦.១០២ | ១៨៩.៣៣៤.៤៦៨ | ៦០.១៣៥.៩១៤ | ៤៦.៨៩៩.៧៩៤ | ២៤១.៦២៦.១០២ | ១៨៩.៣៣៤.៤៦៨ |
| ឥណទានអ្នកប្រើប្រាស់ | ១០៣.៥០៥.០៤៣ | ៧៦.៩៦២.៦២២ | ៤១៥.៨៨៣.២៦៣ | ៣១០.៦៩៨.១០៥ | ១០៣.៥០៥.០៤៣ | ៧៦.៩៦២.៦២២ | ៤១៥.៨៨៣.២៦៣ | ៣១០.៦៩៨.១០៥ |
| ឥណទានភាគីពាក់ព័ន្ធ (កំណត់សម្គាល់ ៣១(ខ.i)) | ៦.១៣៩.២៩៨ | ១៦.១៦៧.៥៨២ | ២៤.៦៦៧.៦៩៩ | ៦៥.២៦៨.៥២៩ | ៥.១៦៨.១៦៣ | ១៥.២៣២.២៣៦ | ២០.៧៦៥.៦៧៩ | ៦១.៤៩២.៥៣៧ |
| ឥណទានយានយន្ត | ២.០៦៦.៦០១ | ១.៣៣៨.៨៤១ | ៨.៣០៣.៦០៣ | ៥.៤០៤.៩០១ | ២.០៦៦.៦០១ | ១.៣៣៨.៨៤១ | ៨.៣០៣.៦០៣ | ៥.៤០៤.៩០១ |
| | ៣.៦២៧.៥៥៩.៤៧៦ | ៣.១៧១.៩៨៧.៨៦២ | ១៤.៥៧៥.៥៣៣.៩៧៥ | ១២.៨០៥.៣១៤.៩៩៨ | ៣.៤៨៨.៥៧០.៣៧៦ | ៣.០២២.៥៥៨.៥០៦ | ១៤.០១៧.០៧៥.៧៧០ | ១២.២០២.០៦៨.៦៨៩ |
| សំវិធានធនឥណទានបាត់បង់ | | | | | | | | |
| សំវិធានធនជាក់លាក់ | (៤៧.៧៣៤.៥៨២) | (២៩.៥៦៣.៤៩១) | (១៩១.៩៥៨.២៧០) | (១១៩.៣៤៧.៨១៣) | (៤៦.៦២៨.៤៧៧) | (២៩.១៦៤.៤៥៨) | (១៨៧.៣៥៣.២២១) | (១១៧.៧៣៦.៩១៧) |
| សំវិធានធនទូទៅ | (៣៥.៦០៥.៦៩៦) | (៣០.៨៧៣.៧៨៩) | (១៤៣.០៦៣.៦៨៧) | (១២៤.៦៣៧.៤៨៦) | (៣៤.២៤៤.២៧៩) | (២៩.៣៩៤.០០២) | (១៣៧.៥៩៣.៥១៣) | (១១៨.៦៦៣.៥៨៦) |
| | (៨៣.៣៤០.២៧៨) | (៦០.៤៣៧.២៨០) | (៣៣៥.០២១.៩៥៧) | (២៤៣.៩៨៥.២៩៩) | (៨០.៨៧២.៧៥៦) | (៥៨.៥៥៨.៤៦០) | (៣២៤.៩៤៦.៧៣៤) | (២៣៦.៤០០.៥០៣) |
| | ៣.៥៤៤.២១៩.១៩៨ | ៣.១១១.៥៥០.៥៨២ | ១៤.២៤០.៥១២.០១៨ | ១២.៥៦១.៣២៩.៦៩៩ | ៣.៤០៧.៦៩៧.៦២០ | ២.៩៦៤.០០០.០៤៦ | ១៣.៦៩២.១២៩.០៣៦ | ១១.៩៦៥.៦៦៨.១៨៦ |
| កម្រៃពីដំណើរការឥណទាននៅសល់ | (៣០.៥៨៥.៣៨៣) | (២៦.៣៣៥.៩៣១) | (១២២.៨៩២.០៦៩) | (១០៦.៣១៨.១៥៣) | (២៩.០២៨.៤០៥) | (២៤.១២៦.២៩០) | (១១៦.៦៣៦.១៣០) | (៩៧.៣៩៧.៨៣៣) |
| | ៣.៥១៣.៥៩៣.៨១៥ | ៣.០៨៥.២១៤.៦៥១ | ១៤.១១៧.៦១៩.៩៤៩ | ១២.៤៥៥.០១១.៥៤៦ | ៣.៣៧៨.៦៦៩.២១៥ | ២.៩៣៩.៨៧៣.៧៥៦ | ១៣.៥៧៥.៤៩២.៩០៦ | ១១.៨៦៨.២៧០.៣៥៣ |

## (ក) សំវិធានធនឥណទានបាត់បង់

(i) សំវិធានធនឥណទានបាត់បង់ដែលបានទទួលស្គាល់លើរបាយការណ៍លទ្ធផល ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សំវិធានធនឥណទានបាត់បង់ | ៤០.៤៣១.៩៩៦ | ៣៤.២៥០.៣២៤ | ១៦២.៤៥៥.៧៦០ | ១៣៨.២៦៨.៥៥៨ | ៣៩.១១០.៩៣៨ | ៣៣.២១៥.៦៤៩ | ១៥៧.១៤៧.៧៤៩ | ១៣៤.០៩១.៥៧៥ |
| សំវិធានធនតាមច្បាប់លើសមតុល្យនៅធនាគារផ្សេងៗ | ២៧៩.១១៤ | - | ១.១២១.៤៨០ | - | ២៤៥.៨៥៥ | - | ៩៨៧.៨៤៥ | - |
| | ៤០.៧១១.១១០ | ៣៤.២៥០.៣២៤ | ១៦៣.៥៧៧.២៤០ | ១៣៨.២៦៨.៥៥៨ | ៣៩.៣៥៦.៧៩៣ | ៣៣.២១៥.៦៤៩ | ១៥៨.១៣៥.៥៩៤ | ១៣៤.០៩១.៥៧៥ |

(ii) បម្រែបម្រួលសំវិធានធនឥណទានបាត់បង់មានដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សំវិធានធនដើមឆ្នាំ | ៦០.៤៣៧.២៨០ | ៣៩.៥៤៣.០៣២ | ២៤៣.៩៨៥.២៩៩ | ១៥៩.៦៣៥.២២០ | ៥៨.៥៥៨.៤៦០ | ៣៧.៨៤៣.៩៥១ | ២៣៦.៤០០.៥០៣ | ១៥២.៧៧៦.០៣១ |
| សំវិធានធនក្នុងឆ្នាំ | | | | | | | | |
| សំវិធានធនជាក់លាក់ | ៣៥.៦៥៦.៥៧៤ | ៣២.០៨៤.៦៧៦ | ១៤៣.២៦៨.១១៤ | ១២៩.៥២៩.៨៣៧ | ៣៤.២៨០.០១៤ | ៣១.៣០៥.៦៣៨ | ១៣៧.៧៣៧.០៩៦ | ១២៦.៣៨០.៨៦១ |
| សំវិធានធនទូទៅ | ៤.៧៧៥.៤២២ | ២.១៦៥.៦៤៨ | ១៩.១៨៧.៦៤៦ | ៨.៧៤២.៧២១ | ៤.៨៣០.៩២៤ | ១.៩១០.០១១ | ១៩.៤១០.៦៥៣ | ៧.៧១០.៧១៤ |
| | ៤០.៤៣១.៩៩៦ | ៣៤.២៥០.៣២៤ | ១៦២.៤៥៥.៧៦០ | ១៣៨.២៧២.៥៥៨ | ៣៩.១១០.៩៣៨ | ៣៣.២១៥.៦៤៩ | ១៥៧.១៤៧.៧៤៩ | ១៣៤.០៩១.៥៧៥ |
| សំវិធានធនបានជម្រះចេញពីបញ្ជីក្នុងឆ្នាំ | (១៧.៣៨១.៩៨៤) | (១៣.៣០២.០៤៦) | (៦៩.៨៤០.៤៦៦) | (៥៣.៧០០.៣៦០) | (១៦.៨០៨.០៥៥) | (១២.៥០៥.៩៣៨) | (៦៧.៥៣៤.៧៦៤) | (៥០.៤៨៦.៤៧២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | (១០៧.១០០) | (៥៤.០៣០) | (៤៣០.៣២៨) | (២១៨.១១៩) | ១១.៤១៣ | ៤.៧៩៨ | ៤៥.៨៥៧ | ១៩.៣៦៩ |
| លម្អៀងពីការផ្តោះប្តូរ | - | - | (១.១៩៨.៣០៨) | - | - | - | (១.១១២.៦១១) | - |
| សំវិធានធនចុងឆ្នាំ | ៨៣.៣៨០.២៧៨ | ៦០.៤៣៧.២៨០ | ៣៣៥.០២១.៩៥៧ | ២៤៣.៩៨៥.២៩៩ | ៨០.៨៧២.៧៥៦ | ៥៨.៥៥៨.៤៦០ | ៣២៤.៩៤៦.៧៣៤ | ២៣៦.៤០០.៥០៣ |

## (ខ) វិភាគតាមចំណាត់ថ្នាក់

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ឥណទានធម្មតា | | | | | | | | |
| មានការធានា | ៣.៥៣៧.១៦២.៤៥៦ | ៣.០៦២.១៩០.៥៤៥ | ១៤.២១២.៣១៨.៩០៩ | ១២.៣៦២.០៦៣.២២៨ | ៣.៤២៤.៤១៤.៦៥១ | ២.៩៣៦.៩០២.៨៤៨ | ១៣.៧៥៩.២៩៨.០៦៦ | ១១.៨៥៦.២៧៦.៧៩៧ |
| មិនមានការធានា | ២៣.៤០៧.១២៨ | ២៥.១៩៨.៣៦១ | ៩៤.០៥៩.៨៤០ | ១០១.៦៨៥.៤១៣ | ១៣.២១០ | ២.៤៩៧.៣៦៥ | ៥៣.០៧៨ | ១០.០៨១.៨៦៣ |
| ឥណទានឃ្លាំមើល | | | | | | | | |
| មានការធានា | ៤.០៨០.៥៧៧ | ១៦.៦៦៣.៤៥៦ | ១៦.៣៩៥.៧៥៨ | ៦៧.២៧០.៣៧២ | ៣.៥១៦.០៤១ | ១៦.២៧៦.៣៩៣ | ១៤.១២៧.៤៥៣ | ៦៥.៧០៧.៧៩៩ |
| មិនមានការធានា | ៤៧.០៦៣ | ១១១.៦៩៤ | ១៨៩.០៩៩ | ៤៥០.៩០៩ | ៣២ | ២៥.២៧ | ១២៩ | ១០២.០១៥ |
| ឥណទានក្រោមស្តង់ដារ | | | | | | | | |
| មានការធានា | ១០.២២៧.៤៣៦ | ៣៨.៥៩៣.៦៩១ | ៤១.០៩៣.៨៣៨ | ១៥៥.៨០២.៧៣១ | ៩.៤១០.៧៤៧ | ៣៨.២៣៤.៤៧៩ | ៣៧.៨១២.៣៨១ | ១៥៤.៣៥២.៩៥២ |
| មិនមានការធានា | ៤១.៣២៤ | ៤៨.៩១១ | ១៦៦.០៤០ | ១៩៧.៤៥៤ | ១៤៩ | ៤៨.៥៩៦ | ៥៩៩ | ១៩៦.១៩២ |
| ឥណទានសង្ស័យ | | | | | | | | |
| មានការធានា | ១៣.៩៦២.៨៦៤ | ១៥.៦៥៥.៦៧១ | ៥៦.១០២.៧៨៨ | ៦៣.២០១.៩៤៤ | ១៣.១៤៩.២១៧ | ១៥.០៤៦.២១៨ | ៥២.៨៣៣.៥៥៤ | ៦០.៧៤១.៩៨២ |
| មិនមានការធានា | ៣០.០៤១ | ៦៣.៣០៧ | ១២០.៧០៥ | ២៥៥.៥៧ | ២៤៤ | ៦៣.៣០៧ | ៩៨០ | ២៥៥.៥៧០ |
| ឥណទានបាត់បង់ | | | | | | | | |
| មានការធានា | ៣៨.២៧១.៨៤៦ | ១៣.៣៤៦.១២៥ | ១៥៣.៧៧៦.២៧៧ | ៥៣.៨៧៨.៣០៧ | ៣៨.០៦៥.១៦៤ | ១៣.៣៣៨.១៩៣ | ១៥២.៩៤៥.៨២៩ | ៥៣.៨៤៦.០៨៣ |
| មិនមានការធានា | ៣២៨.៧០១ | ១២៦.១០១ | ១.៣២០.៧២១ | ៥០៩.០៧០ | ៩២១ | ១២៥.៩៨៧ | ៣.៧០១ | ៥០៨.២០៦ |
| | ៣.៦២៧.៥៥៩.៤៧៦ | ៣.១៧១.៩៨៧.៨៦២ | ១៤.៥៧៥.៥៣៣.៩៧៥ | ១២.៨០៥.៣១៤.៩៩៨ | ៣.៤៨៨.៩៧០.៣៧៦ | ៣.០២២.៥៥៨.៥០៦ | ១៤.០១៧.០៧៥.៧៧០ | ១២.២០២.០៦៨.៦៨៩ |

## (គ) វិភាគតាមប្រភេទអាជីវកម្ម

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ការលក់ដុំ និង លក់រាយ | ១.៣១៩.២៣៤.៤១២ | ១.២៨១.៦៨៨.៤២០ | ៥.៣០០.៦៨៣.៨៦៧ | ៥.១៧៤.១៧៦.១៥២ | ១.៣០៧.៩៧៩.២០៤ | ១.២៧១.៧៥៥.១១៥ | ៥.២៥៥.៤៦០.៤៤២ | ៥.១៣៤.០៧៥.៣៩៩ |
| សេវាកម្ម | ៨៧៧.៤១៦.៥០៤ | ៦២៤.៩០០.៥៦០ | ៣.៥២៥.៤៥៩.៥១៣ | ២.៥២២.៧២៣.៥៦១ | ៨៤៨.៧៩៦.២២៨ | ៥៩៣.៩៣១.៩៨២ | ៣.៤១០.៤៦៣.២៤៤ | ២.៣៩៧.៧០៣.៤១១ |
| កសិកម្ម | ៦៤៦.៦៦២.៥៤៤ | ៥៩០.៧៩៥.៦៦០ | ២.៥៩៨.២៩០.១០២ | ២.៣៨៤.៦៧២.០៧៩ | ៦៣៧.៨១៤.៨៩៤ | ៥៧០.១០៩.១០៧ | ២.៥៦២.៧៤០.២៤៤ | ២.៣០១.៥៣០.៤៦៥ |
| ឥណទានគេហដ្ឋាន | ២០៤.៥១០.៧៨៧ | ២០៨.៧៨៧.៩៧០ | ៨២១.៧២៤.៣៨២ | ៨៤២.៨៧៧.០៣៥ | ២០៤.២១៥.២៣៦ | ២០៨.៥២៣.៨២៩ | ៨២០.៥៣៦.៨១៨ | ៨៤១.៨១០.៦៩៨ |
| ផលិតកម្ម | ១០៣.៦៨៨.៤៤២ | ១០០.៣៥៧.៦១៨ | ៤១៦.៦២០.១៦០ | ៤០៥.១៤៣.៧០៤ | ៩៦.៩៧១.៥៤២ | ៩៣.២០៦.៦៤៤ | ៣៨៩.៦៣១.៦៥៦ | ៣៧៦.២៧៥.២២២ |
| គ្រឹះស្ថានហិរញ្ញវត្ថុ | ៨.៩៣៦.៣២៧ | ១០.៤០០.០០០ | ៣៥.៩០៦.៦៦២ | ៤១.៩៨៤.៨០០ | ៨.៩៣៦.៣២៧ | ១០.៤០០.០០០ | ៣៥.៩០៦.៦៦២ | ៤១.៩៨៤.៨០០ |
| ឥណទានផ្សេងៗ | ៤៦៧.១១០.៤៦០ | ៣៦៥.០៥៧.៦៣៤ | ១.៨៧៦.៨៤៩.៨២៩ | ១.៤៧៣.៧៣៧.៦៦៧ | ៣៨៣.៨៥៦.៩៤៥ | ២៧៤.៦៣១.៨២៩ | ១.៥៤២.៣៣៣.២០៤ | ១.១០៨.៦៨៨.៦៩៤ |
| | ៣.៦២៧.៥៥៩.៤៧៦ | ៣.១៧១.៩៨៧.៨៦២ | ១៤.៥៧៥.៥៣៣.៩៧៥ | ១២.៨០៥.៣១៤.៩៩៨ | ៣.៤៨៨.៥៧០.៣៧៦ | ៣.០២២.៥៥៨.៥០៦ | ១៤.០១៧.០៧៥.៧៧០ | ១២.២០២.០៦៨.៦៨៩ |

## (ឃ) វិភាគតាមហានិភ័យឥណទាន

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ហានិភ័យតូច | ៣.៦២៧.៥៥៩.៤៧៦ | ៣.១៧១.៩៨៧.៨៦២ | ១៤.៥៧៥.៥៣៣.៩៧៥ | ១២.៨០៥.៣១៤.៩៩៨ | ៣.៤៨៨.៥៧០.៣៧៦ | ៣.០២២.៥៥៨.៥០៦ | ១៤.០១៧.០៧៥.៧៧០ | ១២.២០២.០៦៨.៦៨៩ |

ហានិភ័យធំត្រូវបានកំណត់និយមន័យដោយធនាគារកណ្តាល ថាជាហានិភ័យឥណទានទូទៅចំពោះអ្នកទទួលផលជាឯកត្តជន ដែលមានចំនួនលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ហានិភ័យនេះគឺមានចំនួនខ្ពស់ជាងឥណទាន ឬកិច្ចសន្យាដែលនៅមិនទាន់ទូទាត់ និង ឥណទានឬកិច្ចសន្យាដែលបានអនុម័តរួច ។

## (ង) វិភាគតាមកាលកំណត់ឥណទាន

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| មិនលើសពី១ឆ្នាំ | ១.០៤៧.២៤៤.៧០៧ | ១.០០០.៧៨៦.៤៣៣ | ៤.២០៧.៨២៩.២៣៣ | ៤.០៤០.១៧៤.៨២៩ | ៩៧៩.០៩២.០៩៤ | ៩២៤.៥៨៧.១២៤ | ៣.៩៣៣.៩៩២.០៣៤ | ៣.៧៣២.៥៥៨.២២០ |
- ក្រុមប្រឹក្សាភិបាលធ្វើការពិចារណាថា អ្នកគ្រប់គ្រងមានសិទ្ធិគ្រប់គ្រាន់ក្នុងការកែតម្រូវ ផ្លាស់ប្តូរតាមស្ថានភាពជាក់ស្តែង ឬ អភិវឌ្ឍផលិតផលដែលមានស្រាប់ ហើយនឹងខ្សែសង្វាក់ផលិតផល ប៉ុន្តែតម្រូវឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។
- ការទទួលខុសត្រូវប្រចាំថ្ងៃសម្រាប់ហានិភ័យឥណទាន គឺជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់នៃនាយកដ្ឋានឥណទាន ជាមួយអ្នកគ្រប់គ្រងសាខា និង ជាមួយភ្នាក់ងារឥណទានសាខា ។
- ហានិភ័យឥណទានគឺត្រូវបានវាស់វែងជាប្រចាំ ដោយគណនាការខាតបង់ដែលបានរំពឹងទុក ដែលអាចកើតមានឡើង ចំពោះអតិថិជនដែលខកខានសងត្រឡប់ ហានិភ័យក្នុងព្រឹត្តិការណ៍នៃការខកខានសង និង ភាពខ្លាំងនៃការខាតបង់ ដែលបានមកពីការខកខានសងរបស់អតិថិជន ដោយផ្អែកទៅលើពិន្ទុឥណទានសម្រាប់ការអនុវត្ត ។
- ក្រុមប្រឹក្សាភិបាលយល់ឃើញថា ហានិភ័យឥណទានគឺអាចរីករាលដាលដល់វិស័យផ្សេងៗទៀត ដូចជា (វិស័យពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ឧស្សាហកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ...) និងផលិតផលផ្សេងទៀត ដើម្បីជៀសវាងភាពមិនត្រឹមត្រូវទៅលើ ហានិភ័យវិស័យ ឬឧស្សាហកម្មជាក់លាក់មួយ ។
- ហានិភ័យជាប្រព័ន្ធ គឺជាការខូចខាតប្រព័ន្ធទាំងមូលនៃវិស័យហិរញ្ញវត្ថុ ។ ក្រុមប្រឹក្សាភិបាលតម្រូវថា ហានិភ័យឥណទានទៅលើដៃគូភាគីស្ថាប័នហិរញ្ញវត្ថុទាំងឡាយ គួរតែជាកម្មវត្ថុនៃការវាយតម្លៃដ៏ប្រុងប្រយ័ត្ន និង ត្រួតពិនិត្យដូចទៅនឹងទម្រង់នៃការផ្តល់កម្ចីឥណទានដទៃទៀត ហើយកម្រិតកំណត់ស្ថានភាពប្រុងប្រយ័ត្ន គួរតែត្រូវបានកំណត់ដើម្បីការពារធនាគារឱ្យ បានគ្រប់គ្រាន់ សម្រាប់ហានិភ័យជាប្រព័ន្ធ ។

### *កម្រិតកំណត់ស្ថានភាពនៃហានិភ័យឥណទាន*

កម្រិតកំណត់ស្ថានភាពលើផលិតផលឥណទាន គួរតែបង្កើតឡើងដោយគណៈកម្មាធិការគ្រប់គ្រងហានិភ័យនៃ ក្រុមប្រឹក្សាភិបាល និង មានការអនុម័តដោយក្រុមប្រឹក្សាភិបាល ។ កម្រិតកំណត់ស្ថានភាព គួរតែស្របទៅតាមកម្រិតហានិភ័យទទួលយក និងត្រូវបានគេកត់ត្រានៅក្នុងគោលការណ៍ឥណទានរបស់ធនាគារ ។

នាយកដ្ឋានគ្រប់គ្រងហានិភ័យត្រូវត្រួតពិនិត្យជាប្រចាំ ទៅលើរាល់កម្រិតកំណត់ស្ថានភាពដូចដែលបានកំណត់ហើយ អនុម័តដោយក្រុមប្រឹក្សាភិបាលនិងផ្តល់អនុសាសន៍ទៅលើការផ្លាស់ប្តូរផ្សេងៗដែលចាត់ទុកថាសមរម្យ ។

ដើម្បីរក្សាកំណើនឥណទាន ក្នុងមធ្យោបាយដ៏ប្រុងប្រយ័ត្ន និង សមហេតុផលក៏ដូចជាដើម្បីរក្សាគុណភាពសំពៀតឥណទាន ធនាគារបានដាក់កម្រិតកំណត់ផ្សេងៗទៅលើផលិតផលឥណទាន ដែលត្រូវអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួន ដូចខាងក្រោម ៖

- ទំហំហានិភ័យបើកចំហ (Open Exposure) ៖ ទំហំហានិភ័យបើកចំហ ត្រូវបានកំណត់ដូចជាសម្គាធឥណទានដែលមាន ហានិភ័យសរុបចែកជាមួយមូលនិធិទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ តែត្រូវតិចជាង ២៥% ។
- កម្រិតកំណត់ការផ្តល់ឥណទាន (Ceilings) ទៅកាន់វិស័យផ្សេងៗ និងដោយផលិតផលត្រូវដាក់ដែនកំណត់ទៅលើ ហានិភ័យប្រមូលផ្តុំ ។
- ទំហំហានិភ័យធំបំផុត (Maximum Exposure) សម្រាប់អតិថិជនម្នាក់ ឬក្រុមនៃអតិថិជន គឺអាចមានទំហំរហូតដល់ ៥% នៃមូលនិធិទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ ។
- ដៃគូភាគីស្ថាប័នហិរញ្ញវត្ថុនានា ។

### (ក) ការគ្រប់គ្រងហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាលបានបែងចែកការទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យទៅលើហានិភ័យឥណទាន ទៅគណៈកម្មាធិការឥណទាន ។ នាយកដ្ឋានឥណទានដាច់ដោយឡែកមួយ ដែលទទួលខុសត្រូវគ្រប់គ្រងហានិភ័យឥណទាន ត្រូវរាយការណ៍ទៅគណៈកម្មាធិការឥណទាន ដូចដែលមានចែងខាងក្រោម ៖

- ការបែងចែកតួនាទីដាច់ដោយឡែករវាងអ្នកដែលពាក់ព័ន្ធ ក្នុងការប្រាស្រ័យជាមួយអតិថិជន ដែលដាក់ពាក្យសុំខ្ចីឥណទាន និង អ្នកដែលពាក់ព័ន្ធក្នុងការអនុម័តឥណទាន ។
- ការបែងចែកតួនាទីដាច់ដោយឡែក រវាងអ្នកដែលពាក់ព័ន្ធក្នុងការប្រាស្រ័យជាមួយអតិថិជនដោយផ្ទាល់ និងអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងឥណទាន ។
- គោលការណ៍នៃការអនុម័តពីរលំដាប់ថ្នាក់ ដើម្បីធានាឱ្យមានតុល្យភាពនៃផលប្រយោជន៍របស់អតិថិជន និងគោលដៅនៃ ដំណើរការវាយតម្លៃហានិភ័យ ។
- ការរៀបចំឯកសារព្រមព្រៀងឱ្យទាន់ពេលវេលា និងពេញលេញជាមួយអតិថិជនរួមជាមួយព័ត៌មានដែលត្រូវការទាំងអស់ ដែលទាក់ទងនឹងការវាយតម្លៃនិងដំណើរការគ្រប់គ្រងឥណទាន ។
- ប្រព័ន្ធត្រួតពិនិត្យឥណទានត្រូវមានការប្រយ័ត្នប្រយែង គួបផ្សំនឹងការពិនិត្យសមាយិកភាពដែលអាចកំណត់សម្គាល់សញ្ញាណ ទាន់ពេលស្តីពីព័ត៌មាននៃការគ្រប់គ្រងហានិភ័យ ។
- ការត្រួតពិនិត្យដោយឯករាជ្យ ដើម្បីធានាឱ្យមាននូវអនុលោមភាពទៅតាមនីតិវិធី និងនិយ័តកម្ម ក្នុងដំណើរការឥណទាន និង ការតាមដានគុណភាពទាក់ទងនឹងហានិភ័យ និងការត្រួតពិនិត្យឥណទានឱ្យបានទាន់ពេលវេលា ។
- ធនាគារនឹងរក្សាឱ្យបានល្អនូវសមតុល្យឥណទានតាមវិស័យផ្សេងៗ ដូចជាវិស័យឧស្សាហកម្ម តំបន់ភូមិសាស្រ្ត រូបិយប័ណ្ណ និងទំហំឥណទាន ។

- ការវិភាគឥណទានធ្វើឡើងដោយផ្តោតសំខាន់លើសមត្ថភាព និងឆន្ទៈរបស់អតិថិជនក្នុងការសងឥណទាន តាមរយៈការវាយតម្លៃពីអត្តចរិត លំហូរសាច់ប្រាក់ និង ការអនុវត្តតាម green-lining methodology ។
- សំពៀតឥណទានសរុបរបស់ធនាគារដែលផ្តល់ឱ្យអតិថិជនម្នាក់ ឬអតិថិជនក្រុម (គោលការណ៍អ្នកខ្ចីតែមួយ) មិនត្រូវលើស ៥% នៃទ្រព្យសម្បត្តិសុទ្ធរបស់ធនាគារ ។"សំពៀតឥណទាន"(Exposure) គឺរួមមានបរិមាណសរុបនៃ (i) ចំនួនទឹកប្រាក់នៃទ្រព្យរបស់អ្នកខ្ចី ដែលអ្នកខ្ចីនោះជាកូនបំណុល (ii) ប្រាក់ដែលអ្នកខ្ចីជំពាក់ (ឥណទេយ្យ) តាមរយៈការផ្តល់ហិរញ្ញប្បទាន ឬឥណទានទៅឱ្យ ឬជំនួសឱ្យ បុគ្គលនោះ ដែលរួមមានដូចជា ការធានាបំណុលលិខិតឥណទាន និស្សន្ទវត្ថុ (derivatives) ។

## (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

សម្ព័ន្ធធនាគារ និងធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជនជាឯកត្តជន ឬសហគ្រាសនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។ សម្ព័ន្ធធនាគារ និង ធនាគារគ្រប់គ្រងកម្រិតហានិភ័យ និងផ្តោតការយកចិត្តទុកដាក់លើហានិភ័យឥណទាន នៅពេលដែលហានិភ័យត្រូវបានរកឃើញ ។ ហានិភ័យឥណទានធំត្រូវបានកំណត់និយមន័យដោយធនាគារជាតិ នៃកម្ពុជា ថាជាហានិភ័យឥណទានទូទៅជាមួយនឹង អត្ថគាហកឯកត្តជននីមួយៗដែលមានចំនួនលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធ ។

យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារជាតិ នៃ កម្ពុជា តម្រូវឱ្យធនាគាររក្សាឱ្យបានគ្រប់ ពេលវេលានូវអនុបាតអតិបរមាចំនួន ២០% រវាងហានិភ័យសរុបដែលចេញពីប្រតិបត្តិការជាមួយនឹងអត្ថគាហកជាឯកត្តជននីមួយៗ និង មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ហើយត្រូវរក្សាហានិភ័យឥណទានធំៗសរុបមិនត្រូវឱ្យលើស ៣០០% នៃមូលនិធិផ្ទាល់សុទ្ធឡើយ ។

សម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើនដើម្បីកាត់បន្ថយហានិភ័យឥណទាន ។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំលើឥណទាន និងបុរេប្រទាន អតិថិជន ដែលជាការអនុវត្តទូទៅ ។ សម្ព័ន្ធធនាគារ និងធនាគារអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកនូវចំណាត់ ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន ។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗដើម្បីធានាឥណទាន និងបុរេប្រទាន អតិថិជនមានដូចជា ៖

- វត្ថុបញ្ចាំជាទ្រព្យសម្បត្តិក្នុងលក្ខណៈជាលំនៅដ្ឋាន (មានដីធ្លី អគារ និង ទ្រព្យសម្បត្តិផ្សេងៗ)
- កម្រៃផ្សេងៗលើទ្រព្យសកម្មក្នុងអាជីវកម្ម ដូចជាដីធ្លី អគារ
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានកម្រិត ។

## (គ) គោលការណ៍សំវិធានធន និងការថយចុះតម្លៃ

សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយប្រកាសរបស់ ធនាគារ ជាតិ នៃ កម្ពុជា លេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុ ។ ហ្វាស៊ីលីធីផ្សេងៗរួមមាន ឥណទាន និងបុរេប្រទានផលិតផលហិរញ្ញវត្ថុ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វាដោយមិនគិតដល់ទ្រព្យសកម្មដែល ត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមានព័ត៌មានផ្សេងទៀតដែលចង្អុលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ ។

## (ឃ) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានឆ្លុះបញ្ចាំងនៅក្នុងតារាងតុល្យការ មានដូចជាហានិភ័យឥណទាន គឺស្មើនឹងតម្លៃយោងសុទ្ធ ឯលិខិតធានាហិរញ្ញវត្ថុ និងកិច្ចសន្យាទទួល គឺជាទំហំអតិបរមាដែលសម្ព័ន្ធធនាគារ និងធនាគារ នឹងទូទាត់ ប្រសិនបើលិខិតធានា ទាំងនោះត្រូវបានហៅត្រលប់មកវិញ ។ ចំណែកឯឥណទានដែលទាក់ទងនឹងកិច្ចសន្យា និងយថាភាព ដែលមិនអាចបដិសេធបានពេញ អាយុកាលនៃកិច្ចសន្យានោះ ជាទូទៅគឺស្មើនឹងតម្លៃទាំងស្រុងដែលមានក្នុងកិច្ចសន្យា ។

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ហានិភ័យឥណទានទាក់ទិននឹងទ្រព្យសកម្មក្នុងតារាងតុល្យការ ៖ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ២៦.៥៦៧.៦៩២ | ១២០.២៥៤.៩១៧ | ១០៦.៧៤៨.៩៨៦ | ៤៨៥.៤៦៩.១០០ | ២៤.៣៣៩.៦៧៦ | ១២១.៨៦៣.៤៤៩ | ៩៧.៧៩៦.៨១៨ | ៤៩១.៩៦២.៧៤៤ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៣.៥១៣.៥៩៣.៨១៥ | ៣.០៨៥.២១៤.៦៥១ | ១៤.១១៧.៦១៩.៩៤៩ | ១២.៤៥៥.០១១.៥៤៦ | ៣.៣៧៨.៦៦៩.២១៥ | ២.៩៣៩.៨៧៣.៧៥៦ | ១៣.៥៧៥.៤៩២.៩០៦ | ១១.៨៦៨.២៧០.៣៥៣ |
| ទ្រព្យសកម្មផ្សេងៗ | ៣៣.៧៣០.០១៤ | ៣១.៥៣៩.០៨៧ | ១៣៥.៥២៧.១៩៦ | ១២៧.៣២៣.២៩៤ | ៣២.៥១៤.៧៩៥ | ៣០.៤៦៥.៦៦៩ | ១៣០.៦៤៤.៤៤៦ | ១២២.៩៨៩.៩០៦ |
| | ៣.៥៧៣.៨៩១.៥២១ | ៣.២៣៧.០០៨.៦៥៥ | ១៤.៣៥៩.៨៩៦.១៣១ | ១៣.០៦៧.៨០៣.៩៤០ | ៣.៤៣៥.៥២៣.៦៨៦ | ៣.០៩២.២០២.៨៧៤ | ១៣.៨០៣.៩៣៤.១៧០ | ១២.៤៨៣.២២៣.០០៣ |
| ហានិភ័យឥណទានទាក់ទិននឹងទ្រព្យសកម្មក្រៅតារាងតុល្យការ ៖ | | | | | | | | |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ១០០.៤៦៧.៤៩៩ | ១១០.៦២១.៩១៣ | ៤០៣.៦៧៨.៤១១ | ៤៤៦.៥៨០.៦៦៣ | ១០០.៤៦៧.៤៩៩ | ១១០.៦២១.៩១៣ | ៤០៣.៦៧៨.៤១១ | ៤៤៦.៥៨០.៦៦៣ |
| លិខិតធានារបស់ធនាគារ | ៣៦.៧១០.៦៧៥ | ៤៦.៥៧៥.៩៥៤ | ១៤៧.៥០៣.៤៩២ | ១៨៨.០២៧.១២៦ | ៣៦.៦៨៤.៥១០ | ៤៦.៥៣៤.២៩៧ | ១៤៧.៣៩៨.៣៦១ | ១៨៧.៨៥៨.៩៥៧ |
| លិខិតឥណទាន | ៩.២៥០.៦៣៦ | ១៣.៤៦១.៨៨០ | ៣៧.១៦៩.០៥៥ | ៥៤.៣៤៥.៦១០ | ៩.២៥០.៦៣៦ | ១៣.៤៦១.៨៨០ | ៣៧.១៦៩.០៥៥ | ៥៤.៣៤៥.៦១០ |
| ការប្តូររូបិយប័ណ្ណនាពេលអនាគត | - | ៦៨៤.០៨៥ | - | ២.៧៦១.៦៥១ | - | ៦៨៤.០៨៥ | - | ២.៧៦១.៦៥១ |
| | ១៤៦.៤២៨.៨១០ | ១៧១.៣៤៣.៨៣២ | ៥៨៨.៣៥០.៩៥៨ | ៦៩១.៧១៥.០៥០ | ១៤៦.៤០២.៦៤៥ | ១៧១.៣០២.១៧៥ | ៥៨៨.២៤៥.៨២៧ | ៦៩១.៥៤៦.៨៨១ |
| ហានិភ័យឥណទានអតិបរមាសរុប | ៣.៧២០.៣២០.៣៣១ | ៣.៤០៨.៣៥២.៤៨៧ | ១៤.៩៤៨.២៤៧.០៨៩ | ១៣.៧៥៩.៥១៨.៩៩០ | ៣.៥៨១.៩២៦.៣៣១ | ៣.២៦៣.៥០៥.០៤៩ | ១៤.៣៩២.១៧៩.៩៩៧ | ១៣.១៧៤.៧៦៩.៨៨៤ |

តារាងខាងលើនេះបង្ហាញពីស្ថានភាពអាក្រក់បំផុតនៃហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដោយមិនគិតដល់វត្ថុបញ្ចាំឬការបង្កើនឥណទានផ្សេងទៀតទេ ។ ចំពោះទ្រព្យសកម្មក្នុង តារាងតុល្យការ ហានិភ័យដែលបានបង្ហាញខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ ។ ដូចបានបង្ហាញខាងលើ ៩៤,៤៤% នៃហានិភ័យ អតិបរមាសរុបចំពោះសម្ព័ន្ធធនាគារ និង ៩៤,៣៣% នៃហានិភ័យអតិបរមាសរុបចំពោះធនាគារ គឺកើតមកពីឥណទាន និងបុរេប្រទាន អតិថិជន (២០១៧៖ ៩០,៥២% ចំពោះសម្ព័ន្ធធនាគារ និង ៩០,០៨% ចំពោះធនាគារ) ។

គណៈគ្រប់គ្រងមានជំនឿថា ខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ ដែលបណ្តាលមកពីឥណទាន និងបុរេប្រទាន ឱ្យស្ថិតក្នុងកម្រិតអប្បបរមាតាមវិធីដូចខាងក្រោម ។ ប្រមាណ ៩៨,៥៩% នៃឥណទាន និង បុរេប្រទានរបស់ធនាគារ ត្រូវបានធានាដោយវត្ថុបញ្ចាំ ។ យោងតាមគោលការណ៍ឥណទាន ទំហំឥណទានមិនត្រូវលើស ៧៥% នៃតម្លៃលក់ចេញបាន់ស្មានរបស់វត្ថុបញ្ចាំនោះទេ ។

## (ង) ការប្រមូលផ្តុំទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងហានិភ័យឥណទាន

ការប្រមូលផ្តុំហានិភ័យឥណទានកើតឡើងនៅពេលមានភាគីដៃគូមួយចំនួន មានសកម្មភាពអាជីវកម្មប្រហាក់ប្រហែលគ្នា និងមានស្ថានភាពផ្នែកសេដ្ឋកិច្ចស្រដៀងគ្នា ដែលអាចបណ្តាលឱ្យពួកគេពុំមានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុលបាន នៅពេលដែលពួកគេជួបប្រទះនឹងផលប៉ះពាល់នៃបម្រែបម្រួលផ្នែកសេដ្ឋកិច្ច ឬលក្ខខណ្ឌផ្សេងៗទៀតស្រដៀងគ្នា ។

### (i) វិភាគតាមទីតាំងភូមិសាស្ត្រ

ការវិភាគអំពីការប្រមូលផ្តុំហានិភ័យឥណទាន (ដោយមិនគិតពីវត្ថុបញ្ចាំ ឬការពង្រឹងឥណទាន) ផ្អែកទៅតាមទីតាំងនៃប្រទេស ភាគីដៃគូ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានដូចខាងក្រោម ៖

**សម្ព័ន្ធធនាគារ**

| | កម្ពុជា | បារាំង | អាឡឺម៉ង់ | ឡាវ | សិង្ហបុរី | សហរដ្ឋអាមេរិក | មីយ៉ាន់ម៉ា | ប្រទេសផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ២៨៧.៨៣៧ | ៨៣៦.២៩០ | ១៣៨.២៩២ | ៨២៨.៨៣៧ | ៥២៧.៩៥២ | ១៧.៦០៣.៧២៩ | ៩០.៦៦៨ | ៦.២៥៣.៧៤៧ | ២៦.៥៦៧.៦៩២ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៣.៣៧៨.៦៦៩.២១៥ | - | - | ១១១.៩០៣.៩២៨ | - | - | ២៣.០២០.៦៧២ | - | ៣.៥១៣.៥៩៣.៨១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៣២.៣៨១.៣៤៥ | - | - | ៩៤២.៣២២ | - | - | ៤០៦.៣៤៧ | - | ៣៣.៧៣០.០១៤ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៣.៤១១.៣៣៨.៣៩៧ | ៨៣៦.២៩០ | ១៣៨.២៩២ | ១១៣.៦៧៥.១២៧ | ៥២៧.៩៥២ | ១៧.៦០៣.៧២៩ | ២៣.៥១៧.៩៨៧ | ៦.២៥៣.៧៤៧ | ៣.៥៧៣.៨៩១.៥២១ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១៣.៧០៦.៧៥៧.៦៧៩ | ៣.៣៦០.២១៣ | ៥៥៥.៦៥៧ | ៤៥៦.៧៤៦.៦៦០ | ២.១២១.៣១១ | ៧០.៧៣១.៧៨៣ | ៩៤.៤៩៥.២៧២ | ២៥.១២៧.៥៥៦ | ១៤.៣៥៩.៨៩៦.១៣១ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ៣.៣៦៤.៩២៦ | ១៥.៧៤៧.៤៣៧ | ៦៩០.៧៨០ | ៨៩៦.៦៦៩ | ២១.៣៥៧.៨១៣ | ៧០.៦៤៨.៥១៥ | ១.៩០៨.៥៨៣ | ៥.៦៤០.១៥៤ | ១២០.២៥៤.៩១៧ |
| ឥណទាន និង បុរេប្រទានអតិថិជន | ២.៩៣៩.៨៣៣.៧៥៦ | - | - | ១២៣.០១៧.៨៦១ | - | - | ២២.៣២៣.០៣៤ | - | ៣.០៨៥.១៧៤.៦៥១ |
| ទ្រព្យសកម្មផ្សេងៗ | ៣០.០៦៦.៧៤២ | - | - | ១.១១៩.៨០៥ | - | - | ៣៥៣.៥៤០ | - | ៣១.៥៣៩.០៨៧ |
| ត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៧ | ២.៩៧៣.៣០៥.៤២៤ | ១៥.៧៤៧.៤៣៧ | ៦៩០.៧៨០ | ១២៥.០៣៣.៣៣៥ | ២១.៣៥៧.៨១៣ | ៧០.៦៤៨.៥១៥ | ២៤.៥៨៥.១៥៧ | ៥.៦៤០.១៥៤ | ៣.២៣៧.០០៨.៦៥៥ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១២.០០៣.២៣៣.៩៩៣ | ៦៣.៥៧២.៦៦៥ | ២.៧៨៨.៦៧៩ | ៥០៤.៧៩៩.៥៧៣ | ៨៦.២២១.៤៩១ | ២៨៥.២០៨.០៥៥ | ៩៩.២៥០.២៧៩ | ២២.៧៦៩.៣០១ | ១៣.០៦៧.៨០៣.៩៤០ |

**ធនាគារ**

| | កម្ពុជា | បារាំង | អាឡឺម៉ង់ | ឡាវ | សិង្ហបុរី | សហរដ្ឋអាមេរិក | មីយ៉ាន់ម៉ា | ប្រទេសផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ២៩៨.៤៨៤ | ៨៣៦.២៩០ | ១៣៨.២៩២ | - | ៥២៧.៩៥២ | ១៧.៦០៣.៧២៩ | ៤៦.៦៨៦ | ៤.៨៨៨.២៤៣ | ២៤.៣៣៩.៦៧៦ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៣.៣៧៨.៦៦៩.២១៥ | - | - | - | - | - | - | - | ៣.៣៧៨.៦៦៩.២១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៣២.៣៤២.៧៦៩ | | | ៣២០ | | | ១៧១.៧០៦ | | ៣២.៥១៤.៧៩៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៣.៤១១.៣១០.៤៦៨ | ៨៣៦.២៩០ | ១៣៨.២៩២ | ៣២០ | ៥២៧.៩៥២ | ១៧.៦០៣.៧២៩ | ២១៨.៣៩២ | ៤.៨៨៨.២៤៣ | ៣.៤៣៥.៥២៣.៦៨៦ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១៣.៧០៦.៦៤៥.៤៦០ | ៣.៣៦០.២១៣ | ៥៥៥.៦៥៧ | ១.២៨៦ | ២.១២១.៣១១ | ៧០.៧៣១.៧៨៣ | ៨៧៧.៤៩៩ | ១៩.៦៤០.៩៦០ | ១៣.៨០៣.៩៣៤.១៧០ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ៣.៣៦៤.៩២៦ | ១៥.៧៤៧.៤៣៧ | ៦៩០.៧៨០ | ៥.០០០.០០០ | ២១.៣៥៧.៨១៣ | ៧០.៦៤៨.៥១៥ | ៤៧.១៦៨ | ៥.០០៦.៧៧០ | ១២១.៨៦៣.៤៤៩ |
| ឥណទាន និង បុរេប្រទានអតិថិជន | ២.៩៣៩.៨៧៣.៧៥៦ | - | - | - | - | - | - | - | ២.៩៣៩.៨៧៣.៧៥៦ |
| ទ្រព្យសកម្មផ្សេងៗ | ៣០.១២៤.០៣៥ | - | - | ២០២.៤២៤ | - | - | ១៣៩.២១០ | - | ៣០.៤៦៥.៦៦៩ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ២.៩៧៣.៣៦២.៧១៧ | ១៥.៧៤៧.៤៣៧ | ៦៩០.៧៨០ | ៥.២០២.៤២៤ | ២១.៣៥៧.៨១៣ | ៧០.៦៤៨.៥១៥ | ១៨៦.៣៧៨ | ៥.០០៦.៧៧០ | ៣.០៩២.២០២.៨៧៤ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១២.០០៣.៤៦៥.២៨៩ | ៦៣.៥៧២.៦៦៥ | ២.៧៨៨.៦៧៩ | ២១.០០២.៧៨៦ | ៨៦.២២១.៤៩១ | ២៨៥.២០៨.០៥៥ | ៧៥២.៤០៨ | ២០.២១២.៣៣០ | ១២.៤៨៣.២២៣.០០៣ |

(ii) វិភាគតាមប្រភេទអាជីវកម្ម

ការវិភាគអំពីការប្រមូលផ្តុំហានិភ័យឥណទាន (ដោយមិនគិតពីវត្ថុបញ្ចាំ ឬការពង្រឹងឥណទាន) ទៅតាមតម្លៃយោង គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ផ្អែកទៅតាមប្រភេទ អាជីវកម្មរបស់ភាគីដៃគូមានដូចខាងក្រោម ៖

សម្ព័ន្ធធនាគារ

| | គ្រឹះស្ថានហិរញ្ញវត្ថុ | ការលក់ដុំ និងលក់រាយ | សេវាកម្ម | គេហដ្ឋាន | ផលិតកម្ម | កសិកម្ម | អាជីវកម្មផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ២៦.៥៦៧.៦៩២ | - | - | - | - | - | - | ២៦.៥៦៧.៦៩២ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៨.៧៤៥.៤៥៦ | ១.២៧៣.២៥៧.២០៨ | ៨៤៨.៤២៩.២២៤ | ១៩៩.៧៩៤.៣០៣ | ១០១.៣៤៦.៩៥៨ | ៦២៥.០៨៥.៥៩៩ | ៤៥៦.៩៣៥.០៦៧ | ៣.៥១៣.៥៩៣.៨១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៦.៣៤៨.៥៧៧ | ៨.៨១២.៤៥៧ | ៥.៣១៧.១៦២ | ១.២៦៣.៨០៨ | ៦៦២.៧៦៨ | ៥.៤១៩.៥១៦ | ៥.៩០៥.៧២៦ | ៣៣.៧៣០.០១៤ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៤១.៦៦១.៧២៥ | ១.២៨២.០៦៩.៦៦៥ | ៨៥៣.៧៤៦.៣៨៦ | ២០១.០៥៨.១១១ | ១០២.០០៩.៧២៦ | ៦៣០.៥០៥.១១៥ | ៤៦២.៨៤០.៧៩៣ | ៣.៥៧៣.៨៩១.៥២១ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១៦៧.៣៩៦.៨១១ | ៥.១៥១.៣៥៥.៩១៤ | ៣.៤៣០.៣៥២.៩៧៩ | ៨០៧.៨៥១.៤៥០ | ៤០៩.៨៧៥.០៧៩ | ២.៥៣៣.៣៦៩.៥៥២ | ១.៨៥៩.៦៩៤.៣០៦ | ១៤.៣៥៩.៨៩៦.១៣១ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ១២០.២៥៤.៩១៧ | - | - | - | - | - | - | ១២០.២៥៤.៩១៧ |
| ឥណទាន និង បុរេប្រទានអតិថិជន | ១០.២១៥.៨៤៧ | ១.២៤៤.៨៨១.៣១៩ | ៦០៧.៣១៨.៤៣៨ | ២០៤.៥៧៥.១៨៦ | ៩៧.៣១៧.៣០៩ | ៥៦៤.១៦៧.៤៩៥ | ៣៥៦.៧៣៩.០៥៧ | ៣.០៨៥.២១៤.៦៥១ |
| ទ្រព្យសកម្មផ្សេងៗ | ៥.៧២៧.៩៣៥ | ៨.៩៤១.៦៥៨ | ៤.២៨៣.០៨៥ | ១.៣៥១.៧១១ | ៦៩៨.៥៥៧ | ៥.៦៣៣.២៤៥ | ៤.៩០៣.២៩៦ | ៣១.៥៣៩.០៨៧ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ១៣៦.១៩៨.៦៩៩ | ១.២៥៣.៨២២.៩៧៧ | ៦១១.៦០១.៥២៣ | ២០៥.៩២៦.៨៩៧ | ៩៨.០១៥.៨៦៦ | ៥៦៩.៨០០.៧៤០ | ៣៦១.៦៤២.៣៥៣ | ៣.២៣៧.០០៨.៦៥៥ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ៥៤៩.៨៣២.៥៣៣ | ៥.០៦១.៦៨៣.៣៥៨ | ២.៤៦៩.០៣៥.៣៤៨ | ៨៣១.៣២៦.៨៤៣ | ៣៩៥.៦៩០.០៥១ | ២.៣០០.២៨៥.៥៨៧ | ១.៤៥៩.៩៥០.១៨០ | ១៣.០៦៧.៨០៣.៩៤០ |

ធនាគារ

| | គ្រឹះស្ថានហិរញ្ញវត្ថុ | ការលក់ដុំ និងលក់រាយ | សេវាកម្ម | គេហដ្ឋាន | ផលិតកម្ម | កសិកម្ម | អាជីវកម្មផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ២៤.៣៣៩.៦៧៦ | - | - | - | - | - | - | ២៤.៣៣៩.៦៧៦ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៨.៧៤៥.៤៥៦ | ១.២៦២.៣៨៨.៦៨០ | ៨២០.៦៣៦.៧០០ | ១៩៩.៥០៧.០៨២ | ៩៤.៨២៤.៦២២ | ៦១៦.៥៣៨.២៤១ | ៣៧៦.០២៨.៤៣៤ | ៣.៣៧៨.៦៦៩.២១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៦.៤៩១.៦៣៩ | ៨.៦៣៩.៦៧៥ | ៥.០៣៥.៤៣២ | ១.២៦១.២១៤ | ៥៩៥.៥៩៩ | ៥.២៦០.៨៨១ | ៥.២៣០.៣៥៥ | ៣២.៥១៤.៧៩៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៣៩.៥៧៦.៧៧១ | ១.២៧១.០២៨.៣៥៥ | ៨២៥.៦៧២.១៣២ | ២០០.៧៦៨.២៩៦ | ៩៥.៤២០.២២១ | ៦២១.៧៩៩.១២២ | ៣៨១.២៥៨.៧៨៩ | ៣.៤៣៥.៥២៣.៦៨៦ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ១៥៩.០១៩.៤៦៦ | ៥.១០៦.៩៩១.៩៣០ | ៣.៣១៧.៥៥០.៦២៦ | ៨០៦.៦៨៧.០១៣ | ៣៨៣.៣៩៨.៤៤៨ | ២.៤៩៨.៣៨៨.៨៧២ | ១.៥៣១.៨៩៧.៨១៥ | ១៣.៨០៣.៩៣៤.១៧០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | | | | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ១២១.៨៦៣.៤៤៩ | - | - | - | - | - | - | ១២១.៨៦៣.៤៤៩ |
| ឥណទាន និង បុរេប្រទានអតិថិជន | ១០.២១៥.៨៤៧ | ១.២៣៥.១៩៦.៣៩៩ | ៥៧៧.២០៤.៩៤៨ | ២០៤.៣១៨.៦២៣ | ៩០.៣៦៥.០៣៥ | ៥៥៣.៧១៥.៩០៦ | ២៦៨.៩០៦.៩៩៨ | ២.៩៣៩.៨៧៣.៧៥៦ |
| ទ្រព្យសកម្មផ្សេងៗ | ៥.៩២៧.២៤១ | ៨.៧៨៥.៩៤០ | ៤.០០១.៩៤១ | ១.៣៤៩.៥៥១ | ៦៣៤.២៧២ | ៥.៤៨៦.៥៣៨ | ៤.២៨០.១៨៦ | ៣០.៤៦៥.៦៦៩ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ១៣៨.០០៦.៥៣៧ | ១.២៤៣.៩៨២.៣៣៩ | ៥៨១.២០៦.៨៨៩ | ២០៥.៦៦៨.១៧៤ | ៩០.៩៩៩.៣០៧ | ៥៥៩.២០២.៤៤៤ | ២៧៣.១៨៧.១៨៤ | ៣.០៩២.២០២.៨៧៤ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | ៥៥៧.១៣២.៣៩០ | ៥.០២១.៧៥៤.៨៩៣ | ២.៣៤៦.៣៣២.២១១ | ៨៣០.២៨២.៤១៨ | ៣៦៧.៣៦៤.២០២ | ២.២៥៧.៥០០.២៦៦ | ១.១០២.៨៥៦.៦៦៣ | ១២.៤៨៣.២២៣.០០៣ |

## (ច) ឥណទាន និងបុរេប្រទានដែលបានរៀបចំឡើងវិញ

សកម្មភាពក្នុងការរៀបចំឥណទានឡើងវិញ រួមមានការរៀបចំក្នុងការពន្យារពេលសងប្រាក់ ការកែប្រែ និងការផ្អាកការ សងប្រាក់ជាដើម ។ យោងតាមការរៀបចំឡើងវិញនេះ ឥណទានត្រូវបានរក្សាទុកក្នុងចំណាត់ថ្នាក់ដដែល លុះត្រាតែមានភស្តុតាងជាក់ស្តែង បញ្ជាក់ពីភាពប្រសើរឡើងនៃលក្ខខណ្ឌហិរញ្ញវត្ថុរបស់អតិថិជន ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ធនាគារបានរៀបចំឥណទាន និងបុរេប្រទានឡើងវិញ ដែលមានទឹកប្រាក់ចំនួន ១០.២០៩.០៥៣ ដុល្លារអាមេរិក ក្នុងនោះទឹកប្រាក់ចំនួន ៨.០១៥.២៦៤ ដុល្លារអាមេរិក ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានដំណើរការ និងទឹកប្រាក់ចំនួន ២.១៩៣.៧៨៩ ដុល្លារអាមេរិកទៀត ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានមិនដំណើរការ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ សម្ព័ន្ធធនាគារ និងធនាគារ បានរៀបចំឥណទាន និងបុរេប្រទានឡើងវិញ ដែលមានទឹកប្រាក់ចំនួន ៧.៥៤៦.៤៤១ ដុល្លារអាមេរិក ដែលក្នុងនោះទឹកប្រាក់ចំនួន ២.៦០២.៩១៣ ដុល្លារអាមេរិក ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានដំណើរការ ហើយទឹកប្រាក់ចំនួន ៤.៩៤៣.៥២៨ ដុល្លារអាមេរិកទៀត ត្រូវបានចាត់ថ្នាក់ឡើងវិញជាឥណទានមិនដំណើរការ) ។

## (ឆ) ការរឹបអូសវត្ថុបញ្ចាំ

ទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវលក់ចេញក្នុងរយៈពេលមួយឆ្នាំ តាមការកំណត់របស់ធនាគារជាតិ នៃ កម្ពុជា ។ ទ្រព្យសម្បត្តិ ដែលបានរឹបអូស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានចំនួន ៩៣០.១៧១ ដុល្លារអាមេរិក (ឆ្នាំ២០១៧៖ គ្មាន) ។ ទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវបានបង្ហាញនៅក្នុង "ទ្រព្យសកម្មផ្សេងៗ" ក្នុងតារាងតុល្យការ ។

## (ជ) គុណភាពឥណទាននៃឥណទាន និងបុរេប្រទាន

គិតត្រឹមកាលបរិច្ឆេទនៃតារាងតុល្យការ ហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និង ធនាគារ ដែលកើតពីឥណទាន និង បុរេប្រទានអតិថិជន (ដោយមិនគិតវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងៗ និង មិនគិតដល់សំវិធានធនឥណទានបាត់បង់) មានដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ឥណទាន និង បុរេប្រទាន៖ | | | | | | | | |
| មិនហួសកាលកំណត់ និង មិនថយចុះតម្លៃ | ៣.៥៥៩.០០៥.០២០ | ៣.០៨៣.៩០៥.៣៨៤ | ១៤.៣០០.០៨២.១៧០ | ១២.៤៤៩.៧២៦.០៣៣ | ៣.៤២២.៨៧៨.៧៦៦ | ២.៩៣៦.២០៨.១៩១ | ១៣.៧៥៣.១២៦.៨៨១ | ១១.៨៥៣.៤៧២.៤៦៧ |
| ហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃ | ៥.៦៩២.២៤៤ | ២០.២៤៨.៦៧២ | ២២.៨៧១.៤៣៦ | ៨១.៧៤៣.៨៩៩ | ៥.០៦៥.១៦៨ | ១៩.៤៩៣.៦៨៥ | ២០.៣៥១.៨៤៥ | ៧៨.៦៩៦.០០៦ |
| ថយចុះតម្លៃ | ៦២.៨៦២.២១២ | ៦៧.៨៣៣.៨០៦ | ២៥២.៥៨០.៣៦៩ | ២៧៣.៨៤៥.០៧៦ | ៦០.៦២៦.៤៤២ | ៦៦.៨៥៦.៦៣០ | ២៤៣.៥៩៧.០៤៤ | ២៦៩.៩០០.២១៦ |
| ឥណទាន និង បុរេប្រទានដុល | ៣.៦២៧.៥៥៩.៤៧៦ | ៣.១៧១.៩៨៧.៨៦២ | ១៤.៥៧៥.៥៣៣.៩៧៥ | ១២.៨០៥.៣១៤.៩៩៨ | ៣.៤៨៨.៥៧០.៣៧៦ | ៣.០២២.៥៥៨.៥០៦ | ១៤.០១៧.០៧៥.៧៧០ | ១២.២០២.០៦៨.៦៨៩ |
| ដក ៖ សំវិធានធនឥណទានបាត់បង់ | (៨៣.៣៨០.២៧៨) | (៦០.៤៣៧.២៨០) | (៣៣៥.០២១.៩៥៧) | (២៤៣.៩៨៥.២៩៩) | (៨០.៨៧២.៧៥៦) | (៥៨.៥៥៨.៤៦០) | (៣២៤.៩៤៦.៧៣៤) | (២៣៦.៤០០.៥០៣) |
| កម្រៃពីដំណើរការឥណទាននៅសល់ | (៣០.៥៨៥.៣៨៣) | (២៦.៣៣៥.៩៣១) | (១២២.៨៩២.០៦៩) | (១០៦.៣១៨.១៥៣) | (២៩.០២៨.៤០៥) | (២៤.១២៦.២៩០) | (១១៦.៦៣៦.១៣០) | (៩៧.៣៩៧.៨៣៣) |
| ឥណទាន និង បុរេប្រទានសុទ្ធ | ៣.៥១៣.៥៩៣.៨១៥ | ៣.០៨៥.២១៤.៦៥១ | ១៤.១១៧.៦១៩.៩៤៩ | ១២.៤៥៥.០១១.៥៤៦ | ៣.៣៧៨.៦៦៩.២១៥ | ២.៩៣៩.៨៧៣.៧៥៦ | ១៣.៥៧៥.៤៩២.៩០៦ | ១១.៨៦៨.២៧០.៣៥៣ |

*(i) ឥណទាននិងបុរេប្រទានដែលមិនហួសកាលកំណត់សងនិងមិនថយចុះតម្លៃ*

ឥណទាន និង បុរេប្រទានដែលមិនហួសកាលកំណត់សងមិនត្រូវបានចាត់ទុកថាថយចុះតម្លៃនោះទេ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ ។

*(ii) ឥណទាន និងបុរេប្រទានដែលហួសកាលកំណត់សងប៉ុន្តែមិនថយចុះតម្លៃ*

ឥណទាន និង បុរេប្រទានដែលហួសកាលកំណត់សងរហូតដល់ឃ្លាំមើល មិនត្រូវបានចាត់ទុកថាថយចុះតម្លៃនោះទេ លុះត្រាតែមានព័ត៌មានផ្សេងបញ្ជាក់ផ្ទុយពីនេះ ។ ចំនួនឥណទាន និង បុរេប្រទានអតិថិជនដុលដែលត្រូវបានចាត់តាមចំណាក់ថ្នាក់ឥណទាន ហើយដែលបានហួសកាលកំណត់សងប៉ុន្តែមិនថយចុះតម្លៃ មានដូចខាងក្រោម ៖

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ឥណទានធម្មតា | ១.៩៩១.១៤៤ | ៣.១៩២.០២២ | ៨.០០០.៤១៧ | ១២.៨៨៦.១៩៣ | ១.៥៤៩.០៩៥ | ៣.១៩២.០២២ | ៦.២២៤.២៦៤ | ១២.៨៨៦.១៩៣ |
| ឥណទានឃ្លាំមើល | ៤.១២៧.៦៤០ | ១៧.០៥៦.៦៥០ | ១៦.៥៨៤.៨៥៧ | ៦៨.៨៥៧.៦៩៦ | ៣.៥១៦.០៧៣ | ១៦.៣០១.៦៦៣ | ១៤.១២៧.៥៨២ | ៦៥.៨០៩.៨១៣ |
| | ៦.១១៨.៧៨៤ | ២០.២៤៨.៦៧២ | ២៤.៥៨៥.២៧៤ | ៨១.៧៤៣.៨៨៩ | ៥.០៦៥.១៦៨ | ១៩.៤៩៣.៦៨៥ | ២០.៣៥១.៨៤៦ | ៧៨.៦៩៦.០០៦ |

*(iii) ឥណទាន និងបុរេប្រទានដែលថយចុះតម្លៃ*

អនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមកែមិន" ឥណទាន និង បុរេប្រទាន ដែលហួសកាលកំណត់ពីឥណទានក្រោមស្តង់ដារ ត្រូវបានចាត់ទុកថាថយចុះតម្លៃ ។

| | សម្ព័ន្ធធនាគារ | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ | ២០១៨ | ២០១៧ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ឥណទានក្រោមស្តង់ដារ | ១០.២៦៨.៧៦០ | ៣៨.៦៤២.៦០១ | ៤១.២៥៩.៨៧៨ | ១៥៦.០០០.១៨០ | ៩.៤១០.៨៩៦ | ៣៨.២៨៣.០៧៥ | ៣៧.៨១២.៩៨០ | ១៥៤.៥៤៨.៧៧៥ |
| ឥណទានសង្ស័យ | ១៣.៩៩២.៩០៥ | ១៥.៧១៨.៩៧៩ | ៥៦.២២៣.៤៩៣ | ៦៣.៤៥៧.៥១៨ | ១៣.១៤៩.៤៦១ | ១៥.១០៩.៥២៥ | ៥២.៨៣៤.៥៣៤ | ៦០.៩៩៧.១៥២ |
| ឥណទានបាត់បង់ | ៣៨.៦០០.៥៤៧ | ១៣.៤៧២.២២៦ | ១៥៥.០៩៦.៩៩៨ | ៥៤.៣៨៧.៣៧៨ | ៣៨.០៦៦.០៨៥ | ១៣.៤៦៤.០៣០ | ១៥២.៩៤៩.៥៣០ | ៥៤.៣៥៤.២៨៩ |
| | ៦២.៨៦២.២១២ | ៦៧.៨៣៣.៨០៦ | ២៥២.៥៨០.៣៦៩ | ២៧៣.៨៤៥.០៧៦ | ៦០.៦២៦.៤៤២ | ៦៦.៨៥៦.៦៣០ | ២៤៣.៥៩៧.០៤៤ | ២៦៩.៩០០.២១៦ |

## ៣២.២ ហានិភ័យទីផ្សារ

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការដោះស្រាយបញ្ហាទៅលើភាពរងប៉ះពាល់លើហានិភ័យទីផ្សារ ដែលជាហានិភ័យនៃការផ្លាស់ប្តូរនៃកម្រិត ឬភាពឡើងចុះនៃអត្រាទីផ្សារ ឬតម្លៃទីផ្សារ មានដូចជា អត្រាការប្រាក់ គម្លាតឥណទាន អត្រាប្តូរ រូបិយប័ណ្ណបរទេស តម្លៃវត្ថុធាតុដើម និងតម្លៃទ្រព្យម្ចាស់ ដែលអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើចំណូលអនាគត ដើមទុន ឬសមត្ថភាពក្នុងការសម្រេចគោលដៅអាជីវកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

ប្រភេទចម្បងនៃហានិភ័យទីផ្សាររបស់សម្ព័ន្ធធនាគារ និងធនាគារ មានដូចជា ៖

(i) *ហានិភ័យអត្រាការប្រាក់* ៖ អាចនាំមកនូវភាពខាតបង់ នៅពេលមានភាពអសមតុល្យរវាងទ្រពសកម្ម និងបំណុល ហើយអត្រាការប្រាក់លើទ្រព្យទាំងនោះផ្លាស់ប្តូរជាទៀងទាត់ ឬនៅចន្លោះពេលដែលខុសគ្នា ។

(ii) *ហានិភ័យអត្រាប្តូររូបិយប័ណ្ណបរទេស* ៖ អាចនាំមកនូវភាពខាតបង់ នៅពេលមានអសមតុល្យរវាងទ្រព្យសកម្ម និងបំណុល របស់រូបិយប័ណ្ណជាក់លាក់ណាមួយ ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ (BRMC) ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលដើម្បីជួយក្រុមប្រឹក្សាភិបាល ក្នុងការចាកចេញពីទំនួលខុសត្រូវលើការគ្រប់គ្រងហានិភ័យរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងត្រួតពិនិត្យជាទៀងទាត់លើសមត្ថភាព របស់អ្នកគ្រប់គ្រងក្នុងការវាយតម្លៃ និងគ្រប់គ្រងហានិភ័យរបស់ធនាគារ ។ ហានិភ័យទីផ្សារត្រូវបានគ្រប់គ្រងផ្អែកទៅលើគោលការណ៍ និង កម្រិតកំណត់ស្ថានភាពដូចខាងក្រោម ៖

### *គោលការណ៍នៃហានិភ័យទីផ្សារ*

- ស្របទៅតាមគោលនយោបាយធនាគាររឹងមាំ សម្ព័ន្ធធនាគារ និងធនាគារ នឹងគ្រប់គ្រងយ៉ាងសកម្មលើស្ថានភាពរូបិយប័ណ្ណ និងស្ថានភាពហានិភ័យអត្រាការប្រាក់ ក្នុងការទប់បង្ការស្ថានភាព ដោយផ្គូរផ្គងទ្រព្យសកម្ម និងបំណុល ។
- សម្ព័ន្ធធនាគារ និងធនាគារមិនត្រូវពាក់ព័ន្ធនឹងសកម្មភាពដោយទទួលចំណូលបានមកពីការជួញដូរផ្តាច់មុខ ឬការទស្សន៍ ទាយលើបម្រែបម្រួលនៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ ឬតម្លៃនៃមូលធនបត្រ ។
- កម្រិតកំណត់ស្ថានភាពដូចដែលបានកំណត់ដោយធនាគារជាតិ នៃ កម្ពុជា គឺ មានអត្ថន័យកម្រិតផលប៉ះពាល់អវិជ្ជមាន នៃហានិភ័យទីផ្សារ និងមិនមានអត្ថន័យសម្រាប់បង្កើតឱកាសសម្រាប់ការជួញដូរផ្តាច់មុខទេ ។
- ទំនួលខុសត្រូវពីមួយថ្ងៃទៅមួយថ្ងៃសម្រាប់ហានិភ័យទីផ្សារ គឺស្ថិតនៅលើគណៈគ្រប់គ្រងជាន់ខ្ពស់ នៃការិយាល័យរតនាភិបាល ។

### *កម្រិតកំណត់ស្ថានភាពនៃហានិភ័យទីផ្សារ*

- កម្រិតកំណត់ដែលជាបញ្ញត្តិលើភាពមិនផ្គូរផ្គងគ្នានៃការប្តូររូបិយប័ណ្ណបរទេសក្នុងមួយរូបិយប័ណ្ណ និងការបង្គរ គួរត្រូវបានអង្កេតគ្រប់ពេលទាំងអស់ ។
- គ្រប់ពេលទាំងអស់ ធនាគារត្រូវមានកម្រិតកំណត់ស្ថានភាពខាងក្នុងដែលខ្ពស់ជាងកម្រិតកំណត់របស់បញ្ញត្តិ ដើម្បីឱ្យមានដែនសុវត្ថិភាពក្នុងការធានាការអនុលោមទាំងស្រុងជាអចិន្ត្រៃយ៍ ទៅតាមកម្រិតកំណត់បញ្ញត្តិ ។
- ការកំណត់កម្រិតនៃកម្រិតស្ថានភាពខាងក្នុង គឺស្ថិតនៅក្រោមការសម្រេចចិត្តរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និង បំណុល (MALCO) និងចាំបាច់ត្រូវតែ ១) ថែង និងលើកទឹកចិត្តនៅក្នុងកំណត់ហេតុ MALCO និង ២) ត្រូវបានអនុម័តជាផ្លូវការ ដោយប្រធាននាយកប្រតិបត្តិ ។
- នាយកដ្ឋាន និងការិយាល័យដែលពាក់ព័ន្ធគួរវាយតម្លៃជាទៀងទាត់ និងត្រួតពិនិត្យលើហានិភ័យនៃការមិនអនុលោមតាម កម្រិតកំណត់ដែលបានដឹង ។ ការបំពានកម្រិតកំណត់ស្ថានភាពខាងក្នុងគួរត្រូវបានរាយការណ៍ទៅកាន់ MALCO និងប្រធាននាយកប្រតិបត្តិ ។
- ការផ្លាស់ប្តូរទៅលើកម្រិតកំណត់ស្ថានភាពខាងក្នុង និង ត្រូវរាយការណ៍ដោយអ៊ីម៉ែល ទៅកាន់ប្រធានគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល (BALCO) និង BRMC នៅក្នុងថ្ងៃតែមួយនៃការផ្លាស់ប្តូរ ។
- គ្រប់ពេលទាំងអស់ ធនាគារត្រូវមានផែនការគ្រាអាសន្នសម្រាប់អនុវត្ត នៅពេលដែលប្រធាននាយកប្រតិបត្តិយល់ឃើញថា កម្រិតសុវត្ថិភាពអាចនឹងមិនគ្រប់គ្រាន់ និងមានហានិភ័យលើការល្មើសលើកម្រិតកំណត់បញ្ញត្តិ លើភាពមិនផ្គូរផ្គងគ្នានៃការប្តូររូបិយប័ណ្ណបរទេស ។ ផែនការគ្រាអាសន្ននេះគួរតែគ្រប់គ្រាន់ដើម្បីធានាថាកម្រិតកំណត់បញ្ញត្តិភាពលើភាពមិនផ្គូរផ្គងការប្តូររូបិយប័ណ្ណបរទេស នឹងមិនត្រូវបានល្មើស ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ សម្ព័ន្ធធនាគារ និងធនាគារ មិនមានឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃសមស្របទេ ។ សម្ព័ន្ធធនាគារប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និង ការផ្តោះប្តូរអត្រាការប្រាក់ ដើម្បីគ្រប់គ្រងហានិភ័យរបស់ខ្លួន ។

### (ក) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ គឺជាហានិភ័យដែលធ្វើឱ្យមានការប្រែប្រួលលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ ហានិភ័យអត្រាការប្រាក់នៃតម្លៃសមស្របគឺជាហានិភ័យ ដែលធ្វើឱ្យមានការប្រែប្រួលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ ។ កម្រិតនៃការប្រាក់អាចកើន ឡើងដោយសារលទ្ធផលនៃការប្រែប្រួល ប៉ុន្តែអាចកាត់បន្ថយការខាតបង់នៅក្នុងករណីដែលបម្រែបម្រួលឥតរំពឹងទុកកើតឡើង ។

គណៈគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងខណៈនេះមិនមានចែងជាគោលការណ៍ ដើម្បីកំណត់កម្រិតនៃភាព លម្អៀងនៃការប្រែប្រួលថ្លៃរបស់អត្រាការប្រាក់ដើម្បីអនុវត្តនោះទេ ប៉ុន្តែគណៈគ្រប់គ្រងក៏បានធ្វើការត្រួតពិនិត្យជាប្រចាំនូវបម្រែបម្រួល នោះដែរ ។

ហានិភ័យអត្រាការប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ កើតពីប្រាក់កម្ចី ។ ប្រាក់កម្ចីដែលបានផ្តល់ក្នុងអត្រាការប្រាក់អថេរ ធ្វើឱ្យសម្ព័ន្ធធនាគារ និងធនាគារប្រឈមនឹងហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ ។ សម្ព័ន្ធធនាគារ និងធនាគារ គ្រប់គ្រង ហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ ដោយប្រើការផ្តោះប្តូរអត្រាការប្រាក់អថេរទៅអត្រាថេរ (floating-to-fixed interest rate swaps) ។ ការផ្តោះប្តូរអត្រាការប្រាក់បែបនេះ មានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចលើការបង្វិលប្រាក់កម្ចីពីអត្រាអថេរទៅ អត្រាថេរ និង ប៉ះពាល់ដល់ការកត់ត្រាចំណាយការប្រាក់ដែលផ្អែកទៅតាមអត្រាថេរ ។ សម្ព័ន្ធធនាគារ និងធនាគារ ទទួលប្រាក់កម្ចី តាមអត្រាអថេរ និង ប្តូរវាទៅជាអត្រាថេរដែលទាបជាងអត្រាដែលមានប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ បានខ្ចីតាមអត្រាថេរ ដោយផ្ទាល់ ។ តាមការប្តូរអត្រាការប្រាក់ សម្ព័ន្ធធនាគារ និងធនាគារ ព្រមព្រៀងជាមួយភាគីផ្សេងៗដើម្បីផ្តោះប្តូរតាមចន្លោះពេលវេលាជាក់លាក់ (ជាចម្បង តាមមូលដ្ឋានប្រចាំឆមាស) ភាពលម្អៀងរវាងអត្រាថេរក្នុងកិច្ចសន្យា និងចំនួនការប្រាក់ដែលមាន អត្រាអថេរ ត្រូវបានគណនាដោយ យោងទៅ តាមចំនួនដែលបានព្រមព្រៀងគ្នា ។

តារាងខាងក្រោមនេះ សង្ខេបពីហានិភ័យអត្រាការប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ ។ នៅក្នុងតារាងនេះក៏រួមបញ្ចូលនូវ ឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោងដោយបានចាត់ថ្នាក់តាមតម្លៃក្នុងកិច្ចសន្យាដើមគ្រា ឬតាមកាលផុតកំណត់សង ។

| | សម្ព័ន្ធធនាគារ | | | | | | |
|---|---|---|---|---|---|---|---|
| | ១ខែ | ១ខែទៅ៣ខែ | ៣ខែទៅ១២ខែ | ១ឆ្នាំទៅ៥ឆ្នាំ | លើសពី៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៤០៧.៨៦៤.៧០៣ | ៤០៧.៨៦៤.៧០៣ |
| សមតុល្យនៅធនាគារកណ្តាល | ៣២៩.៨០០.០០០ | ២៥៨.៧២៨.៣៣២ | ៣១.៤០០.០០០ | - | - | ៣១០.៣៣៨.០៨៩ | ៩៣០.២៦៦.៤២១ |
| សមតុល្យនៅធនាគារផ្សេងៗ | ១៩.៣១១.៧១២ | ៣១០.៩០៥ | - | - | - | ៦.៩៤៥.០៧៥ | ២៦.៥៦៧.៦៩២ |
| ឥណទាន និង បុរេប្រទានអតិថិជន | | | | | | | |
| ឥណទានដំណើរការ | ១១០.៥៩១.៣៤៦ | ២២៩.០០១.៨៦៥ | ៧០៧.៦៥១.៤៩៧ | ២.០៤៨.១៦២.៨១៩ | ៤២៩.២៨៩.៧៣៧ | - | ៣.៥៦៤.៦៩៧.២៦៤ |
| ឥណទានមិនដំណើរការ | - | - | - | - | - | ៦២.៨៦២.២១២ | ៦២.៨៦២.២១២ |
| សំវិធានធនឥណទានបាត់បង់ | - | - | - | - | - | (៨៣.៣៨០.២៧៨) | (៨៣.៣៨០.២៧៨) |
| កម្រៃពីដំណើរការឥណទាននៅសល់ | - | - | - | - | - | (៣០.៥៨៥.៣៨៣) | (៣០.៥៨៥.៣៨៣) |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ៣៣.៧៣០.០១៤ | ៣៣.៧៣០.០១៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៤៥៩.៧០៣.០៥៨ | ៤៨៨.០៤១.១០២ | ៧៣៩.០៥១.៤៩៧ | ២.០៤៨.១៦២.៨១៩ | ៤២៩.២៨៩.៧៣៧ | ៧០៧.៧៧៤.៤៣២ | ៤.៩១២.០២២.៦៤៥ |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ៧៩.១៦៥.៥៨៩ | ៩.៣៩២.៩៦៤ | ៦.១៣៨.២៣២ | ៧.៦២១.០៩៨ | ៦១.៦៥០.០០០ | ១២២.៩៧៣.៤២៦ | ២៨៦.៩៤១.៣០៩ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១.៦៩២.៤៥២.៧៤៩ | ២៦២.៥៩០.០៦៤ | ៨៣៤.២១៤.០១២ | ៣៤៧.៥៤០.៣៦៣ | ១២.៤០០.៨១៨ | ៣៩៩.៦៩១.០៣៤ | ៣.៥៤៨.៨៨៩.០៤០ |
| បំណុលផ្សេងៗ | - | - | - | - | - | ៧៥.០២៩.៥១៦ | ៧៥.០២៩.៥១៦ |
| ប្រាក់កម្ចី | ២៧.៧៩០.៧៧៨ | ២៧.៥៦២.៨១៧ | ៣៧១.៣០៨.៩១៣ | ៣៤៩.៦៦៤.២០៦ | ៨.៣៤៥.១៦៥ | - | ៧៨៤.៦៧១.៨៧៩ |
| បំណុលបន្ទាប់បន្សំ | - | - | ៣២.០០០.០០០ | ១៧.០០០.០០០ | ២៨.១០១.៤៩០ | - | ៧៧.១០១.៤៩០ |
| បំណុលហិរញ្ញវត្ថុសរុប | ១.៧៩៩.៤០៩.១១៦ | ២៩៩.៥៤៥.៨៤៥ | ១.២៤៣.៦៦១.១៥៧ | ៧២១.៨២៥.៦៦៧ | ១១០.៤៩៧.៤៧៣ | ៥៩៧.៦៩៣.៩៧៦ | ៤.៧៧២.៦៣៣.២៣៤ |
| គំលាតតម្លៃអត្រាការប្រាក់សរុប | (១.៣៣៩.៧០៦.០៥៨) | ១៨៨.៤៩៥.២៥៧ | (៥០៤.៦០៩.៦៦០) | ១.៣២៦.៣៣៧.១៥២ | ៣១៨.៧៩២.២៦៤ | ១១០.០៨០.៤៥៦ | ១៣៩.៣៨៩.៤១១ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | (៥.៣៨២.៩៣៨.៩៤១) | ៧៥៧.៣៧៣.៩៤៣ | (២.០២៧.៥២១.៦១៤) | ៥.៤៨៩.៩៤២.៦៧៧ | ១.២៨០.៩០៧.៣១៧ | ៤៤២.៣០៣.២៧០ | ៥៦០.០៦៦.៦៥២ |

| | សម្ព័ន្ធធនាគារ | | | | | | |
|---|---|---|---|---|---|---|---|
| | ១ខែ | ១ខែទៅ៣ខែ | ៣ខែទៅ១២ខែ | ១ឆ្នាំទៅ៥ឆ្នាំ | លើសពី៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៣២១.៧៤៤.២៤៥ | ៣២១.៧៤៤.២៤៥ |
| សមតុល្យនៅធនាគារកណ្តាល | ៤៧១.៦៥២.២១៧ | ២៣៩.៩៤០.៦៧៤ | - | - | - | ២៩០.០៥៤.២៤៣ | ១.០០១.៦៤៧.១៣៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ១០៧.៨៦១.១០៤ | - | ៣.០០០.០០០ | - | - | ៩.៣៩៣.៨១៣ | ១២០.២៥៤.៩១៧ |
| ឥណទាន និង បុរេប្រទានអតិថិជន | | | | | | | |
| ឥណទានដំណើរការ | ១០២.៧៤៣.៤០៧ | ២៣៧.៧១៥.៥៨៦ | ៦៦០.២៨៤.៣៧៣ | ១.៧៦៦.៧០៣.១៤៦ | ៣៣៦.៧០៧.៥៤៤ | - | ៣.១០៤.១៥៤.០៥៦ |
| ឥណទានមិនដំណើរការ | - | - | - | - | - | ៦៧.៨៣៣.៨០៦ | ៦៧.៨៣៣.៨០៦ |
| សំវិធានធនឥណទានបាត់បង | - | - | - | - | - | (៦០.៤៣៧.២៨០) | (៦០.៤៣៧.២៨០) |
| កម្រៃពីដំណើរការឥណទាននៅសល់ | - | - | - | - | - | (២៦.៣៣៥.៩៣១) | (២៦.៣៣៥.៩៣១) |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ៣១.៥៣៩.០៨៧ | ៣១.៥៣៩.០៨៧ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៦៨២.២៥៦.៧២៨ | ៤៧៧.៦៥៦.២៦០ | ៦៦៣.២៨៤.៣៧៣ | ១.៧៦៦.៧០៣.១៤៦ | ៣៣៦.៧០៧.៥៤៤ | ៦៣៣.៧៩១.៩៨៣ | ៤.៥៦០.៤០០.០៣៤ |
| | | | | | | | |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១០៤.២០៥.០៥៦ | ៥.៣២០.៣៦៩ | ១០.៦៨៤.២៧៦ | - | - | ៩២.២៤៥.៣៨៨ | ២១២.៤៥៥.០៨៩ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១.៤០១.៥៦៦.៨៦៧ | ៣១០.៧០៥.០៧៨ | ៧៤២.០៧០.១០៤ | ២៦៤.៦៣៦.៩៦៣ | ៦៣.៧៥៤.៩៦៨ | ៣៣៤.៤៧៥.៧៤២ | ៣.១១៧.២០៩.៧២៦ |
| បំណុលផ្សេងៗ | - | - | ៧៩១.០២១ | - | - | ៥៨.៧៧៨.៣៩២ | ៥៩.៥៦៩.៤១៣ |
| ប្រាក់កម្ចី | ១៨.៣៣៣.៣៣១ | ១២០.០៥៨.៦២០ | ៣៤៨.៤៥៧.៩៩៤ | ៣៩៦.២៨១.៦៦៦ | ២៣.២៤៦.៥៧១ | - | ៩០៦.៣៧៨.១៨២ |
| បំណុលបន្ទាប់បន្សំ | - | - | ៤៣.០០០.០០០ | ៤៩.០០០.០០០ | ១៦.៦៨៤.០៩០ | - | ១០៨.៦៨៤.០៩០ |
| បំណុលហិរញ្ញវត្ថុសរុប | ១.៥២៤.១០៥.២៥៤ | ៤៣៦.០៨៤.០៦៧ | ១.១៤៥.០០៣.៣៩៩ | ៧០៩.៩១៨.៦២៩ | ១០៣.៦៨៥.៦២៩ | ៤៨៥.៤៩៩.៥២២ | ៤.៤០៤.២៩៦.៥០០ |
| | | | | | | | |
| គំលាតតម្លៃអត្រាការប្រាក់សរុប | (៨៤១.៨៤៨.៥២៦) | ៤១.៥៧២.១៩៣ | (៤៨១.៧១៩.០២៦) | ១.០៥៦.៧៨៤.៥១៧ | ២៣៣.០២១.៩១៥ | ១៤៨.២៩២.៤៦១ | ១៥៦.១០៣.៥៣៤ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | (៣.៣៨៨.៥៤២.៩៩៩) | ១៦៧.៨២៦.៩៤៣ | (១.៩៤៤.៦៩៩.៧០៨) | ៤.២៦៦.២៣៩.០៩៥ | ៩៤០.៧០៥.៤៧១ | ៥៩៨.៦៥៦.៦៥៥ | ៦៣០.១៨៩.៩៦៧ |

| | ធនាគារ | | | | | | |
|---|---|---|---|---|---|---|---|
| | ១ខែ | ១ខែទៅ៣ខែ | ៣ខែទៅ១២ខែ | ១ឆ្នាំទៅ៥ឆ្នាំ | លើសេ៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៣៩៨.០១២.១៨៤ | ៣៩៨.០១២.១៨៤ |
| សមតុល្យនៅធនាគារកណ្តាល | ៣២៩.៨០០.០០០ | ២៥៨.១០៦.៥២១ | ៣១.៤០០.០០០ | - | - | ៣០៤.៣២១.២៥៧ | ៩២៣.៦២៧.៧៧៨ |
| សមតុល្យនៅធនាគារផ្សេងៗ | ១៩.៣១១.៣៧៧ | - | - | - | - | ៥.០២៨.២៩៩ | ២៤.៣៣៩.៦៧៦ |
| ឥណទាន និង បុរេប្រទានអតិថិជន | | | | | | | |
| ឥណទានដំណើរការ | ១០៣.៣៦២.៧១៣ | ២១៣.៧៨៥.៩៦៣ | ៦៦១.៩៤៣.៤១៩ | ២.០២១.០៣៧.៣៧២ | ៤២៧.៨១៤.៤៦៧ | - | ៣.៤២៧.៩៤៣.៩៣៤ |
| ឥណទានមិនដំណើរការ | - | - | - | - | - | ៦០.៦២៦.៤៤២ | ៦០.៦២៦.៤៤២ |
| សំវិធានធនឥណទានបាត់បង | - | - | - | - | - | ( ៨០.៨៧២.៧៥៦ ) | ( ៨០.៨៧២.៧៥៦ ) |
| កម្រៃពីដំណើរការឥណទាននៅសល់ | - | - | - | - | - | ( ២៩.០២៨.៤០៥ ) | ( ២៩.០២៨.៤០៥ ) |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ៣២.៥១៤.៧៩៥ | ៣២.៥១៤.៧៩៥ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៤៥២.៤៧៤.០៩០ | ៤៧១.៨៩២.៤៨៤ | ៦៩៣.៣៤៣.៤១៩ | ២.០២១.០៣៧.៣៧២ | ៤២៧.៨១៤.៤៦៧ | ៦៩០.៦០១.៨១៦ | ៤.៧៥៧.១៦៣.៦៤៨ |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ៧៧.៨៤៣.៨៥៣ | ៦.៤០៥.៩៦៦ | ៥.៤៥៨.៨៣៦ | ៧.៦២១.០៩៨ | ៦១.៦៥០.០០០ | ១២៤.០៣៧.០៧៣ | ២៨៣.០១៦.៨២៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១.៦៦២.៣៦៣.៦៩២ | ២៥៦.៨១៦.១១៩ | ៨១៥.៦៥៣.៤៥៥ | ៣៣១.២៥៧.៥០២ | ១០.៩៩១.៥៧៦ | ៣៩៣.៣០៤.២២៨ | ៣.៤៧០.៣៨៦.៥៧២ |
| បំណុលផ្សេងៗ | - | - | - | - | - | ៧០.៧២៧.៧៦១ | ៧០.៧២៧.៧៦១ |
| ប្រាក់កម្ចី | ២៧.៧៩០.៧៧៧ | ២២.៦៥៦.១៧២ | ៣៦១.១០០.៤៦៧ | ៣៣២.៩៥២.៣៨៣ | ៣.៧៥០.០០០ | - | ៧៤៨.២៤៩.៧៩៩ |
| បំណុលបន្ទាប់បន្សំ | - | - | ៣២.០០០.០០០ | ១៧.០០០.០០០ | ២៨.១០១.៤៩០ | - | ៧៧.១០១.៤៩០ |
| បំណុលហិរញ្ញវត្ថុសរុប | ១.៧៦៧.៩៩៨.៣២២ | ២៨៥.៨៧៨.២៥៧ | ១.២១៤.២១២.៧៥៨ | ៦៨៨.៨៣០.៩៨៣ | ១០៤.៤៩៣.០៦៦ | ៥៨៨.០៦៩.០៦២ | ៤.៦៤៩.៤៨២.៤៤៨ |
| គំលាតតម្លៃអត្រាការប្រាក់សរុប | ( ១.៣១៥.៥២៤.២៣២ ) | ១៨៦.០១៤.២២៧ | ( ៥២០.៨៦៩.៣៣៩ ) | ១.៣៣២.២០៦.៣៨៩ | ៣២៣.៣២១.៤០១ | ១០២.៥៣២.៧៥៤ | ១០៧.៦៨១.២០០ |
| សមមូលនឹងពាន់រៀល ( កំណត់សម្គាល់ ៤ ) | ( ៥.២៨៥.៧៧៦.៣៦៥ ) | ៧៤៧.៤០៥.១៦៤ | ( ២.០៩២.៨៩៣.០០៤ ) | ៥.៣៥២.៨០៥.២៧១ | ១.២៩៩.១០៥.៣៨៩ | ៤១១.៩៧៦.៦០៦ | ៤៣២.៦៦៣.០៦១ |

| | ធនាគារ | | | | | | |
|---|---|---|---|---|---|---|---|
| | ១ខែ | ១ខែទៅ៣ខែ | ៣ខែទៅ១២ខែ | ១ឆ្នាំទៅ៥ឆ្នាំ | លើសពី៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៣១០.៨៧៥.៧៣០ | ៣១០.៨៧៥.៧៣០ |
| សមតុល្យនៅធនាគារកណ្ដាល | ៤៧១.៦៥២.២១៧ | ២៣៧.៩៤០.៦៧៤ | - | - | - | ២៨០.៤៩៣.៣៥៦ | ៩៩០.០៨៦.២៤៧ |
| សមតុល្យនៅធនាគារផ្សេងៗ | ១០៧.៨៦១.០១៦ | ៥.០០០.០០០ | ៣.០០០.០០០ | - | - | ៦.០០២.៤៣៣ | ១២១.៨៦៣.៤៤៩ |
| ឥណទាន និង បុរេប្រទានអតិថិជន | | | | | | | |
| ឥណទានដំណើរការ | ៩៤.៨២៧.៤៥៦ | ២២១.០០៣.៦៩៥ | ៦០៨.៧៥៥.៩៧៣ | ១.៦៩៤.៨៩៨.៦៩០ | ៣៣៦.២១៦.០៦២ | - | ២.៩៥៥.៧០១.៨៧៦ |
| ឥណទានមិនដំណើរការ | - | - | - | - | - | ៦៦.៨៥៦.៦៣០ | ៦៦.៨៥៦.៦៣០ |
| សំវិធានធនឥណទានបាត់បង់ | - | - | - | - | - | (៥៨.៥៥៨.៤៦០) | (៥៨.៥៥៨.៤៦០) |
| កម្រៃពីដំណើរការឥណទាននៅសល់ | - | - | - | - | - | (២៤.១២៦.២៩០) | (២៤.១២៦.២៩០) |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ៣០.៤៦៥.៦៦៩ | ៣០.៤៦៥.៦៦៩ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៦៧៤.៣៤០.៦៨៩ | ៤៦៣.៩៤៤.៣៦៩ | ៦១១.៧៥៥.៩៧៣ | ១.៦៩៤.៨៩៨.៦៩០ | ៣៣៦.២១៦.០៦២ | ៦១២.០០៩.០៦៨ | ៤.៣៩៣.១៦៤.៨៥១ |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១០៣.២២៥.៣១៨ | ១១៤.៧៧១ | ៨.២៧១.១៩៩ | - | - | ៩៣.៨៥៧.០៣៨ | ២០៥.៤៦៨.២៧៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១.៣៧០.៨១៧.៦៩៩ | ៣០៧.៦០៧.៨១០ | ៧២៦.៥៦៥.៦៦៤ | ២៤៣.៨២៤.១៣២ | ៦២.៩៥០.៩៧៨ | ៣៣២.៧១៧.៨៩៥ | ៣.០៤៤.៤៨៤.១៧៨ |
| បំណុលផ្សេងៗ | - | - | ៧៩១.០២១ | - | - | ៥៥.៣៣២.៧១៦ | ៥៦.១២៣.៧៣៧ |
| ប្រាក់កម្ចី | ១៨.៣៣៣.៣៣១ | ១១៥.១៧៨.៥៧១ | ៣៣៨.១៩០.៤៧៦ | ៣៧៣.៦០៧.១៤៩ | ២០.៨៣៣.៣៣៣ | - | ៨៦៦.១៤២.៨៦០ |
| បំណុលបន្ទាប់បន្សំ | - | - | ៤៣.០០០.០០០ | ៤៩.០០០.០០០ | ១៦.៦៨៤.០៩០ | - | ១០៨.៦៨៤.០៩០ |
| បំណុលហិរញ្ញវត្ថុសរុប | ១.៤៩២.៣៧៦.៣៤៨ | ៤២២.៩០១.១៥២ | ១.១១៦.៨១៨.៣១០ | ៦៦៦.៤៣១.២៨១ | ១០០.៤៦៨.៤០១ | ៤៨១.៩០៧.៦៤៩ | ៤.២៨០.៩០៣.១៤១ |
| គំលាតតម្លៃអត្រាការប្រាក់សរុប | (៨១៨.០៣៥.៦៥៩) | ៤១.០៤៣.២១៧ | (៥០៥.០៦២.៣៣៧) | ១.០២៨.៤៦៧.៤០៩ | ២៣៥.៧៤៧.៦៦១ | ១៣០.១០១.៤១៩ | ១១២.២៦១.៧១០ |
| សមមូលនឹងពាន់រៀល (កំណត់សម្គាល់ ៤) | (៣.៣០២.៤០៩.៩៥៥) | ១៦៥.៦៩១.៤៦៧ | (២.០៣៨.៩៣៦.៦៥៤) | ៤.១៥១.៩២២.៩៣០ | ៩៥១.៧១៣.៣០៧ | ៥២៥.២១៩.៤២៩ | ៤៥៣.២០០.៥២៤ |

*ការវិភាគ sensitivity តម្លៃសមស្រប ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាថេរ*

សម្ព័ន្ធធនាគារ និង ធនាគារ មិនកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលមានអត្រាថេរ តាមតម្លៃសមស្របទេ ។ ដូចនេះ ប្រសិនបើមានបម្រែបម្រួលអត្រាការប្រាក់ណាមួយនាកាលបរិច្ឆេទរាយការណ៍នេះ វានឹងមិនមានផលប៉ះពាល់ដល់របាយការណ៍លទ្ធផលទេ ។

*ការវិភាគ sensitivity លំហូរសាច់ប្រាក់ ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាអថេរ*

របាយការណ៍លទ្ធផលមានសភាពងាយប្រែប្រួលទៅតាមចំណាយការប្រាក់លើប្រាក់កម្ចី ដែលខ្ពស់ជាង/ទាបជាងអាស្រ័យ ទៅតាមការប្រែប្រួលអត្រាការប្រាក់ ។ ការប្រែប្រួលពិន្ទុមូលដ្ឋាន ២៥ ("bp") នៃអត្រាការប្រាក់របស់ប្រាក់កម្ចីនាកាលបរិច្ឆេទរាយការណ៍ នឹងមិនមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍លទ្ធផលរបស់សម្ព័ន្ធធនាគារ និងធនាគារទេ ។

## (ខ) ហានិភ័យការប្តូររូបិយប័ណ្ណ

សម្ព័ន្ធធនាគារធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ និង ប្រទេសមីយ៉ាន់ម៉ា និងធ្វើប្រតិបត្តិការដោយប្រើរូបិយប័ណ្ណ ច្រើនប្រភេទ ហើយត្រូវប្រឈមមុខនឹងហានិភ័យរូបិយប័ណ្ណផ្សេងៗគ្នាដែរ ក្នុងនោះរូបិយប័ណ្ណសំខាន់ៗរួមមាន ប្រាក់រៀល ប្រាក់អឺរ៉ូ ប្រាក់បាតថៃ ប្រាក់គីបឡាវ ប្រាក់យ៉េនជប៉ុន ប្រាក់ដុល្លារអូស្ត្រាលី ប្រាក់ដុងវៀតណាម ប្រាក់ដុល្លារកាណាដា ប្រាក់ក្យាត មីយ៉ាន់ម៉ា និង រូបិយប័ណ្ណផ្សេងៗទៀត ។

ហានិភ័យរូបិយប័ណ្ណកើតពីប្រតិបត្តិការពាណិជ្ជកម្មក្នុងពេលអនាគត ទ្រព្យសកម្ម និងបំណុលដែលបានកត់ត្រាជា រូបិយប័ណ្ណមួយ ដែលមិនមែនជារូបិយប័ណ្ណគោលរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

គណៈគ្រប់គ្រងត្រួតពិនិត្យហានិភ័យការប្តូររូបិយប័ណ្ណ ដោយផ្ទៀបនឹងរូបិយប័ណ្ណគោល ។ ដើម្បីការពារហានិភ័យការប្តូររូបិយប័ណ្ណដែលកើតពីប្រតិបត្តិការពាណិជ្ជកម្មក្នុងពេលអនាគត និងទ្រព្យសកម្ម និងបំណុលដែលបានកត់ត្រា សម្ព័ន្ធធនាគារប្រើកិច្ចសន្យានាពេលអនាគត ។

តារាងខាងក្រោមនេះសង្ខេបអំពីហានិភ័យការប្តូររូបិយប័ណ្ណរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ។ ក្នុងតារាងនេះគឺជាឧបករណ៍ហិរញ្ញវត្ថុតាមតម្លៃយោង ដោយវិភាគតាមរូបិយប័ណ្ណ និងមានតម្លៃសមមូលនឹងប្រាក់ដុល្លារអាមេរិក ។

| | សម្ព័ន្ធធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សមមូលជាប្រាក់ដុល្លារអាមេរិក | | | | | | | |
| | ប្រាក់រៀល | ប្រាក់ដុល្លារអាមេរិក | ប្រាក់បាតថៃ | ប្រាក់អឺរ៉ូ | ប្រាក់ដុល្លារអូស្ត្រាលី | ប្រាក់គីបឡាវ | រូបិយប័ណ្ណផ្សេងៗ | សរុប |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧៤.០៤៦.១៦៣ | ៣០៧.៦២៧.៨៤៦ | ១៦.១៨០.១១៥ | ១.៩១៩.៦៣១ | ២៩៧.១១២ | ៥.៤៥៧.៦៩២ | ២.៣៣៦.១៤៤ | ៤០៧.៨៦៤.៧០៣ |
| សមតុល្យនៅធនាគារកណ្តាល | ៧៣.១៥០.១៨០ | ៨៥២.០៨២.០១៦ | ២.០៨៤.៣២២ | - | - | ២.៩៤៩.៩០៣ | - | ៩៣០.២៦៦.៤២១ |
| សមតុល្យនៅធនាគារផ្សេងៗ | - | ២១.៤៨០.៥៣៧ | ២.១៩៣.០០២ | ១.៨៧០.៣៧១ | - | ៣២៤.៧១២ | ៦៩៩.០៧០ | ២៦.៥៦៧.៦៩២ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៤០៩.៤៥០.៤៣៤ | ២.៩៤៤.៤៩២.៧០៤ | ២៥.១៩០.៨៣៩ | - | - | ១១១.៤៣៩.១៦៦ | ២៣.០២០.៦៧២ | ៣.៥១៣.៥៩៣.៨១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៣.៨៥៨.៣៧៦ | ២៨.២៥៧.៣០៧ | ២៧១.៩៣៦ | - | - | ៩៣៦.០៤៨ | ៤០៦.៣៤៧ | ៣៣.៧៣០.០១៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៥៦០.៥០៥.១៥៣ | ៤.១៥៣.៩៤០.៤១០ | ៤៥.៩២០.២១៤ | ៣.៧៩០.០០២ | ២៩៧.១១២ | ១២១.១០៧.៥២១ | ២៦.៤៦២.២៣៣ | ៤.៩១២.០២២.៦៤៥ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ២៨.៥១៥.៩៤៦ | ២៤៧.០១៦.៤០៦ | ៨.១៧៧.៨០២ | - | - | ៣.២៣១.១៥៥ | - | ២៨៦.៩៤១.៣០៩ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៤៦២.៧៦៣.០៥៧ | ២.៩៣៧.៥៣៦.៧៦២ | ៣៦.០២២.៥០៧ | ៣.៤១៩.៧៤៩ | ២២៦ | ៦៥.៨២៨.៩៩៦ | ៣.៣១៧.៧៤៣ | ៣.៥៤៨.៨៨៩.០៤០ |
| បំណុលផ្សេងៗ | ៧.៧៩៨.១៩០ | ៦៤.៧៦៩.១៣៣ | ៨៥.១៩២ | ២២១.៦០៤ | - | ១.៨៨៦.៥៨៩ | ២៦៨.៨០៨ | ៧៥.០២៩.៥១៦ |
| ប្រាក់កម្ចី | ៤៤.២២៥.៩៨៤ | ៧១៦.៨៨៤.៥១៨ | - | - | - | ១៣.៥១៩.៤៥៣ | ១០.០៤១.៩២៤ | ៧៨៤.៦៧១.៨៧៩ |
| បំណុលបន្ទាប់បន្សំ | - | ៧៧.១០១.៤៥០ | - | - | - | - | - | ៧៧.១០១.៤៥០ |
| បំណុលហិរញ្ញវត្ថុសរុប | ៥៤៣.៣០៣.១៧៧ | ៤.០៤៣.៣០៨.៣០៩ | ៤៤.២៨៥.៥០១ | ៣.៦៤១.៣៥៣ | ២២៦ | ៨៤.៤៦៦.១៩៣ | ១៣.៦២៨.៤៧៥ | ៤.៧៧២.៦៣៣.២៣៤ |
| **ស្ថានភាពសុទ្ធនៅលើតារាងតុល្យការ** | ១៧.២០១.៩៧៦ | ៧០.៦៣២.១០១ | ១.៦៣៤.៧១៣ | ១៤៨.៦៤៩ | ២៩៦.៨៨៦ | ៣៦.៦៤១.៣២៨ | ១២.៨៣៣.៧៥៨ | ១៣៩.៣៨៩.៤១១ |
| **សមមូលនឹងពាន់រៀល** (កំណត់សម្គាល់ ៤) | ៦៩.១១៧.៥៣៧ | ២៨៣.៧៩៩.៧៨២ | ៦.៥៦៨.២៧៧ | ៥៩៧.២៧២ | ១.១៩២.៨៨៨ | ១៤៧.២២៤.៨៥៦ | ៥១.៥៦៦.០៤០ | ៥៦០.០៦៦.៦៥២ |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ២.១៥២.៥៨៣ | ៩៩.២២៩.២០៥ | ២៤៥.៩៤០ | - | - | - | - | ១០១.៦២៧.៧២៨ |
| កិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត | - | - | - | - | - | - | - | - |
| លិខិតធានាធនាគារ លិខិតទទួលស្គាល់ និង ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ | ២.៤៨៨.១៥៩ | ៤៣.៥៤៨.៤៥៧ | ៤៨.៩៧៣ | ១៨៣.៩៣៨ | - | - | ១៩៧.៧០២ | ៤៦.៤៦៧.២២៩ |
| **កិច្ចសន្យាត្រូវសង** | ៤.៦៤០.៧៤២ | ១៤២.៧៧៧.៦៦២ | ២៩៤.៩១៣ | ១៨៣.៩៣៨ | - | - | ១៩៧.៧០២ | ១៤៨.០៩៤.៩៥៧ |
| **សមមូលនឹងពាន់រៀល** (កំណត់សម្គាល់ ៤) | ១៨.៦៤៦.៥០១ | ៥៧៣.៦៨០.៦៤៦ | ១.១៨៤.៩៦០ | ៧៣៩.០៦៣ | - | - | ៧៩៤.៣៦៧ | ៥៩៥.០៤៥.៥៣៧ |

| | សម្ព័ន្ធធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សមមូលជាប្រាក់ដុល្លារអាមេរិក | | | | | | | |
| | ប្រាក់រៀល | ប្រាក់ដុល្លារអាមេរិក | ប្រាក់បាតថៃ | ប្រាក់អឺរ៉ូ | ប្រាក់ដុល្លារអូស្រ្តាលី | ប្រាក់គីបឡាវ | រូបិយប័ណ្ណផ្សេងៗ | សរុប |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧៦.២១៣.២៦៣ | ២២០.៤២៩.៣៤៧ | ១៥.៤១៧.១៣៨ | ១.៨៣៤.៨០០ | ២៦១.១៧៦ | ៦.៦៧០.៩៧០ | ៩១៧.៥៥១ | ៣២១.៧៤៤.២៤៥ |
| សមតុល្យនៅធនាគារកណ្តាល | ២៣១.៨២៩.០០៣ | ៧៦៣.៥៥០.៧២៨ | ២.៩៨៣.៥៤៤ | - | - | ៣.២៨៣.៨៥៩ | - | ១.០០១.៦៤៧.១៣៤ |
| សមតុល្យនៅធនាគារផ្សេងៗ | - | ១១២.៧៤៨.៧៧៥ | ១.៧៣៤.៨៩៣ | ១.៩៧៩.៦៩២ | ១២១.១៦៣ | ៥២៦.៩៩៩ | ៣.១៤៣.៣៩៥ | ១២០.២៥៤.៩១៧ |
| ឥណទាន និង បុរេប្រទានអតិថិជន | ១៥៩.២៩៨.៥៦៥ | ២.៧៤៩.២៣៥.៧៦៦ | ៣៣.០៤៦.៧៩៨ | - | - | ១២១.៣១០.៤៨៨ | ២២.៣២៣.០៣៤ | ៣.០៨៥.២១៤.៦៥១ |
| ទ្រព្យសកម្មផ្សេងៗ | ២.០៦៩.៣០៧ | ២៧.៦៧៧.៧០៩ | ៣៨០.៧៩៣ | - | - | ១.០៥៧.៧៣៨ | ៣៥៣.៥៤០ | ៣១.៥៣៩.០៨៧ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៤៦៩.៤១០.១៣៨ | ៣.៨៧៣.៦៤២.៣២៥ | ៥៣.៥៦៣.១៦៦ | ៣.៨១៤.៤៩២ | ៣៨២.៣៣៩ | ១៣២.៨៥០.០៥៤ | ២៦.៧៣៧.៥២០ | ៤.៥៦០.៤០០.០៣៤ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ៥៥.០៥៧.៥៤១ | ១៤២.១៩៩.៣៨០ | ៧.០៩៩.៦៣៤ | - | - | ៨.០៩៨.៥៣៤ | - | ២១២.៤៥៥.០៨៩ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៤១១.៨៩៩.១៨៤ | ២.៥៩០.៣៣៥.០១៨ | ៤៧.៦៤៨.០៤៨ | ២.៩៥៨.៦៦១ | ៣៦៥ | ៦២.៥៣៩.៩២៥ | ១.៨២៨.៥២៥ | ៣.១១៧.២០៩.៧២៦ |
| បំណុលផ្សេងៗ | ៦.៦០៧.១៩៧ | ៥០.២២២.២០៨ | ៣២៣.៥៧២ | ១១៣.៦៦៤ | ៧៨៣ | ១.៨៨៦.៣៨៣ | ៤១៥.៦០៦ | ៥៩.៥៦៩.៤១៣ |
| ប្រាក់កម្ចី | - | ៨៧០.៥៦៩.៣៣៧ | - | - | - | ២២.៧៣៦.១៦៩ | ១២.៦៧២.៦៧៦ | ៩០៦.៣៧៨.១៨២ |
| បំណុលបន្ទាប់បន្សំ | - | ១០៨.៦៨៤.០៩០ | - | - | - | - | - | ១០៨.៦៨៤.០៩០ |
| បំណុលហិរញ្ញវត្ថុសរុប | ៤៧៣.៥៦៣.៩២២ | ៣.៧៦២.០១០.០៣៣ | ៥៥.០៧១.២៥៤ | ៣.០៧២.៣២៥ | ១.១៤៨ | ៩៥.២៦១.០១១ | ១៤.៩១៦.៨០៧ | ៤.៤០៤.២៩៦.៥០០ |
| **ស្ថានភាពសុទ្ធនៅលើតារាងតុល្យការ** | (៤.១៥៣.៧៨៤) | ១១១.២៣២.២៩២ | (១.៥០៨.០៨៨) | ៧៤២.១៦៧ | ៣៨១.១៩១ | ៣៧.៥៨៩.០៤៣ | ១១.៨២០.៧១៣ | ១៥៦.១០៣.៥៣៤ |
| **សមមូលនឹងពាន់រៀល** (កំណត់សម្គាល់ ៤) | (១៦.៧៦៨.៨២៦) | ៤៤៩.០៤៤.៧៦៣ | (៦.០៨៨.១៥១) | ២.៩៩៦.១២៨ | ១.៥៣៨.៨៦៨ | ១៥១.៧៤៦.៩៦៧ | ៤៧.៧២០.២១៨ | ៦៣០.១៨៩.៩៦៧ |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ១.៥៩៧.៩០៧ | ១១០.០៥៦.៩០៤ | ១៦៥.៨៦៦ | - | - | - | - | ១១១.៨២០.៦៧៧ |
| កិច្ចសន្យាប្តូររូបិយប័ណ្ណនាពេលអនាគត | - | - | - | ៦៨៤.០៨៥ | - | - | - | ៦៨៤.០៨៥ |
| លិខិតធានាធនាគារ លិខិតទទួលស្គាល់ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ | ១.៥៤៩.១៥៩ | ៥៧.៥០២.០៩៤ | ១៧៥.៣៩៤ | ១.៣៣៨.២៧២ | - | - | ៨៨.៣៥៤ | ៦០.៦៥៣.២៧៣ |
| **កិច្ចសន្យាត្រូវសង** | ៣.១៤៧.០៦៦ | ១៦៧.៥៥៨.៩៩៨ | ៣៤១.២៦០ | ២.០២២.៣៥៧ | - | - | ៨៨.៣៥៤ | ១៧៣.១៥៨.០៣៥ |
| **សមមូលនឹងពាន់រៀល** (កំណត់សម្គាល់ ៤) | ១២.៧០៤.៧០៥ | ៦៧៦.៤៣៥.៦៧៥ | ១.៣៧៧.៦៦៧ | ៨.១៦៤.២៥៥ | - | - | ៣៥៦.៦៨៦ | ៦៩៩.០៣៨.៩៨៨ |

| | ធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សមមូលជាប្រាក់ដុល្លារអាមេរិក | | | | | | | |
| | ប្រាក់រៀល | ប្រាក់ដុល្លារអាមេរិក | ប្រាក់បាតថៃ | ប្រាក់អឺរ៉ូ | ប្រាក់ដុល្លារអូស្ត្រាលី | ប្រាក់គីបឡាវ | រូបិយប័ណ្ណផ្សេងៗ | សរុប |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | | | | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧៤.០៤១.៧៥៣ | ៣០៥.៩៨០.៤៦៧ | ១៤.៥១៤.៥២៣ | ១.៨០៤.០០២ | ២៨០.២៥៨ | ៩១៥ | ១.៧៩០.២៦៦ | ៣៩៨.០១២.១៨៤ |
| សមតុល្យនៅធនាគារកណ្តាល | ៧៣.១៥០.១៨០ | ៨៥០.៤៧៧.៥៩៨ | - | - | - | - | - | ៩២៣.៦២៧.៧៧៨ |
| សមតុល្យនៅធនាគារផ្សេងៗ | - | ២១.៤១៥.៨៥១ | ៣៨៩.៩៤៩ | ១.៨៧០.៣៧១ | - | - | ៦៦៣.៥០៥ | ២៤.៣៣៩.៦៧៦ |
| ឥណទាន និង បុរេប្រទានអតិថិជន | ៤០៩.៤៥០.៤៣៤ | ២.៩៤៤.១៩៧.៧៦១ | ២៥.០៧១.០២០ | - | - | - | - | ៣.៣៧៨.៦៦៩.២១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៣.៨៣០.៦៦៨ | ២៨.៤១៣.៤៧២ | ២៧០.៦៥៥ | - | - | - | - | ៣២.៥១៤.៧៩៥ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៥៦០.៤៧៣.០៣៥ | ៤.១៥០.០៣៥.១៩៩ | ៤០.២៤៦.១៤៧ | ៣.៦៧៤.៣៧៣ | ២៨០.២៥៨ | ៩១៥ | ២.៤៥៣.៧៧១ | ៤.៧៥៧.១៦៣.៦៤៨ |
| បំណុលហិរញ្ញវត្ថុ | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ២៨.៥១៥.៩៤៦ | ២៤៦.៣១៤.៥២៦ | ៨.១៨៦.៣៥៤ | - | - | - | - | ២៨៣.០១៦.៨២៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៤៦២.៧៧៣.៩៥០ | ២.៩៣៤.៤៩១.៨១១ | ២៩.៦៩៩.៥៥៥ | ៣.៤១៩.៧៤៩ | ២២៦ | - | ១.២៨១ | ៣.៤៣០.៣៨៦.៥៧២ |
| បំណុលផ្សេងៗ | ៧.៧៩៧.០២៧ | ៦២.៥៦៣.២៧៣ | ៧២.៤៩៣ | ២២១.៦០៤ | - | - | ៧៣.៣៦៤ | ៧០.៧២៧.៧៦១ |
| ប្រាក់កម្ចី | ៤៤.២២៥.៩៨៣ | ៣០៤.០២៣.៨១៦ | - | - | - | - | - | ៣៤៨.២៤៩.៧៩៩ |
| បំណុលបន្ទាប់បន្សំ | - | ៧៧.១០១.៩៥០ | - | - | - | - | - | ៧៧.១០១.៩៥០ |
| បំណុលហិរញ្ញវត្ថុសរុប | ៥៤៣.៣១២.៩០៦ | ៤.០៦៤.៤៩៤.៩១៦ | ៣៧.៩៥៨.៤០២ | ៣.៦៤១.៣៥៣ | ២២៦ | - | ៧៤.៦៤៥ | ៤.៦៤៩.៤៨២.៤៤៨ |
| ស្ថានភាពសុទ្ធនៅលើតារាងតុល្យការ | ១៧.១៦០.១២៩ | ៨៥.៥៤០.២៨៣ | ២.២៨៧.៧៤៥ | ៣៣.០២០ | ២៨០.០៣២ | ៩១៥ | ២.៣៧៩.១២៦ | ១០៧.៦៨១.២០០ |
| សមមូលនឹងពាន់រៀល ( កំណត់សម្គាល់ ៤ ) | ៦៨.៩៤៩.៣៩៩ | ៣៤៣.៧០០.៦៥៦ | ៩.១៩២.១៥៩ | ១៣២.៦៧៤ | ១.១២៥.១៦៩ | ៣.៦៧៦ | ៩.៥៥៩.៣២៨ | ៤៣២.៦៦៣.០៦១ |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | ២.១៥២.៥៨៣ | ៩៩.២២៩.២០៥ | ២៤៥.៩៤០ | - | - | - | - | ១០១.៦២៧.៧២៨ |
